

## សមាគមព្រះគម្ពីរកម្ពុជាច្រានចោលការចោទប្រកាន់និងព្រមានចាត់វិធានការ

សមាគមព្រះគម្ពីរកម្ពុជា សូមធ្វើការបដិសេធទាំងស្រុងនូវរាល់ព័ត៌មានទាំងឡាយណាដែលមានប្រភពមិនច្បាស់លាស់ ដែលបានលើកឡើងចោទប្រកាន់ដោយគ្មានមូលដ្ឋាន និងគ្មានភស្តុតាងនៅលើបណ្តាញសង្គមដែលផ្ទុយពីសេចក្តីប្រកាសព័ត៌មាននេះ។ <ទំព័រ-១៨-១៩

កាសែតចេញផ្សាយ
ប្រចាំខែ ឆ្នាំទី១២

# អ្នកនាំសារ the messenger

ខែ សីហា | ឆ្នាំ ២០២០ | លេខទី ១៣០

www.catholiccambodia.org/km/ www.facebook.com/RVAKHMER/ www.khmer.rvasia.org/

AUGUST, 2020 | #130

# ពិធីប្រគល់និងទទួលផែនទីឋានលេខាព្រំដែនកម្ពុជា – វៀតណាម មាត្រដ្ឋាន ១/២៥០០០

## សមត្ថកិច្ចចាប់ខ្លួនលោក រ៉ុង ឈុន ព្រោះរឿងព្រំដែនកម្ពុជា-វៀតណាម

ទំព័រ៖ ៤-៥

## របាយការណ៍៖ ការរំលោភសិទ្ធិមនុស្ស និងបំផ្លាញបរិស្ថាននៅពេលអភិវឌ្ឍ របស់ឯកជនគំរាមកំហែងធ្វើឱ្យមានការជន់លិចនៅក្នុងរាជធានីភ្នំពេញ

ទំព័រ៖ ១០-១១





## វប្បធម៌សិល្បៈនិងអក្សរសាស្ត្រខ្មែរនាពេលសព្វថ្ងៃកំពុងឈានទៅរកភាពបាត់បង់

ទំព័រ-១៦

# សូមកុំប្រហែស ជាមួយមេរោគឆ្លង កូវីដ១៩



*ប្រជាពលរដ្ឋត្រូវបានពិនិត្យ និងវាស់កំដៅមុនពេលអនុញ្ញាតឱ្យចូលរួមទស្សនាកំសាន្តកម្មវិធីនាខេត្តសៀមរាបក្នុងឱកាសឈប់ស្រមាកសង។*
***រូបភាព៖ រដ្ឋបាលខេត្តសៀមរាប***

*ដោយ៖ លី សុវណ្ណា*

បងប្អូន ថ្ងៃដែលបងប្អូនតែងទន្ទឹងរង់ចាំបានមកដល់ហើយ រាជរដ្ឋាភិបាល បានសម្រេចឱ្យ គ្រប់ស្ថាប័ន រោងចក្រ សហគ្រាសនានា ឈប់សម្រាកជំនួសថ្ងៃឈប់សម្រាក បុណ្យចូលឆ្នាំថ្មី ប្រពៃណីជាតិខ្មែរ កាលពីខែមេសាកន្លងទៅ ដែលរាជរដ្ឋាភិបាលបានលើកពេលឈប់សម្រាប់ ដើម្បីប្រយុទ្ធនឹងមេរោគឆ្លងកូវីដ១៩ ដែលកំពុងរីករាលដាលពេញពិភពលោកនាពេលនេះ។

កាលពីខែមេសាកន្លងទៅ យើងទាំងអស់គ្នាមិនបានឈប់សម្រាក គឺព្រោះតែការទប់ស្កាត់ ការឆ្លងរីករាលដាល នៃមេរោគឆ្លង កូវីដ១៩។ រហូតមកដល់ពេលនេះ មេរោគនេះ នៅមិនទាន់ស្រាកស្រាននៃការឆ្លងពីមនុស្សម្នាក់ទៅម្នាក់នៅឡើយ ហើយក៏បានបង្ករឱ្យមានអ្នកស្លាប់ជារៀងរាល់ថ្ងៃផងដែរ។

កន្លងទៅរាជរដ្ឋាភិបាល បានហាមប្រាមការជួបជុំនានាបែបសាសនា បិទសាលារៀន កន្លែងកំសាន្ត ជាដើម រារាំងការជួបជុំប្រមូលផ្តុំដែលមានមនុស្សច្រើន ហើយបងប្អូនប្រាកដជាចាំបានថា ថ្មីៗនេះម្នាក់ៗមានការភ័យខ្លាចណាស់ និងអនុវត្តន៍បានយ៉ាងប្រុងប្រយ័ត្នតែមួយរយៈពេលនេះ ហាក់ដូចជា ព្រងើយកន្តើយ។ ក្នុងរយៈពេលនៃការឈប់សម្រាកនេះទៀត ប្រាកដណាស់ បងប្អូន នឹងជួបជុំ តាមគ្រួសារ ជួបជុំនៅកន្លែងរមនីយ៍ដ្ឋានណាមួយ។ល។ ទៅតាមផែនការដែលបងប្អូនបានគ្រោងទុក។

មានបងប្អូនច្រើនណាស់មិនបានយកចិត្តទុកដាក់នោះឡើយ ព្រោះថាកម្ពុជា មិនទាន់មានករណីឆ្លងជំងឺនេះក្នុងសហគមន៍នោះឡើយ។ តាមរបាយការណ៍របស់ក្រសួងសុខាភិបាល រហូតមកដល់ថ្ងៃទី២១ ខែសីហា កម្ពុជាមានអ្នកឆ្លងមេរោគកូវីដ១៩ សរុបចំនួន ២៧៣ ករណី អ្នកជាសះស្បើយ ចំនួន ២៥៩ នាក់។ ករណីទាំងអស់គឺនាំចូលមកពីបរទេស ដោយសារប៉ុន្មានថ្ងៃនេះមានករណីថ្មីកើនឡើង រាជរដ្ឋាភិបាលសម្រេច ផ្អាកទទួលការហោះហើររបស់ក្រុមហ៊ុនអាកាសចរ ដែលមកពី ប្រទេសឥណ្ឌូណេស៊ី ម៉ាឡេស៊ី ហ្វីលីពីន អឺរ៉ុប...ជាដើម។

នៅលើពិភពលោករហូតមកដល់ថ្ងៃទី១៣ ខែសីហានេះ វាបានឆ្លងដល់ទៅជាង ២០ លាននាក់ ហើយសម្លាប់មនុស្សជាង ៧៤៧.០០០ នាក់ ហើយអ្នកវិទ្យាសាស្ត្រមិនទាន់រកថ្នាំវ៉ាក់សាំងបង្ការបាននៅឡើយទេ។

រាជរដ្ឋាភិបាលតាមរយៈក្រសួងសុខាភិបាល បានរំលឹកយើងទាំងអស់គ្នាម្តងហើយម្តងទៀត ត្រូវយកចិត្តទុកដាក់អំពីការការពារខ្លួន រក្សាអនាម័យជានិច្ច។

ពិតហើយ ក្នុងមួយរយៈពេលនេះ បងប្អូនប្រហែលជាអាចប្តូររបៀបរស់នៅរបស់ខ្លួនបានតាមរបៀបថ្មីស្របតាមការណែនាំរបស់ក្រសួងសុខភិបាល។ កុំភ្លេចខ្លួន ! តាមព្រះសហគមន៍ពេលនេះ ក៏មានការជួបជុំក្រុមតូចៗដែរ ហេតុនេះត្រូវរក្សាជានិច្ច អំពីគម្លាតសង្គម។ អ្នកនាំពាក្យរបស់ក្រសួងសុខាភិបាល លោកស្រី ឱ វណ្ណឌីន បានមានប្រសាសន៍ថា «លទ្ធភាពនៃការចម្លងវីរុសកូវីដ១៩ ចូលសហគមន៍ យើងមិនអាចមើលរំលងបានឡើយ។ ដូច្នេះហើយ បានជាក្រសួងសុខាភិបាល តែងតែអំពាវនាវហើយអំពាវនាវទៀត ឱ្យបងប្អូនប្រជាពលរដ្ឋ ត្រូវតែបន្តកិច្ចការពារខ្លួនជាប់ជានិច្ច។ សូមអ្នកដើរកំសាន្តទាំងអស់ ត្រូវតែចេះប្រុងប្រយ័ត្នមែនទែន ដោយសារហានិភ័យនៃការចម្លងវីរុសកូវីដ១៩ ដែលអាចកើតមានគ្រប់ពេលវេលា គ្រប់កាលៈទេសៈ និងគ្រប់ទីកន្លែងទាំងអស់។ សុំកុំភ្លេចខ្លួន និងសុំកុំសន្តិភាពនិយមជាមួយវីរុសកូវីដ១៩ នេះឱ្យសោះ»។

នៅក្នុងអំឡុងពេលឈប់សម្រាកដែលមានរយៈពេល៩ថ្ងៃនេះ សូមចូលរួម បង្កាខ្លួនយើងកុំឱ្យចម្លងទៅអ្នកដទៃទៀត។ ក្រសួងបានចេញវិធានការបង្ការជាច្រើន ប៉ុន្តែ ចំណុចដែលយើងគួរយកចិត្តទុកដាក់នោះ គឺទៅណាមកណាត្រូវពាក់ម៉ាស់ពីព្រោះវាអាចជួយកាត់បន្ថយការចម្លងពីយើងទៅអ្នកដទៃ និងអាចការពារយើងមិនឱ្យឆ្លង កុំឧស្សាហ៍យកដៃទៅប៉ះផ្ទៃមុខ ត្រូវលាងដៃនឹងសាប៊ូ ឬ ជែល ឬ អាល់កុល ជាប្រចាំ ទទួលទានអាហារដែលមានអនាម័យចំអិនឆ្អិនល្អ រក្សាគុណភាពអាហារ ព្យាយាមអនុវត្តឱ្យបាននូវគម្លាតសង្គម និង បុគ្គល ហើយគួរកាត់បន្ថយសកម្មភាពជួបជុំមនុស្សច្រើន។ ពេលក្អកឬកណ្តាស់ត្រូវតែ ខ្ទប់មាត់នឹងក្រដាសអនាម័យឬ កែងដៃបើគ្មាន ... ។

បងប្អូនជាទីស្រឡាញ់អ្នកនាំសារ សូមរំលឹកបងប្អូនដែរថា នៅកម្ពុជាក៏មានអ្នកលាប់ជំងឺនេះដែរ ជាសះស្បើយហើយ ក៏វិលត្រលប់មកជាវិជ្ជមានវិញដែរ ហេតុដូចនេះលទ្ធភាពឆ្លងចូលសហគមន៍មានច្រើនណាស់។

សន្តិតេរេសា នៃគុលគូថា បានមានប្រសាសន៍ថា៖ «ចរិតពិតរបស់បងប្អូនត្រូវបានវាស់វែងយ៉ាងត្រឹមត្រូវបំផុតពីរបៀបដែលបងប្អូនប្រព្រឹត្តចំពោះអ្នកដែលមិនអាចធ្វើអ្វីបានសម្រាប់បងប្អូន។ បងប្អូនគោរពខ្លួនឯង និងមនុស្សជុំវិញបងប្អូន ដោយសេចក្តីស្រឡាញ់ជាប្រការសំខាន់ ដែលការអធិដ្ឋាន និងព្រះបន្ទូលមានជីវិតក្នុងបងប្អូន»។

សរុបមកវិញ សូមបងប្អូនមានការប្រុងប្រយ័ត្នខ្ពស់ចំពោះការរីករាលដាលនៃមេរោគកូវីដ ១៩នៅក្នុង ប្រទេសរបស់យើង។ សូមចូលរួមការពារកុំឱ្យវាមានករណីដូចជានៅប្រទេសជិតខាងយើងមាន ថៃ វៀតណាម និង ប្រទេសនៅក្នុងតំបន់ឯទៀត ដូចជា សិង្ហបុរី ឥណ្ឌូនេស៊ី ហ្វីលីពិន ម៉ាឡេស៊ី ជាដើម ហើយមួយវិញទៀត ក្រៅពីជំងឺកូវីដ១៩ នេះយើងទាំងអស់គ្នាក៏គួរតែយកចិត្តទុកដាក់ចំពោះគ្រោះថ្នាក់ចរាចរណ៍ គ្រប់គ្រងការប្រើប្រាស់គ្រឿងស្រវឹង និង យកចិត្តទុកដាក់រឿងសន្តិសុខផ្ទាល់ខ្លួន ផ្ទះសម្បែង នៅមុនពេលទៅណាមកណា។ សូមអរគុណនិងសូមជូនពរ!

CSC
Formation, Dailouge, Cooperation
ការិយាល័យផ្សព្វផ្សាយព័ត៌មានកាតូលិក

ចាងហ្វាង : លោក លី សុវណ្ណា
សេចក្តីប្រកាសលេខ៖ ០៦០/១៩ ព.ម.ព.ល.អ/ ១៥-មករា-២០១៩
ផ្ទះលេខ ២៥ ផ្លូវលេខ ២៤២ សង្កាត់ បឹងព្រលិត ខណ្ឌ ៧ មករា រាជធានីភ្នំពេញ
Tel/Fax : (855) 23 224 120
Email : csccambodia@gmail.com / Website : www.catholiccambodia.org
Email : catholicphnompenh@gmail.com / Website : www.catholicphnompenh.org
https://www.facebook.com/CatholicCambodia / https://www.facebook.com/CatholicPhnomPenh



# មជ្ឈមណ្ឌលឯកសារកម្ពុជាដាក់ឈ្មោះ បណ្ណាល័យថា «បណ្ណាល័យសម្តេចម៉ែ»



*លោក ឆាំង យុ នាយកមជ្ឈមណ្ឌលឯកសារកម្ពុជា ចូលក្រាបបង្គំចូលគាល់ព្រះវររាជមាតា នេរាត្តម មុនិនាថ សីហនុ។ **រូបភាព៖ DC-CAM***

*អត្ថបទ៖ អមរិន្ទ ដានុត*

ដើម្បីធ្វើការទទួលស្គាល់ការចូលរួមចំណែកដ៏មានតម្លៃនេះ ព្រមទាំងជាការថ្វាយព្រះកិត្តិយសជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត ចំពោះកិច្ចខិតខំប្រឹងប្រែងពេញមួយជីវិតរបស់ព្រះវររាជមាតា សម្តេចព្រះនរោត្តម មុនិនាថ សីហនុ ចំពោះប្រទេសកម្ពុជា មជ្ឈមណ្ឌលឯកសារកម្ពុជា នឹងដាក់ឈ្មោះបណ្ណាល័យរបស់ខ្លួនថា«បណ្ណាល័យសម្តេចម៉ែ» ដោយទទួលបានព្រះរាជានុញ្ញាតពីសម្តេចព្រះវររាជមាតា។

ការដាក់ឈ្មោះនេះបន្ទាប់ពី នាពេលថ្មីៗនេះ ឯកអគ្គរាជទូតបណ្ឌិត ហ្វូលីយ៉ូ ជែលជ្រេស អតីតលេខាផ្ទាល់និងជាអ្នកនិពន្ធជីវប្រវត្តិរបស់ព្រះករុណា ព្រះមហាវីរក្សត្រ ព្រះបរមរតនកោដ្ឋ នរោត្តមសីហនុ បានបរិច្ចាគសមុច្ច័យផ្ទាល់ខ្លួនទាំងស្រុងរបស់លោកដែលរួមមាន សៀវ ភៅនិង ឯកសារផ្សេងៗ មកកាន់បណ្ណាល័យរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា។

នៅថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០២០ លោក ឆាំង យុ នាយកមជ្ឈមណ្ឌលឯកសារកម្ពុជា បានក្រាបបង្គំចូលគាល់ព្រះវររាជមាតានិងរាជវង្សានុវង្សដើម្បីប្រកាសថ្វាយឈ្មោះនេះជាផ្លូវការ។ នៅថ្ងៃទី១១ ខែកក្កដា ឆ្នាំ២០២០ ព្រះវររាជមាតាទ្រង់បានសព្វព្រះហឫទ័យរាជានុញ្ញាតឱ្យប្រើប្រាស់ឈ្មោះបណ្ណាល័យនេះ។

យោងតាមលិខិតរបស់មជ្ឈមណ្ឌលឯកសារកម្ពុជាដែល RVAKhmer ទទួលបាននៅថ្ងៃចន្ទ ទី២០ ខែកក្កដា ឆ្នាំ២០២០ នេះបានលើកឡើងថា ថ្វាយព្រះកិត្តិយសជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុតដល់សម្តេចម៉ែដែលជាសម្តេចព្រះមហាក្សត្រីព្រះវររាជមាតាជាតិខ្មែរ ក្នុងព្រះសកម្មភាពគាំពារការសិក្សាស្រាវជ្រាវ និងការលើកស្ទួយប្រវត្តិសាស្ត្រ វប្បធម៌ ព្រមទាំងសិល្បៈសហសម័យនៃប្រទេសកម្ពុជាការសិក្សាស្រាវជ្រាវ ការអប់រំ និងវប្បធម៌ គឺមានសារសំខាន់ ចំពោះអត្តសញ្ញាណនិងការអភិវឌ្ឍរបស់ប្រទេសជាតិមួយនិងការបោះជំហានទៅមុខរបស់មនុស្សជាតិ។

មជ្ឈមណ្ឌលឯកសារកម្ពុជា ពុះពារធានាថាប្រវត្តិសាស្ត្រនិងសិល្បៈរបស់ប្រទេសកម្ពុជា ទាំងបុរាណ និងសហសម័យនឹងត្រូវបានអភិរក្ស ការពារ និងបើកទូលាយសម្រាប់សាធារណជនទូទៅ។

ប្រភពដដែលបានបន្តថា បន្ថែមពីលើសមុច្ច័យរបស់ឯកអគ្គរាជទូតបណ្ឌិត ហ្វូលីយ៉ូ ជែលជ្រេស បណ្ណាល័យសម្តេចម៉ែ មានតម្កល់ទុកឯកសារប្រវត្តិសាស្ត្រ សៀវ ភៅ និងសម្ភារផ្សេងៗ ស្តីពីអំពើប្រល័យពូជសាសន៍ និងសិទ្ធិមនុស្សនៅប្រទេសកម្ពុជា។ មជ្ឈមណ្ឌលឯកសារកម្ពុជា កំពុងនឹងបន្តពង្រីកបន្ថែមនូវចំនួនបណ្តុំឯកសាររបស់ខ្លួន។ បណ្ណាល័យនេះនឹងជាប្រភពធនធានដ៏មានសារសំខាន់មួយសម្រាប់សិស្សានុសិស្សនិងអ្នកស្រាវជ្រាវទូទៅ ដោយដើរតួនាទីជាស្ថាប័នមួយដែលបើកទូលាយសម្រាប់សាធារណជន ដើម្បីបង្កើនការយល់ដឹងអំពីប្រវត្តិសាស្ត្រ វប្បធម៌ និងសិល្បៈសហសម័យរបស់កម្ពុជា។

«បណ្ណាល័យសម្តេចម៉ែ» នឹងដើរតួនាទីជាទីតម្កល់ទុកឯកសារបណ្ណសារ សៀវ ភៅ និងសម្ភារផ្សេងៗដែលមានសារៈសំខាន់ចំពោះជាតិ រហូតដល់មានវត្តមានរបស់វិទ្យាស្ថានស្លឹករឹត ដែលជាបូជនីយដ្ឋាននៃការចងចាំពិភពលោកមួយ រចនាឡើងដោយលោកស្រី ហ្សាហាហាឌីដ ដើម្បីឧទ្ទិសជូនដល់វិញ្ញាណខន្ធជនរងគ្រោះនៃអំពើប្រល័យពូជសាសន៍នៅជុំវិញពិភពលោក។

មជ្ឈមណ្ឌលឯកសារកម្ពុជា គឺកំពុងបន្តស្រាវជ្រាវរកមូលនិធិគាំទ្រវិទ្យាស្ថានស្លឹករឹតនិងធ្វើការជាមួយរដ្ឋាភិបាលកម្ពុជា ដើម្បីទទួលបានការគាំទ្រសម្រាប់អនាគតដៃគូវិនិយោគរបស់ខ្លួន។ នៅពេលបញ្ចប់ការសាងសង់ វិទ្យាស្ថានស្លឹករឹត បន្ថែមលើបណ្ណាសារនឹងរួមមាន សារមន្ទីរមជ្ឈមណ្ឌលសិក្សាស្រាវជ្រាវលើអំពើប្រល័យពូជសាសន៍ មជ្ឈមណ្ឌលអប់រំស្តីពីការសិក្សានិងបង្ការអំពើប្រល័យពូជសាសន៍ និងសាវនដ្ឋានសម្រាប់រៀបចំពិព័រណ៍ ការប្រគុំតន្ត្រី និងការធ្វើបទបង្ហាញនានា។

ការបង្កើតឱ្យមាន «បណ្ណាល័យសម្តេចម៉ែ» គឺជាព្រឹត្តិការណ៍មួយដ៏មានសារសំខាន់ចំពោះជាតិ។ ការបង្កើតជា «បណ្ណាល័យសម្តេចម៉ែ» គឺមិនត្រឹមតែបង្ហាញ អំពីការចាប់ផ្តើមកកើតធនធានថ្មីសម្រាប់ការអប់រំ ការសិក្សាស្រាវជ្រាវ និងការលើកស្ទួយសិល្បៈសហសម័យតែប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងជាការទទួលស្គាល់ចំពោះការលះបង់របស់ព្រះវររាជមាតាជូនដល់ ព្រះករុណា ព្រះមហាវីរក្សត្រ ព្រះបរមរតនកោដ្ឋ នរោត្តម សីហនុ និងការពុះពារ របស់ព្រះវររាជមាតាដ៏ខ្ពង់ខ្ពស់ ចំពោះប្រជាជនកម្ពុជា៕

# កុមារខ្វះអាហារូបត្ថម្ភនឹងកើនឡើងក្នុង អំឡុងនៃការរីករាលដាលជំងឺកូវីដ១៩



***រូបភាព៖ ស៊ីអេសស៊ី***

*អត្ថបទ៖ អមរិន្ទ ដានុត*

អត្រាខ្ពស់នៃភាពស្គមស្គាំងនិងការខ្វះអាហារូបត្ថម្ភរបស់កុមារកម្ពុជាត្រូវគេរំពឹងទុកថានឹងកើនឡើងដែលបណ្តាលមកពីបញ្ហាសង្គមសេដ្ឋកិច្ចបង្កឡើងដោយជំងឺកូវីដ១៩។ នេះបើយើងយោងតាមរបាយការណ៍របស់អង្គការយូនីសេហ្វ។

អង្គការយូនីសេហ្វបានចេញសេចក្តីប្រកាសព័ត៌មាននាដើមខែសីហា ឆ្នាំ ២០២០កន្លងមកថា កុមារអាយុក្រោម ៥ឆ្នាំចំនួន ៦,៧ លាននាក់បន្ថែមទៀតនៅទូទាំងពិភពលោកអាចរងគ្រោះពីបញ្ហាស្គមស្គាំង (ទម្ងន់ស្រាលធៀបនឹងអាយុ) នៅឆ្នាំនេះ ដែលបណ្តាលមកពីផលប៉ះពាល់ពីជំងឺកូវីដ១៩។

ប្រភពដដែលបានលើកឡើងថា ក្នុងឆ្នាំ២០២០ នៅទូទាំងពិភពលោក មានកុមារអាយុក្រោម៥ឆ្នាំចំនួន ៦,៧ លាននាក់បន្ថែមទៀត អាចរងគ្រោះពីបញ្ហាស្គមស្គាំងដែលបណ្តាលឱ្យពួកគេជួបប្រទះនឹងបញ្ហាខ្វះអាហារូបត្ថម្ភរហូតដល់កម្រិតគ្រោះថ្នាក់ ដោយសារតែផលប៉ះពាល់សង្គមសេដ្ឋកិច្ចបង្កឡើងដោយការរាតត្បាតជាសកលនៃជំងឺកូវីដ១៩។

លោកស្រី ហិនរីតា ហ្វ័រ នាយិកាប្រតិបត្តិយូនីសេហ្វ បានមានប្រសាសន៍ថា វាមានរយៈពេល៧ខែកន្លងមកហើយ ចាប់តាំងពីមានការរាយការណ៍ពីករណីជំងឺកូវីដ១៩ដំបូងៗ ហើយភស្តុតាងបានបង្ហាញកាន់តែច្បាស់ថា ផលប៉ះពាល់ចេញពីការរាតត្បាតជាសកលនេះកំពុងបង្កគ្រោះថ្នាក់ដល់កុមារ ច្រើនជាងគ្រោះថ្នាក់ដែលបង្កដោយជំងឺនេះផ្ទាល់។

នៅតាមបណ្តាប្រទេសនានាដូចជាប្រទេសកម្ពុជាជាដើម ផលប៉ះពាល់មកលើសង្គមសេដ្ឋកិច្ចកំពុងបំផ្លាញសន្តិសុខស្បៀងជីវភាពរស់នៅ និងសេដ្ឋកិច្ចប្រទេស។ កត្តានេះបណ្តាលឱ្យធនធាននៃគ្រួសារកាន់តែមានតិចទៅ និងជាហេតុនាំឱ្យប៉ះពាល់អវិជ្ជមានដល់អាហារូបត្ថម្ភកុមារ។

អង្គការយូនីសេហ្វបានបន្តថា ការបាត់បង់ការងារ ជាទូទៅធ្វើឱ្យមនុស្សត្រូវខ្ចីបុលអ្នកដទៃសម្រាប់ទិញអាហារហូបចុក កាត់បន្ថយការទទួលទានអាហាររបស់ពួកគេ និងផ្លាស់ប្តូរប្រភេទអាហារដែលពួកគេធ្លាប់បរិភោគ។

តម្លៃស្បៀង ជាពិសេសសាច់ ស៊ុត និងត្រីមួយចំនួននៅទីក្រុងភ្នំពេញ និងបន្លែស្រស់នៅក្នុងផ្សារតាមបណ្តាខេត្ត ក៏មានការកើនឡើងផងដែរ នេះបើតាមព័ត៌មានបច្ចុប្បន្នភាពសេដ្ឋកិច្ចប្រទេសកម្ពុជា ដែលចេញផ្សាយដោយធនាគារពិភពលោកនៅដើមឆ្នាំ២០២០កន្លងមកនេះ។

គួរបញ្ជាក់ផងដែរថា នៅក្នុងរយៈពេលជាច្រើនឆ្នាំកន្លងមក ប្រទេសកម្ពុជាបានសម្រេចនូវវឌ្ឍនភាពដ៏គួរឱ្យកត់សម្គាល់ក្នុងការលើកកម្ពស់អាហារូបត្ថម្ភកុមារតាមរយៈការកាត់បន្ថយអត្រាក្រិសក្រិន (កម្ពស់ទាបធៀបនឹងអាយុ) ពី ៤២% ក្នុងឆ្នាំ២០០៥ មកនៅ ៣២% នៅឆ្នាំ២០១៤។

ទោះជាយ៉ាងនេះក្តី ទិន្នន័យដែលមានស្រាប់នៃបញ្ហាស្គមស្គាំង (ទម្ងន់ស្រាលធៀបនឹងកម្ពស់) បង្ហាញថាមានការកើនឡើងពី៨% ក្នុងឆ្នាំ២០០៥ ទៅ ៩,៦% នៅឆ្នាំ២០១៤។

សេចក្តីរាយការណ៍ The Lancet បានរកឃើញថា អត្រាប្រេវ៉ាឡង់នៃភាពស្គមស្គាំងរបស់កុមារអាយុក្រោម៥ឆ្នាំនៅទូទាំងសកលលោកនៅឆ្នាំនេះ អាចកើនឡើង ១៤,៣% នៅតាមប្រទេសដែលមានចំណូលទាប និងចំណូលមធ្យម ព្រោះតែផលប៉ះពាល់សង្គមសេដ្ឋកិច្ចដែលបង្កឡើងដោយជំងឺកូវីដ១៩។

នាយករងយូនីសេហ្វប្រចាំកម្ពុជា លោក ចាឡាក់ អាប់ឱលវ៉ា ហាប់ បានមានប្រសាសន៍ថា៖ «ការខកខានពុំបានព្យាបាលករណីខ្វះអាហារូបត្ថម្ភស្រួចស្រាវបន្ថែមនូវបន្ទុកនៃករណីឈឺនិងស្លាប់របស់កុមារអាយុក្រោម៥ឆ្នាំនៅកម្ពុជា»។

លោកបានបន្តថា យូនីសេហ្វក្នុងភាពជាដៃគូជាមួយក្រសួងសុខាភិបាលកំពុងខិតខំប្រឹងប្រែងគាំទ្រដល់ការព្យាបាលបញ្ហាខ្វះអាហារូបត្ថម្ភស្រួចស្រាវ ដើម្បីឱ្យកុមារគ្រប់រូបអាចចម្រើនលូតលាស់ និងអភិវឌ្ឍខ្លួនឈានទៅសម្រេចសក្តានុពលពេញលេញរបស់ខ្លួន៕





*លោក រ៉ុង ឈុន ត្រូវបានសមត្ថកិច្ចនៃស្នងការដ្ឋាននគរបាលរាជធានីភ្នំពេញធ្វើការឃាត់ខ្លួននាយប់ថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០២០ ពាក់ព័ន្ធនឹងបទល្មើសជាក់ស្ដែងញុះញង់ឱ្យមានភាពវឹកវរដល់សន្តិសុខសង្គមលើបញ្ហាព្រំដែនកម្ពុជា។* ***សហការី***

# សមត្ថកិច្ចក្រុងភ្នំពេញចាប់និងឃុំខ្លួន លោក រ៉ុង ឈុន ព្រោះរឿងព្រំដែនកម្ពុជា–វៀតណាម

*អត្ថបទ៖ អមរិន្ទ ដានុត*

ប្រធានសហភាពសហជីពកម្ពុជាដ៏ល្បីមួយរូប និងជាតំណាងក្រុមប្រឹក្សាឃ្លាំមើលកម្ពុជា លោក រ៉ុង ឈុន ត្រូវបានសមត្ថកិច្ចនៃស្នងការដ្ឋាននគរបាលរាជធានីភ្នំពេញធ្វើការឃាត់ខ្លួននាយប់ថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០២០ ពាក់ព័ន្ធនឹងបទល្មើសជាក់ស្ដែងញុះញង់ឱ្យមានភាពវឹកវរដល់សន្តិសុខសង្គមលើបញ្ហាព្រំដែនកម្ពុជា។

ការឃាត់ខ្លួនលោក រ៉ុង ឈុន ត្រូវបានធ្វើឡើងប៉ុន្មានម៉ោងបន្ទាប់ពីគណៈកម្មាធិការចម្រុះកិច្ចការព្រំដែន បានចេញសេចក្ដីថ្លែងការណ៍ច្រានចោលទាំងស្រុងនូវសេចក្ដីថ្លែងការណ៍របស់លោក រ៉ុង ឈុន តំណាងក្រុមប្រឹក្សាឃ្លាំមើលកម្ពុជានិងជាប្រធានសហភាពសហជីពកម្ពុជាដែលបានផ្សាយព័ត៌មានមិនពិតនិងបំផ្លើសការពិតកាលពីថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០២០កន្លងមក។

លោក រ៉ុង ឈុន បានធ្វើការចោទថា ការបោះបង្គោលព្រំដែនពីលេខ១១៤ដល់លេខ១១៩ មានភាពមិនប្រក្រតីច្រើនដែលធ្វើឱ្យប្រជាពលរដ្ឋបាត់បង់ដីអាស្រ័យផលទៅខាងភាគីយួនជាច្រើនរយហិចតា ហើយបើគិតពីបន្ទាត់ព្រំដែនចាស់មកដល់ការបោះបង្គោលឡាក់ និងបង្គោលរណបថ្មី បានចូលមកប្រហែល៥០០ម៉ែត្រក្នុងដីកម្ពុជា ខ្សែបន្ទាត់ព្រំដែនចេះតែរំកិលបន្តិចម្ដងៗចូលមកក្នុងទឹកដីកម្ពុជាប្រមាណ៣គីឡូម៉ែត្របច្ចុប្បន្ននេះ និងថាអាជ្ញាធរយួនបានចូលរួមបណ្ដេញនិងរុញច្រានប្រជាពលរដ្ឋខ្មែរដែលរងគ្រោះពីដីធ្លីចូលប្រមាណជាង២០០ម៉ែត្រក្នុងដីខ្មែរ ដែលអាជ្ញាធរខ្មែរមិនបានទប់ស្កាត់ ចំពោះទង្វើអាជ្ញាធរយួនធ្វើមកលើពលរដ្ឋរងគ្រោះនៅឃុំត្រពាំងផ្លុង ស្រុកពញាក្រែក ខេត្តត្បូងឃ្មុំ។

ជាការឆ្លើយតបនឹងការចោទរបស់លោក រ៉ុង ឈុន ដូចនេះ គណៈកម្មាធិការចម្រុះកិច្ចការព្រំដែន បានប្រកាសបដិសេធចោលទាំងស្រុងនូវការចោទប្រកាន់នេះ ដោយបានលើកឡើងថា៖ «លោក រ៉ុង ឈុន និងគូកននៃក្រុមប្រឹក្សាឃ្លាំមើលកម្ពុជាដែលមានចេតនាបង្កើត ប្រឌិតរឿង និងផ្សព្វផ្សាយនូវព័ត៌មានក្លែងក្លាយដោយចេតនាទុច្ចរិត ក្នុងគោលបំណងបំភ័ន្តសាធារណៈមតិជាតិនិងអន្តរជាតិ ដោយធ្វើការចោទប្រកាន់គ្មានមូលដ្ឋានមកលើការងារព្រំដែនរបស់រាជរដ្ឋាភិបាលអំពីការធ្វើឱ្យបាត់បង់ទឹកដី ក៏ដូចជាការបណ្ដោយឱ្យមានការរំលោភបំពានទឹកដីពីប្រទេសជិតខាង ធ្វើឱ្យប្រជាពលរដ្ឋបាត់បង់ដីស្រែចំការនៅភូមិត្រពាំងផ្លុង ឃុំត្រពាំងផ្លុង ស្រុកពញាក្រែក ខេត្តត្បូងឃ្មុំ»។

គណៈកម្មាធិការចម្រុះកិច្ចការព្រំដែនអំពាវនាវដល់ជនរួមជាតិទាំងក្នុងនិងក្រៅប្រទេស កុំជឿនិងកុំចែកចាយរាល់ការបង្ហោះសេចក្ដីថ្លែងការណ៍បោកប្រាស់របស់លោក រ៉ុង ឈុននិងជនអគតិមួយចំនួនដែលតែងតែបង្កើតព័ត៌មានក្លែងក្លាយក្នុងចេតនាទុច្ចរិត ដើម្បីវាយប្រហារដល់កិច្ចការព្រំដែនរបស់រាជរដ្ឋាភិបាលហើយដែលសកម្មភាពទាំងអស់នេះអាចប្រឈមមុខនឹងផ្លូវច្បាប់។

### តុលាការក្រុងភ្នំពេញសម្រេចឃុំខ្លួន លោក រ៉ុង ឈុន នៅពន្ធនាគារព្រៃស

លោក រ៉ុង ឈុន ត្រូវបានសាលាដំបូងរាជធានីភ្នំពេញចោទប្រកាន់ជាផ្លូវការនៅល្ងាចថ្ងៃសៅរ៍ទី០១ ខែសីហា ឆ្នាំ២០២០ពីបទ «ញុះញង់បង្កឱ្យមានភាពវឹកវរធ្ងន់ធ្ងរដល់សន្តិសុខសង្គម តាមមាត្រា៤៩៥ នៃក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា» និងបានសម្រេចធ្វើការឃុំខ្លួនជាបណ្ដោះអាសន្ននៅពន្ធនាគារព្រៃស។ នេះបើតាមការបញ្ជាក់ពីអ្នកនាំពាក្យនៃសាលាដំបូងរាជធានីភ្នំពេញ និងជាព្រះរាជអាជ្ញារងលោក គុជ គឹមឡុង។




*លោក រ៉ុង ឈុន ត្រូវបានដល់សន្តិសុខសង្គមលើបញ្ហាព្រំដែនកម្ពុជា។* ***សហការី***

លោកបានថ្លែងថា៖ «ក្រោយពីសាកសួរតាមនីតិវិធីរួចរាល់ ចៅក្រមស៊ើបសួរ វ៉ាន់ សែនវិសុទ្ធ បានសម្រេចឃុំខ្លួនលោក រ៉ុង ឈុន ជាបណ្ដោះអាសន្ន»។

លោក សម សុខគង់ ជាមេធាវីការពារក្ដីឱ្យលោក រ៉ុង ឈុន បានឱ្យដឹងថា តុលាការចោទប្រកាន់កូនក្ដីរបស់លោកនេះគឺជារឿងមួយដែលមិនអាចទទួលយកបានទេ ដោយសារកូនក្ដីរបស់លោកមិនបានទៅធ្វើការញុះញង់នោះទេ។

លោកបានថ្លែងថា៖ «កូនក្ដីរបស់ខ្ញុំបានទៅធ្វើការងារសង្គម ហើយអ្វីដែលលោកបានលើកឡើងនៅក្នុងបណ្ដាញសង្គមរបស់លោកនោះ គឺជាការរកឃើញរបស់គាត់ ក៏ដូចជាការសម្ដែងនូវមតិដែលធានាដោយរដ្ឋធម្មនុញ្ញតែប៉ុណ្ណោះ»។ លោកបានប្រាប់បន្ថែមថា៖ «មកដល់ពេលនេះខ្ញុំមិនទាន់មានភស្តុតាងឬឯកសារសំណុំរឿងយកមកសិក្សានៅឡើយទេ ប៉ុន្តែយើងនឹងព្យាយាមចម្លងឯកសារយកមកសិក្សានិងភស្តុតាងបន្ថែមដើម្បីដោះបន្ទុករបស់លោក រ៉ុង ឈុន ដើម្បីឱ្យមានសេរីភាពឡើងវិញ»។









*លោក រ៉ុង ឈុន បានធ្វើការចោទថា ការបោះបង្គោលព្រំដែនពីលេខ១១៤ដល់លេខ១១៩ មានភាពមិនប្រក្រតីច្រើនដែលធ្វើឱ្យប្រជាពលរដ្ឋបាត់បង់ដីអាស្រ័យផល។* ***រូបភាព៖ សហការី***

### ការស្នើនិងទាមទារឱ្យដោះលែងលោក រ៉ុង ឈុន

ក្រុមប្រឹក្សាឃ្លាំមើលកម្ពុជា សមាគមសម្ពន្ធនិស្សិតបញ្ញវន្តខ្មែរ និងអង្គការសមាគមជាច្រើនបានស្នើឱ្យរដ្ឋាភិបាលនិងតុលាការកម្ពុជាដោះលែងលោក រ៉ុង ឈុន ជាបន្ទាន់ដោយគ្មានលក្ខខណ្ឌ។ លោក ម៉ែន ណាត ប្រធានក្រុមប្រឹក្សាឃ្លាំមើលកម្ពុជាដែលមានទីស្នាក់ការនៅក្រុងគ្រីស្ទានសាន់ ប្រទេសន័រវេស៍បានចេញសេចក្ដីថ្លែងការណ៍មួយនៅថ្ងៃទី១ ខែសីហា ឆ្នាំ២០២០ដោយស្នើសម្ដេចនាយករដ្ឋមន្ត្រី ហ៊ុន សែន ដោះលែងលោក រ៉ុង ឈុន ជាបន្ទាន់។

សមាគមសម្ពន្ធនិស្សិតបញ្ញវន្តខ្មែរ បានសម្ដែងនូវការខកចិត្តយ៉ាងខ្លាំងចំពោះអាជ្ញាធរនិងតុលាការកម្ពុជាដែលបានចាប់ឃុំខ្លួនលោក រ៉ុង ឈុន ហើយសមាគមនេះបានអំពាវនាវឱ្យទម្លាក់ការចោទប្រកាន់និងដោះលែងមេសហជីពរូបនេះជាបន្ទាន់។ សមាគមនេះថា ការចាប់ឃុំខ្លួននេះជាការរំលោភបំពានច្បាប់ជាតិ និងអន្តរជាតិយ៉ាងធ្ងន់ធ្ងរ។

> បងប្អូនដែលកំពុងធ្វើសកម្មភាពខុសច្បាប់ទាមទារដោះលែង រ៉ុង ឈុន សូមបញ្ឈប់សកម្មភាពជាបន្ទាន់ មុននឹងអាជ្ញាធរមានសមត្ថកិច្ចចាត់វិធានការតាមច្បាប់

ក្រុមសង្គមស៊ីវិលជាង១៤០បានសម្ដែងការសោកស្ដាយជាខ្លាំងចំពោះការចាប់ខ្លួនលោក រ៉ុង ឈុន និងបានឱ្យមានការទម្លាក់ចោលការចោទប្រកាន់ទាំងអស់ចំពោះរូបលោក។

ក្រុមសង្គមស៊ីវិលទាំងនេះបានបញ្ជាក់ថា៖ «ការចោទប្រកាន់ដែលធ្វើឱ្យលោក រ៉ុង ឈុន ប្រឈមនឹងការជាប់ពន្ធនាគាររហូតដល់២ឆ្នាំគឺជាការរំលោភសិទ្ធិនិងសេរីភាពរបស់លោកក្នុងការសម្ដែងមតិដែលត្រូវបានធានាដោយរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា»។

សង្គមស៊ីវិលបានថ្លែងថា៖ «យើងខ្ញុំសង្ឃឹមថា



*ក្រុមប្រឹក្សាឃ្លាំមើលកម្ពុជា សមាគមសម្ពន្ធនិស្សិតបញ្ញវន្តខ្មែរ និងអង្គការសមាគមជាច្រើនបានស្នើឱ្យរដ្ឋាភិបាលនិងតុលាការកម្ពុជាដោះលែងលោក រ៉ុង ឈុន។* ***សហការី***

រាជរដ្ឋាភិបាលនឹងអាចគោរពកាតព្វកិច្ចរបស់ខ្លួនដើម្បីធានាសិទ្ធិក្នុងការបញ្ចេញមតិ ផ្អែកតាមរដ្ឋធម្មនុញ្ញនិងច្បាប់អន្តរជាតិ។ យើងសង្ឃឹមថា សាលាដំបូងរាជធានីភ្នំពេញនឹងអាចទម្លាក់ចោលការចោទ ប្រកាន់ទាំងអស់និងដោះលែងលោក រ៉ុង ឈុន ឱ្យមានសេរីភាពវិញឱ្យបានឆាប់ផងដែរ»។

ក្រោយពីការចាប់និងឃុំខ្លួនលោក រ៉ុង ឈុន មានអ្នកគាំទ្រលោកបាននាំគ្នាមកប្រមូលផ្ដុំឈរលើកបដា ស្រែកតវ៉ាទាមទារឱ្យតុលាការដោះលែងលោក រ៉ុង ឈុន ឱ្យមានសេរីភាពវិញ។ ជាមួយគ្នានោះដែរក្រសួងយុត្តិធម៌បានប្រកាសឱ្យអ្នកដែលកំពុងធ្វើសកម្មភាពទាមទាឱ្យមានការដោះលែងលោក រ៉ុង ឈុន បញ្ឈប់សកម្មភាពជាបន្ទាន់ មុននឹងអាជ្ញាធរមានសមត្ថកិច្ចចាត់វិធានការតាមច្បាប់។

លោក គឹម សន្តិភាព អ្នកនាំពាក្យនៃក្រសួងយុត្តិធម៌បានឱ្យដឹងថា៖ «បងប្អូនដែលកំពុងធ្វើសកម្មភាពខុសច្បាប់ទាមទារដោះលែង រ៉ុង ឈុន សូមបញ្ឈប់សកម្មភាពជាបន្ទាន់ មុននឹងអាជ្ញាធរមានសមត្ថកិច្ចចាត់វិធានការតាមច្បាប់»។

អ្នកនាំពាក្យក្រសួងយុត្តិធម៌បានបញ្ជាក់បន្ថែមថា សកម្មភាពក្នុងការប្រមូលផ្ដុំមនុស្សនៅខាងមុខសាលាដំបូងរាជធានីភ្នំពេញ ដែលទាមទារឱ្យស្ថាប័នតុលាការដោះលែងជនត្រូវចោទឈ្មោះ រ៉ុង ឈុន ពុំមែនជាទង្វើត្រឹមត្រូវតាមច្បាប់នោះទេ ប៉ុន្តែគឺជាទង្វើដាក់សម្ពាធលើស្ថាប័នតុលាការដែលអាចប្រឈមមុខនឹងការចោទប្រកាន់អំពីបទល្មើសព្រហ្មទណ្ឌ តាមមាត្រា៥២២ នៃក្រមព្រហ្មទណ្ឌនៃប្រទេសកម្ពុជា។

គណៈកម្មាធិការចម្រុះកិច្ចការព្រំដែនបានចេញថ្លែងការណ៍មួយច្រានចោលការចោទប្រកាន់ថា ផែនទីខ្នាត ១/២៥ ០០០ ជាផែនទីដែលគូសវាងដោយប្រទេសវៀតណាម ដែលក្រុមឧទ្ទាមក្រៅច្បាប់ដែលបានចោទប្រកាន់ បំផ្លើស មួលបង្កាច់អំពីសមិទ្ធផលការងារដែលសម្រេចបានដោយគណៈកម្មាធិការចម្រុះកិច្ចការព្រំដែននៃរាជរដ្ឋាភិបាលកម្ពុជា។ គណៈកម្មាធិការចម្រុះកិច្ចការព្រំដែនបានបញ្ជាក់ថា ការចោទប្រកាន់គ្មានមូលដ្ឋាននេះជាការប្រឌិតរឿង និងផ្សព្វផ្សាយនូវព័ត៌មានមិនពិត ក្នុងចេតនាទុច្ចរិត និងក្នុងគោលបំណងបំភ័ន្តសាធារណមតិជាតិ និងអន្តរជាតិ ឱ្យមានការយល់ច្រឡំមកលើការងារព្រំដែនរបស់រាជរដ្ឋាភិបាលអំពីការធ្វើឱ្យបាត់បង់ទឹកដី ក៏ដូចជាការបណ្ដោយឱ្យមានការរំលោភបំពានទឹកដីពីប្រទេសវៀតណាម។ គណៈកម្មាធិការចម្រុះកិច្ចការព្រំដែន បានអំពាវនាវដល់ជនរួមជាតិទាំងក្នុង និងក្រៅប្រទេស សូមកុំជឿ និងកុំចែកចាយរាល់ការបង្ហោះសេចក្ដីថ្លែងការណ៍បោកប្រាស់ខុសពីការពិតរបស់ក្រុមឧទ្ទាមក្រៅច្បាប់ និងគូកន ដែលតែងតែបង្កើតព័ត៌មានក្លែងក្លាយក្នុងចេតនាទុច្ចរិត ដើម្បីវាយប្រហារដល់កិច្ចការព្រំដែនរបស់រាជរដ្ឋាភិបាល ហើយដែលសកម្មភាពទាំងអស់នោះអាចប្រឈមមុខនឹងផ្លូវច្បាប់៕



*ក្រុមអ្នកតវ៉ាឱ្យមានការដោះលែងលោក រ៉ុង ឈុន ក្រោមការឃ្លាំមើលពីសំណាក់សន្តិសុខ។* ***រូបភាព៖ ស៊ីអេសស៊ី***

# ផ្អាកការងារមន្ត្រីនគរបាលខេត្តព្រៃវែង៧នាក់ ករណីចាប់មនុស្សធ្វើទារុណកម្ម និងជំរិតទារប្រាក់

*អត្ថបទ៖ អមរិន្ទ ដានុត*

អគ្គស្នងការនគរបាលជាតិ នាយឧត្តមសេនីយ៍សន្តិបណ្ឌិត នេត សាវឿន បានសម្រេចផ្អាកការងារបណ្ដោះអាសន្នមន្ត្រីនគរបាលជាតិនៃស្នងការដ្ឋាននគរបាលខេត្តព្រៃវែងចំនួន៧រូបបន្ទាប់ពីមានបណ្ដឹងពីប្រជាពលរដ្ឋទាក់ទងនឹងការចាប់មនុស្សធ្វើទារុណកម្មព្រៃផ្សៃនិងជំរិតទារលុយ ១០០០ដុល្លាផងដែរ។

យោងតាមសេចក្ដីសម្រេចស្ដីពីការផ្អាកការងារបណ្ដោះអាសន្ន ដែលចុះហត្ថលេខាដោយនាយឧត្ដមសេនីយ៍សន្តិបណ្ឌិត នេត សាវឿន ចុះថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០២០នេះថា ត្រូវបានសម្រេចផ្អាកការងារបណ្ដោះអាសន្នចំពោះមន្ត្រីនគរបាលជាតិចំនួន៧រូប នៃស្នងការដ្ឋាននគរបាលខេត្តព្រៃវែងដែលមានលោក ថោង វណ្ណឌី ស្នងការរងទទួលផែនការងារប្រឆាំងគ្រឿងញៀន, លោក ពៅ ជីវ៉ន នាយការិយាល័យប្រឆាំងគ្រឿងញៀន, លោក ទូច ធារ៉ា នាយរងការិយាល័យប្រឆាំងគ្រឿងញៀន, លោក ស៊ី បូ នាយផ្នែកនៃការិយាល័យប្រឆាំងគ្រឿងញៀន, លោក ហេង ចាន់រតនា មន្ត្រីនៃការិយាល័យប្រឆាំងគ្រឿងញៀន, លោក សៀក ចាន់ធឿន មន្ត្រីនៃការិយាល័យប្រឆាំងគ្រឿងញៀន និងលោក យុន តារាភ័ស្ត មន្ត្រីនៃការិយាល័យប្រឆាំងគ្រឿងញៀន។

នាយឧត្តមសេនីយ៍ សន្តិបណ្ឌិត នេត សាវឿន បានបញ្ជាក់ទៀតថា សាមីខ្លួនដែលមានឈ្មោះទាំងអស់ត្រូវមកបង្ហាញខ្លួនរៀងរាល់ម៉ោងការងារនៅការិយាល័យបុគ្គលិកនៃស្នងការដ្ឋាននគរបាលខេត្តព្រៃវែង ដើម្បីរង់ចាំការសម្រេចជាថ្មី។

> តំណាងអយ្យការអមសាលាដំបូងខេត្ត សូមបដិសេធទាំងស្រុងលើការលើកឡើងដែលអះអាងថា ព្រះរាជអាជ្ញាទទួលប្រាក់ជាថ្នូរក្នុងការដោះលែងឱ្យមានសេរីភាពដែលបញ្ហានេះធ្វើឱ្យប៉ះពាល់ដល់កិត្តិយសនិងសេចក្ដីថ្លៃថ្នូរបស់ស្ថាប័នអមសាលាដំបូងទាំងមូលដែលមិនអាចទទួលយកបាន

គួរបញ្ជាក់ផងដែរថា ការផ្អាកពីការងារបណ្ដោះអាសន្ននេះធ្វើឡើងបន្ទាប់ពីប្រជាពលរដ្ឋបានប្ដឹងនិងចោទប្រកាន់មន្ត្រីនគរបាលទាំងនោះបានចាប់ប្រជាពលរដ្ឋធ្វើទារុណកម្មយ៉ាងព្រៃផ្សៃ រួចជំរិតទារលុយបានសម្រេច១,០០០ដុល្លារអាមេរិក។ គឺក្រុមនេះបានបង្គាប់ឱ្យឪពុកម្ដាយជនរងគ្រោះ យកលុយ៤,០០០,០០០,រៀលមកឱ្យប៉ូលីសជាថ្នូរនឹងការដោះលែងឱ្យជនរងគ្រោះទៅផ្ទះវិញ។

ជនរងគ្រោះក្នុងអំពើហិង្សានេះមានគ្នា២នាក់ដែលមានលោក ថៃ សាមាឌ អាយុ២៦ឆ្នាំ និងលោក ហឿន រ័ត្ន អាយុ២៨ឆ្នាំ ដែលអ្នកទាំង២មានទីលំនៅភូមិស្វាយសុខោ សង្កាត់ជើងទឹក ក្រុងព្រៃវែង ខេត្តព្រៃវែង។

ជនរងគ្រោះទាំងពីរបានរបួសហើមក្បាល ជាំភ្នែក ខៀវ ហើមខ្លួននិងដៃជើង រងរបួសធ្ងន់។ ករណីនេះបានកើតឡើង កាលពីវេលាម៉ោង១០យប់ថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០២០ នៅចំណុចមុខវត្តរោងដំរី ភូមិប្រាំមួយ សង្កាត់កំពង់លាវ ក្រុងព្រៃវែង ខេត្តព្រៃវែង។

បន្ទាប់ពីមានការផ្អាកការងារបណ្ដោះអាសន្នរបស់មន្ត្រីនគរបាលខេត្តព្រៃវែងចំនួន៧នាក់រួច អយ្យការអមសាលាដំបូងខេត្តបានចេញលិខិតបដិសេដការចោទប្រកាន់របស់ប៉ូលីសថាប្រគល់ប្រាក់ទៅឱ្យព្រះរាជអាជ្ញាខេត្តព្រៃវែងជាថ្នូរនឹងការដោះលែង។

អ្នកនាំពាក្យអយ្យការអមសាលាដំបូងខេត្តព្រៃវែងបានចេញសេចក្ដីប្រកាសព័ត៌មានមួយថា ចំពោះករណីបង្ក្រាបគ្រឿងញៀននៅចំណុចមុខក្លោងទ្វារវត្តដំរី ស្ថិតនៅភូមិ៦ សង្កាត់កំពង់លាវ ក្រុងព្រៃវែង ខេត្តព្រៃវែងនោះ តំណាងអយ្យការអមសាលាដំបូងខេត្តមិនបានទទួលព័ត៌មានឬរបាយការណ៍ណាមួយពីលោក ថោង វណ្ណឌី ស្នងការរងទទួលបន្ទុកផែនការងារប្រឆាំងបទល្មើសគ្រឿងញៀនទេ។

អ្នកនាំពាក្យដដែលនេះបានបញ្ជាក់ថា៖ «លោក ទូច ធារ៉ា នាយរងការិយាល័យប្រឆាំងគ្រឿងញៀន ដែលបានប្រាប់បណ្ដាញព័ត៌មានថា លុយចំនួន៤លានរៀលបានប្រគល់ទៅឱ្យលោកព្រះរាជអាជ្ញាខេត្តព្រៃវែងជាថ្នូរនឹងការដោះលែងជនសង្ស័យមានសេរីភាពវិញនោះ ជាការមិនពិតទេ តំណាងអយ្យការអមសាលាដំបូងខេត្តមិនបានទទួលប្រាក់ដូចដែលឈ្មោះទូច ធារ៉ាបានលើកឡើងនោះឡើយ»។

សាលាដំបូងខេត្តព្រៃវែងបានលើកឡើងបន្ថែមថា ករណីនេះ សាលាដំបូងខេត្តមិនបានបញ្ជាឱ្យធ្វើទារុណកម្មឬទារប្រាក់ពីជនសង្ស័យនោះឡើយ ហើយសមត្ថកិច្ចក៏មិនបានកសាងសំណុំរឿងទាំងនោះបញ្ជូនមកស្ថាប័នអយ្យការអមសាលាដំបូងខេត្តនោះដែរ។ តំណាងអយ្យការអមសាលាដំបូងខេត្ត សូមបដិសេធទាំងស្រុងលើការលើកឡើងដែលអះអាងថា ព្រះរាជអាជ្ញាទទួលប្រាក់ជាថ្នូរក្នុងការដោះលែងឱ្យមានសេរីភាព ដែលបញ្ហានេះធ្វើឱ្យប៉ះពាល់ដល់កិត្តិយសនិងសេចក្ដីថ្លៃថ្នូរបស់ស្ថាប័នអមសាលាដំបូងទាំងមូលដែលមិនអាចទទួលយកបាន។

ករណីនេះដែរ ជនរងគ្រោះទាំង២នាក់នោះបានសម្រេចមកដាក់ពាក្យបណ្ដឹងនៅអយ្យការអមសាលាដំបូងខេត្តព្រៃវែងជាផ្លូវការហើយដោយបានស្នើតុលាការចាត់ការតាមច្បាប់និងទាមទារសំណងជំងឺចិត្តក្នុងម្នាក់ៗ១០០លានរៀល ២នាក់ស្មើ (២០០លានរៀល) គិតជាដុល្លារស្មើ ៥០,០០០ដុល្លារ៕



ជនរងគ្រោះទាំង២នាក់ ឈ្មោះ ថៃ សាមាឌ និង ហឿន រ័ត្ន ដែលអ្នកទាំង២មានទីលំនៅភូមិស្វាយសុខោ សង្កាត់ជើងទឹក ក្រុងព្រៃវែង ខេត្តព្រៃវែង។ *រូបថត៖ សហការី*



*លិខិតប្រកាសផ្អាកការងារបណ្ដោះអាសន្នមន្ត្រីនគរបាលខេត្តព្រៃវែងទាំង៧នាក់។ សហការី*




*ជនរងគ្រោះរបួសហើមក្បាល ជាំភ្នែក ខៀវ ហើមខ្លួននិងដៃជើង រងរបួសធ្ងន់។ សហការី*




*មន្ត្រីនគរបាលជាតិចំនួន៧រូប នៃស្នងការដ្ឋាននគរបាលខេត្តព្រៃវែង ដែលត្រូវបានផ្អាកការងារនិងស្ថិតក្រោមការស៊ើបអង្កេត។ សហការី*





# យុវជននៅអាស៊ីអាគ្នេយ៍កំពុងរៀនគ្រប់គ្រងហិរញ្ញវត្ថុនៅក្នុងដំណាក់កាលកូវីដ១៩

*អត្ថបទ៖ អរិយបុត្រ*

បណ្ដាយុវជននៅក្នុងប្រជាជាតិអាស៊ីអាគ្នេយ៍កំពុងតែសិក្សាអំពីការគ្រប់គ្រងហិរញ្ញវត្ថុផ្ទាល់ខ្លួនរបស់ពួកគេនិងវិធីដើម្បីបង្កើនប្រាក់ចំណូលនៅក្នុងគោលបំណងបន្សាំខ្លួនប្រឆាំងនឹងការរីករាលប្រឆាំងនឹងមេរោគកូវីដ១៩ នេះបើតាមសេចក្ដីរាយការណ៍មួយដែលបានប្រកាសផ្សព្វផ្សាយដោយអង្គការវេទិការសេដ្ឋកិច្ចពិភពលោក។

របាយការណ៍សិក្សាមួយដែលមានចំណងជើងថា «ការសាកល្បងនៃការពិតចំពោះការបន្សាំនិងលទ្ធភាពបន្សាំរបស់យុវជនអាស៊ាន: ផលប៉ះពាល់នៃគន្លាតសង្គមចំពោះយុវជនអាស៊ាន» បានបង្ហាញថា ៥៨ ភាគរយនៃពលរដ្ឋនៅអាស៊ានដែលមានអាយុពី១៦ទៅ៣៥ឆ្នាំ គឺបានសិក្សាអំពីវិធីសាស្ត្រនៅក្នុងការគ្រប់គ្រងថវិការបានយ៉ាងប្រសើរ ហើយនៅពេលជាមួយគ្នានោះ គឺមាន៥៦ ភាគបានសិក្សាអំពីតម្លៃនៃការសន្សំគ្រាអាសន្ន និង ៣១ភាគរយសិក្សាអំពីវិធីនៅក្នុងការបង្កើនប្រាក់ចំណូលរបស់ពួកគេ។

លោក សានទីតាន សាធីរ៉ាថៃ (Santitarn Sathirathai) ប្រធានក្រុមអ្នកសេដ្ឋកិច្ចអាស៊ីអាគ្នេយ៍ ដែលមានមូលដ្ឋាននៅសិង្ហបុរី បាននិយាយថា នេះគឺជាពេលរិះគិតមួយ ហើយមនុស្សគឺត្រូវការរៀបចំប្រឈមនឹងភាពមិនច្បាស់លាស់ដូច្នេះពួកគេបានសិក្សាច្រើនផ្ដោតអំពីការសន្សំនិងការគ្រប់គ្រងសាច់ប្រាក់ព្រមទាំងវិធីដើម្បីសន្សំសម្រាប់ពេលទៅមុខ។

លោកបានអះអាងថា នៅក្នុងចំណោមអ្នកដែលបានឆ្លើយតបទាំងអស់គឺថា យុវជនអាស៊ានរហូតដល់ទៅ៣១ភាគរយ គឺបានរកឃើញនូវគំរូនៃអាជីវកម្មថ្មីនិងវិធីថ្មីៗដើម្បីកែលំអរប្រាក់ចំណូលរបស់ពួកគេ។ លោកបានអះអាងថា ស្ថានភាពបែបនេះ គឺជារឿងពិតជាពិសេសគឺសម្រាប់សហគ្រិនអាស៊ានដែលមានអាយុពី២៦ទៅ៣៥ឆ្នាំ។

តាមរបាយការណ៍ដដែលបានឱ្យដឹងថា យុវជនអាស៊ានប្រែក្លាយទៅជាបណ្ដុំនៃអ្នកវិនិយោគិនដ៏លឿន ហើយអ្នកដែលបណ្ដាក់ទុនមានអាយុចាប់ពី១៨ទៅ២៥ឆ្នាំ។ យុវជនជាច្រើនបានរិះគិតអំពីការធ្វើអាជីវកម្ម ជាពិសេសគឺចន្លោះពីឆ្នាំ២០១៦ដល់ខែឧសភា ឆ្នាំ២០២០។

ប្រភពដដែលបានរាយការណ៍ថា ការអង្កេតដែលគេបានធ្វើកាលពីខែ មិថុនាកន្លងទៅបានរកឃើញថា ៦៤ ភាគរយនៃយុវជនគឺជានិស្សិតពេញម៉ោង ហើយ៣៨ ភាគរយទៀត ជាអ្នកបម្រើការដ៏សកម្ម ហើយពួកគេកំពុងតែសិក្សានិងអនុវត្តការសិក្សាតាមរយៈអនឡាញយ៉ាងសកម្មនៅក្នុងអំឡុងពេលនៃការរីករាលដាលនៃមេរោគកូវីដ១៩។

លោក សានទីតាន សាធីរ៉ាថៃ បានអះអាងថា៖ «សម្រាប់និស្សិត ខ្ញុំគិតថា ពួកគេកំពុងតែសិក្សាតាមអនឡាញ ប៉ុន្តែប្អូនៗដែលជាអ្នកបម្រើការងារគឺពួកគេគឺកំពុងតែរីករាយនឹងផ្ដោតលើការសិក្សាជំនាញថ្មីៗ»។ នេះវាបង្ហាញអំពីការកើនឡើងនូវការគិតនៅក្នុងចំណោមយុវជនអាស៊ាន។ ប៉ុន្តែទោះបីជាយ៉ាងណាក៏ដោយ លោកបានអះអាងថា ៦៩ ភាគរយនៃអ្នកដែលបានចូលរួមសិក្សា គឺថា ពួកគេមានការលំបាកនៅក្នុងការធ្វើការនិងសិក្សាពីផ្ទះ ហើយនៅក្នុងនោះមាន ៧ ភាគរយដែលបានឆ្លើយថា មិនអាចតែម្ដង។ ការអង្កេតបានកត់សំគាល់ថា ហេតុផលសំខាន់ គឺដោយសារតែគុណភាពនៃសេវាអ៊ិនធើណែត តម្លៃនៃការប្រើប្រាស់អ៊ិនធើណិតខ្ពស់ ហើយនិងបរិយាកាសសម្រាប់ការសិក្សារបស់ពួកគេនៅផ្ទះគឺពិបាក។

ប្រភពដដែលបានបន្តថា យុវជនដែលកំពុងតែរស់នៅឆ្ងាយពីទីក្រុង ហើយនឹងអ្នកដែលកំពុងតែសិក្សានៅក្រោមកម្រិតវិទ្យាល័យ គឺពិតជាប្រឈមមុខនឹងការលំបាកនឹងការបម្រើការនៅកន្លែងឆ្ងាយ ឬ សិក្សាដាច់ពីគេនៅក្នុងអំឡុងពេលនៃការរីករាលដាលមេរោគ។

បញ្ហាទាំងនេះត្រូវបានរកឃើញនៅប្រទេសជាច្រើននៅអាស៊ាន រួមទាំងឥណ្ឌូនេស៊ី ហ្វីលីពិន វៀតណាម ជាដើម នៅក្នុងចំណោមអ្នកដែលពិបាកទាំងនេះ គឺនៅក្នុងចំណោមអ្នកដែលសិក្សាពឹងផ្អែកនៅលើកម្ចីពីធនាគារ ជាដើម។

លោក សានទីតាន សាធីរ៉ាថៃ បានអះអាងថា នេះគឺជាឱកាសសម្រាប់ដៃគូឯកជន-សាធារណៈដោះស្រាយនូវគម្លាតនៃមូលនិធិ។ យុវជនត្រូវការមូលនិធិដើម្បីបងថ្លៃសម្រាប់សិក្សា និង ឧបត្ថម្ភគ្រួសារនិងសហគ្រិនភាព និង ដើម្បីពង្រឹងអាជីវកម្មរបស់ពួកគេ។

ដូចគ្នានេះដែរ លោក ឃុង ពក (Khung Paok) អគ្គលេខាធិការរងនៃសហគមន៍វប្បធម៌សង្គម - អាស៊ានបានមានប្រសាសន៍ថា រដ្ឋជាសមាជិកចាំបាច់ត្រូវដាក់ចេញនូវកម្មវិធីគាំទ្រឬកម្មវិធីជំរុញរបស់រដ្ឋាភិបាលជាពិសេសសម្រាប់សហគ្រាសធុនតូចនិងមធ្យម។

លោកក៏បានស្នើឱ្យមានការរៀនសូត្រនៅតាមសហគមន៍ដើម្បីដោះស្រាយភាពមិនស្មើគ្នានៃការអប់រំក្នុងពេលមានជំងឺរាតត្បាតជាពិសេសនៅក្នុងតំបន់ដែលប្រជាជនមិនមានលទ្ធភាពប្រើប្រាស់អ៊ីនធឺណិត។

រដ្ឋមន្ត្រីស្រាវជ្រាវនិងបច្ចេកវិទ្យាឥណ្ឌូនេស៊ី លោក បាំបាង ប្រូដចូណេហ្គូ( Bambang Brodjonegoro) បាននិយាយថាប្រទេសឥណ្ឌូណេស៊ីនៅតែត្រូវការបញ្ចប់ហេដ្ឋារចនាសម្ព័ន្ធតភ្ជាប់អ៊ីនធឺណែតដើម្បីផ្ដល់នូវការតភ្ជាប់អ៊ីនធឺណិតមានស្ថេរភាពនិងមានគុណភាពនៅទូទាំងប្រជុំកោះ។

លោកបានមានប្រសាសន៍ថា៖ «ទោះជាយ៉ាងនេះក្ដី កិច្ចការនេះត្រូវការការវិនិយោគធំនិងពេលវេលាត្រូវបញ្ចប់»។ ដំណោះស្រាយរយៈពេលខ្លីមួយដើម្បីផ្ដល់ការតភ្ជាប់កាន់តែប្រសើរគឺការប្រើផ្កាយរណបទូរគមនាគមន៍ដែលមានស្រាប់ ប៉ុន្តែរដ្ឋាភិបាលចាំបាច់ត្រូវបង្កើនចំនួនខ្សែប្រេ្វកង់ដើម្បីធ្វើដូច្នេះ»។

ការសិក្សាពីផ្ទះបានក្លាយជាបន្ទុកដែលកំពុងកើនឡើងសម្រាប់សិស្សគ្រូនិងឪពុកម្ដាយជាពិសេសនៅតាមទីដាច់ស្រយាលក្នុងប្រទេសដែលគំរាមកំហែងធ្វើឱ្យវិសមភាពអប់រំកាន់តែរាលដាលនៅក្នុងតំបន់៕




*លោក សានទីតាន សាធីរ៉ាថៃ (Santitarn Sathirathai) ប្រធានក្រុមអ្នកសេដ្ឋកិច្ចអាស៊ីអាគ្នេយ៍ ដែលមានមូលដ្ឋាននៅសិង្ហបុរី។ រូបថត៖ បរទេស*



# ក្រសួងទេសចរណ៍អះអាង ថាវិស័យទេសចរណ៍កម្ពុជាត្រូវការ ពេលវេលាបីឆ្នាំដើម្បីស្តារឡើងវិញ

*អត្ថបទ៖ អរិយបុត្រ*

ក្រសួងទេសចរណ៍បានអះអាងថា វិបត្តិនៃជំងឺកូវីដ១៩ បានជះឥទ្ធិពលយ៉ាងខ្លាំងមកលើសេដ្ឋកិច្ចពិភពលោកនិងកម្ពុជា ជាពិសេសគឺវិស័យទេសចរណ៍។

យោងតាមការព្យាករណ៍មួយដែលបានផ្សព្វផ្សាយដោយក្រសួងកាលពីដើមខែសីហា ឆ្នាំ២០២០ បានឱ្យដឹងថា វិស័យទេសចរណ៍កម្ពុជាត្រូវចំណាយពេលវេលាពី០៣ទៅ០៥ ឆ្នាំ ទើបអាចស្តារមកស្ថានការណ៍ដូចដើមវិញ ប៉ុន្តែបើស្ថានការណ៍អូសបន្លាយ នោះអាចត្រូវចំណាយពេលវេលារហូតដល់០៧ឆ្នាំ។

ប្រភពដដែលបានបន្តថា ដើម្បីជំរុញនិងបង្កើនល្បឿននៅក្នុងការស្តារវិស័យឧស្សាហកម្មគ្មានផ្សែងនេះ ក្រសួងកំពុងតែជំរុញនិងលើកទឹកចិត្តទេសចរណ៍នៅក្នុងស្រុកឱ្យធ្វើដំណើរកំសាន្ត ដើម្បីគាំទ្រដល់ចរន្តសេដ្ឋកិច្ចទេសចរណ៍ បង្កើនការអប់រំប្រជាពលរដ្ឋឱ្យអនុវត្តន៍នូវការប្រកាន់ខ្ជាប់ "ទម្លាប់ថ្មី"។

នៅក្នុងបរិការណ៍នៃការរីករាលដាលនៃជំងឺកូវីដ១៩បានធ្វើឱ្យក្រសួងទេសចរណ៍កំណត់ការព្យាករណ៍អំពីស្ថានភាពវិស័យនេះ៣សេណារីយ៉ូ។

ប្រភពពីក្រសួងទេសចរណ៍បានឱ្យដឹងថា សេណារីយ៉ូទី១ ក្រសួងបានព្យាករណ៍ថា ភ្ញៀវទេសចរអាចថយចុះពី៥០%ទៅ៦០% ដោយកម្ពុជានឹងទទួលបានទេសចរអន្តរជាតិប្រមាណតែ២,៥ លាននាក់ប៉ុណ្ណោះ។

ប្រភពដដែលបានបន្តទៀតថា សេណារីយ៉ូទី២ ភ្ញៀវទេសចរថយចុះពី ៦០% ទៅ ៧០% ដូច្នេះនេះបានន័យថា កម្ពុជាទទួលភ្ញៀវទេសចរអន្តរជាតិប្រមាណត្រឹមតែ២លាននាក់ប៉ុណ្ណោះ។ ហើយដោយឡែក ចំពោះសេណារីយ៉ូ ទី៣ ភ្ញៀវទេសចរនឹងថយចុះពី៧០% ទៅ៩០% ដូច្នេះ កម្ពុជានឹងទទួលបានទេសចរអន្តរជាតិត្រឹមតែប្រមាណ១,៥លាននាក់ប៉ុណ្ណោះ។

ប្រភពដដែលបានបន្តថា ស្ថិតក្នុងស្ថានភាពមិនច្បាស់លាស់នៃជំងឺនេះ កម្ពុជាប្រហែលជាស្ថិតក្នុងសេណារីយ៉ូទី៣ ដែលផលប៉ះពាល់នៃវិបត្តជំងឺកូវីដ១៩ មានដូចជា៖ (១) ខាតបង់ចំណូលទេសចរណ៍អន្តរជាតិប្រមាណ ៣ ពាន់លានដុល្លារ (២) អត្រាផលិតផលក្នុងស្រុកសរុប (GDP) អាចថយចុះពីជាង ១២% មកក្រោម១០% និង (៣) មូលដ្ឋានអាជីវកម្មទេសចរណ៍ ៣.១៣៥ ទីតាំងត្រូវបានបិទនិងផ្អាកដំណើរការ (គិតត្រឹមខែកក្កដា ឆ្នាំ ២០២០) រួមមានសណ្ឋាគារ ផ្ទះសំណាក់ ភោជនីយដ្ឋាន ទីភ្នាក់ងារទេសចរណ៍ កីឡាទេសចរណ៍ និងអាជីវកម្មខារ៉ាអូខេ វង្គសាល បៀហ្គាឌិន ហើយបុគ្គលិកបម្រើការប្រមាណជាង១១ម៉ឺននាក់ ប្រហែលពី១៥% ទៅ២០% នៃកម្លាំងពលកម្មបម្រើការក្នុងវិស័យទេសចរណ៍ ត្រូវបានបញ្ឈប់ការងារ។

ប្រភពដដែលបានបន្តថា ក្នុងនោះ បុគ្គលិកបម្រើការ ដែលរងផលប៉ះពាល់ធ្ងន់ធ្ងរជាងគេ ដូចជា ម៉ាស្សានិងអ្នកដែលនៅក្នុងផ្នែកសេវាកម្មកំសាន្តមនុស្សពេញវ័យ ហើយដោយឡែក មគ្គុទេសទេសចរណ៍ប្រមាណជាជាង៣ភាគរយ ត្រូវបានព្យួរអាជ្ញាបណ្ណ។

ប្រភពដដែលបានបន្តថា សម្រាប់ឆ្នាំ២០២១ ទេសចរណ៍កម្ពុជាត្រូវបានព្យាករណ៍ថា នឹងមានកំណើនឡើងវិញក្នុងចន្លោះពី២៥ទៅ៣៥ភាគរយ តែស្ថិតនៅក្នុងបរិមាណតិចនៅឡើយ ក្នុងនោះចំណូលទេសចរណ៍អន្តរជាតិនឹងទទួលបានប្រមាណជា២ពាន់លានដុល្លារ រួមចំណែកក្នុងផលិតផលក្នុងស្រុកសរុបប្រមាណជា ១០ភាគរយនិងមុខរបរក៏ដូចជាការងារក្នុងវិស័យទេសចរណ៍ប្រមាណជា៥០ម៉ឺននាក់។



*ភ្ញៀវទេសចរសម្រុកទៅទស្សនាខេត្តសៀមរាប ក្នុងពេលនៃការឈប់សម្រាកសងថ្ងៃចូលឆ្នាំខែកាលពីខែមេសា។ **រូបភាព៖ រដ្ឋបាលខេត្តសៀមរាប***

ប្រភពដដែលបានបន្តទៀតថា សម្រាប់ឆ្នាំ ២០២២ វិស័យទេសចរណ៍កម្ពុជាត្រូវបានព្យាករណ៍ថា នឹងរក្សានូវកំណើនក្នុងចន្លោះពី២០ទៅ៣០ភាគរយ ដោយឡែកសម្រាប់ឆ្នាំ២០២៣ ដែលជាឆ្នាំកម្ពុជាត្រូវធ្វើជាម្ចាស់ផ្ទះនៃកីឡាស៊ីហ្គេមនោះ ភ្ញៀវទេសចរអន្តរជាតិត្រូវបានព្យាករណ៍ថា នឹងមានកំណើនល្អចន្លោះពី៣០ទៅ៣៥ ភាគរយ ប៉ុន្តែទោះបីជាយ៉ាងណាក៏ដោយ ក៏បរិមាណនៃកំណើន គឺនៅតិចនៅឡើយ គឺចន្លោះពី ២,៥ទៅ ៣,៥ លាននាក់៕

# មាត់ច្រកនៃការនាំចេញនាំចូលកម្ពុជានៅតែរក្សា បាននិរន្តរភាពទោះកូវីដ១៩កំពុងតែរាតត្បាត

*អត្ថបទ៖ អរិយបុត្រ*

ទោះពិភពលោកកំពុងតែប្រឈមមុខនឹងការរាតត្បាតនៃមេរោគកូវីដ១៩ ហើយសេដ្ឋកិច្ចនិងពាណិជ្ជកម្មពិភពលោកកំពុងតែស្ថិតនៅក្នុងដំណាក់កាលនៃការធ្លាក់ចុះដែលមិនដែលបានជួបប្រទះពីមុនមកនោះក៏ដោយ កំពង់ផែស្វយ័តក្រុងព្រះសីហនុដែលជាមាត់ច្រកនៃការនាំចេញនាំចូលកម្ពុជា នៅតែបន្តរក្សាបាននូវនិរន្តភាព។ នេះបើតាមការលើកឡើង ដោយ លោក ថៃ ឫទ្ធី អគ្គនាយករងអាជីវកម្មនៃកំពង់ផែស្វយ័តក្រុងព្រះសីហនុ។

លោកបានថ្លែងបន្តថា នៅក្នុងអំឡុងខែមករានិងខែកុម្ភៈ កំពង់ផែនៅដំណើរការល្អ ដោយកំពង់ផែទទួលបានកំណើនជាង ២០ភាគរយ លើទំនិញឆ្លងកាត់។

លោកបានបញ្ជាក់ថា៖ «យើងឃើញថា សកម្មភាពអាជីវកម្មនៅកំពង់ផែ គឺទទួលបានដំណើរការល្អ ប៉ុន្តែក្រោយមកគឺចាប់ពីខែមីនា ទៅដល់ខែមេសា មកសកម្មភាពនាំចូលមានការធ្លាក់ចុះច្រើន»។

លោកបានបន្តថា ការធ្លាក់ចុះនេះដោយសារតែការដឹកជញ្ជូនវត្ថុធាតុដើមពីស្រុកចិន គឺមានការថមថយ ប៉ុន្តែការនាំចេញគឺ មិនទាន់ជួបប្រទះបញ្ហាទេ ដោយសារតែគោលដៅនៃការនាំចេញកម្ពុជា គឺសហគមន៍អឺរ៉ុប និង សហរដ្ឋអាមេរិក ប៉ុន្តែនៅខែមេសា និង ខែឧសភា ក៏ស្រាប់តែ សហគមន៍អឺរ៉ុប ក៏ដូចជាសហរដ្ឋអាមេរិកគាត់ប៉ះវិញម្តង រីឯការនាំចូលពីចិនមកក៏ឡើងបន្តិចវិញ ដូច្នេះសកម្មភាពកំពង់ផែគឺនៅតែមាននិរន្តរភាពឡើងវិញ។

លោកបានបន្តថា ជារួមនៅក្នុងរយៈពេល៥ខែ មកនេះសម្រាប់សកម្មភាពកំពង់ផែ គឺនៅតែទទួលបាននិរន្តរភាព។

លោក ថៃ ឫទ្ធី បានមានប្រសាសន៍បន្ថែមថា បរិមាណនៃទំនិញដែលបានឆ្លងកាត់កំពង់ផែ បើគិតជាតោន គឺយើងនៅទទួលកំណើន ៣,៤១ ភាគរយ នៅក្នុងរយៈពេល៥ខែ ដើមឆ្នាំនេះ។ ដោយឡែកកុងតឺណ័ វិញ គឺយើងនៅទទួលបានកំណើន ៤,៨២ TEU ប៉ុន្តែសម្រាប់នាវា ដែលចេញចូល គឺនាវាមានការធ្លាក់ចុះ ២,៧១ ភាគរយ។

លោកបានបញ្ជាក់ជាថ្មីទៀតថា៖ «នៅឆ្នាំ២០២០ យើងរំពឹងថា យើងអាចមិនទទួលបានកំណើនទេ ហើយអាចនឹងចុះបន្តិចបន្តួច ប៉ុន្តែយើងអាចរក្សាបាននូវសកម្មភាពអាជីវកម្ម ហើយក៏មិនមានការកាត់បន្ថយបុគ្គលិក ឡើយ»។

លោកបានបន្តទៀតថា សម្រាប់ឆ្នាំ ២០២០ និង ២០២១ ខាងមុខបើកុំតែកូវីដ១៩ យើងអត់មានការបារម្ភរឿង EBA អ្វីឡើយ ពីព្រោះថា សកម្មភាពនៅកំពង់ផែ គឺសំខាន់ដៃគូ ជាពិសេសគឺក្រុមហ៊ុនកប៉ាល់គេទុកចិត្តសេវារបស់យើង ដូច្នេះ បើសេវារបស់យើងគេទទួលយកបាន ហើយក្រុមហ៊ុនកប៉ាល់នៅតែស្មោះស្ម័គ្រនឹងយើង។

កំពង់ផែស្វយ័តក្រុងព្រះសីហនុគឺជាមាត់ច្រកដ៏សំខាន់សម្រាប់ប្រទេសពោលគឺជាកំពង់ផែទឹកជ្រៅតែមួយគត់ដែលភ្ជាប់ក្រុងព្រះសីហនុទៅបណ្តាខេត្តនិងរាជធានីតាមរយៈផ្លូវជាតិលេខ ៤ លេខ៣ និង ផ្លូវរថភ្លើង។ បច្ចុប្បន្ននេះបរិមាណទំនិញ ស្ទើរតែជាង ៧០ ភាគរយបាននាំចេញពីកម្ពុជា និងនាំចូលកម្ពុជាគឺឆ្លងកាត់កំពង់ផែនេះ ក្រៅពីនោះគឺឆ្លងកាត់តាមកំពង់ផែស្វយ័តភ្នំពេញ និង តាមច្រកព្រំដែន។ ដើម្បីបន្តថែរក្សានិរន្តរភាព កំពងផែក៏កំពុងបន្តអភិវឌ្ឍន៍កំពង់ផែផងដែរ។

លោក ថៃ ឫទ្ធី បានមានប្រសាសន៍ថា ថ្នាក់ដឹកនាំផ្ទាល់របស់កំពង់ផែ និងអ្នកបច្ចេកទេស គឺកំពុងតែសិក្សាធ្វើយ៉ាងម៉េច ដើម្បីឱ្យជំហានទី២ និង ជំហានទី៣ នៃការអភិវឌ្ឍកំពង់ផែទឹកជ្រៅនៃខេត្តព្រះសីហនុនេះ អាចឱ្យនាវាផុនយក្សចេញចូលបាន នៅក្នុងរង្វង់ពីឆ្នាំ២០២៧ ទៅ ២០២៨។

លោកបានបញ្ជាក់ថា កំពង់ផែបានធ្វើសំណើរទៅក្រសួងអាណាព្យាបាលរួចរាល់ហើយ ជាការឆ្លើយតបដៃគូអភិវឌ្ឍជាពិសេស គឺជប៉ុនគឺបានធានាថា នឹងជួយកម្ពុជានៅក្នុងការអភិវឌ្ឍកំពង់ផែជំហានទី២ និងទី៣ នេះ។

លោកបានបន្ថែមថា «គេនឹងបញ្ជូនអ្នកជំនាញការ ក្រោយពេលដែលកូវីដ១៩ ធូរស្រាល ទាក់ទងនឹងផែនការការអភិវឌ្ឍជំហានទី២ និងទី៣ ដោយជំហានទី២ យើងមានផែនការកសាងផែដែលមានប្រវែង ៤១០ ម ជម្រៅទឹក ១៦ ម ហើយជំហានទី៣ គឺ ៤៤០ ម ជម្រៅទឹក ១៧,៥០ ម។ ជំហានទី២ និងទី៣ តាមការចង់បាន តាមការព្យាករណ៍អំពីកំណើននៅទីនេះយើងដាច់ខាតត្រូវតែសង់នៅក្នុងពេលតែមួយ»។

កំពង់ផែស្វយ័តក្រុងព្រះសីហនុ គឺជាកំពង់ផែសមុទ្រទឹកជ្រៅដ៏សំខាន់នៃព្រះរាជាណាចក្រកម្ពុជា ដែលមានផ្ទៃដីប្រតិបត្តិការប្រមាណ១២៥ហិកតា។

កំពង់ផែនេះត្រូវបានសាងសង់ឡើងនៅដើមឆ្នាំ១៩៥៦ និងបានពង្រីកជាលំដាប់ ហើយឥឡូវនេះ កំពង់ផែមានចំណតនាវាចំនួន៨ចំណត ដែលបំពាក់ដោយឧបករណ៍លើកដាក់ទំនើបទាន់សម័យ ក្នុងរយៈពេល៥ឆ្នាំចុងក្រោយនេះបរិមាណទំនិញឆ្លងកាត់មានការកើនឡើងជាបន្តបន្ទាប់៕





# សម្បត្តិលោហៈមានតម្លៃរបស់ ជាតិកម្ពុជាមាន៣៦,៥តោន

*អត្ថបទ៖ អរិយបុត្រ*



*សម្តេចតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា។ **រូបភាព៖ ហ្វេសប៊ុកនាយករដ្ឋមន្ត្រី***

រតនៈសម្បត្តិជាមាសជាតិដែលរក្សាទុកបម្រុងដោយធនាគារជាតិកម្ពុជាទាំងនៅអន្តរជាតិនិងនៅក្នុងស្រុកនៅពេលនេះបានកើនឡើងរហូតដល់ទី៣៦,៥ តោន។ នេះបើតាមការប្រកាសឱ្យដឹង ជាសាធារណៈដោយប្រមុខរាជរដ្ឋាភិបាលកម្ពុជាតាមបណ្តាញសង្គម នៅថ្ងៃទី២៣ ខែ កក្កដា ឆ្នាំ២០២០។

នៅក្នុងឱកាសនោះសម្តេចតេជោ ហ៊ុន សែន បានថ្លែងថា មាសបម្រុងរបស់កម្ពុជាមិនបានទៅណា ឬមានការកេងបន្លំយកធ្វើជាសម្បត្តិឯកជនឬផ្ទាល់ខ្លួនដូចជាការលើកឡើងរបស់ជនអគតិមួយចំនួននោះឡើយ ហើយមិនតែប៉ុណ្ណោះ រតនៈវត្ថុដ៏មានតម្លៃជាសាកលនេះមិនត្រឹមតែនៅដដែល នោះទេ គឺមានការកើនឡើងជាបន្តបន្ទាប់ថែមទៀតថា។

សម្តេចតេជោ ហ៊ុន សែន បានថ្លែងបញ្ជាក់តាមសំណេរនៅលើបណ្តាញសង្គមថា «មានបងប្អូនយើងមួយចំនួនចង់ដឹងអំពីមាសដែលជាទុនបម្រុងរបស់ជាតិ។ ការចង់ដឹងរបស់បងប្អូនមួយចំនួនធំមានភាពសុចរិត ពីព្រោះវាជារបស់ជាតិតែនៅមានជនអាក្រក់មួយចំនួនតូចបាននិងកំពុងប្រើប្រាស់ការបាត់បង់ដំណឹងអំពីមាសដើម្បីវាយប្រហាររាជរដ្ឋាភិបាលថាចង់បន្លំយកមាសក្នុងពេលមានជំងឺឆ្លងកូវីដ១៩ ព្រោះមិនដែលឮលោក ហ៊ុន សែន និយាយពីមាសនេះទៀតទេ»។

សម្តេចតេជោ ហ៊ុន សែន បាន ថ្លែងទៀតថា ដើម្បីច្បាស់ពីមាសសូមមើលការពន្យល់របស់ធនាគារជាតិកម្ពុជានោះ បងប្អូនប្រាកដជាយល់និងអបអរសាទរជាមួយទុនបម្រុងរបស់ជាតិយើងដែលកើនឡើងជាលំដាប់។

សម្តេចតេជោ ហ៊ុន សែន បានថ្លែងថា៖ «ប្រហែលមួយឆ្នាំមុនខ្ញុំធ្លាប់ប្រកាសថាមាសរបស់យើងមាន៣០តោនតែតាមតួលេខថ្មីនេះមាសរបស់យើងមានដល់៣៦,៥តោន។ នេះមិនមែនជាមារយាទស្រីកញ្ជើធ្លុះក្នុងការគ្រប់គ្រងសេដ្ឋកិច្ចជាតិនោះទេ»។

បើយោងទៅតាមសេចក្តីបញ្ជាក់របស់ធនាគារជាតិ ដែលបានផ្សព្វផ្សាយកាលពីថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០២០ បានបញ្ជាក់ថា បច្ចុប្បន្ននេះទុនបម្រុងអន្តរជាតិរបស់កម្ពុជាគិតជាដុល្លារអាមេរិក គឺមានចំនួន ១៩,៥ ប៊ីលាន គិតត្រឹមចុងខែ មិថុនា ឆ្នាំដដែល។

ប្រភពដដែលបានបន្តទៀតថា ធនាគារជាតិនៃកម្ពុជា ត្រូវគ្រប់គ្រងដោយប្រុងប្រយ័ត្ន ដើម្បីរក្សាសុវត្ថិភាពទុនបម្រុងទាំងនេះ ដូច្នេះធនាគារជាតិនៃកម្ពុជាវិនិយោគលើឧបករណ៍ដែលមានស្ថិរភាពខ្ពស់ដូចជារូបិយប័ណ្ណខ្លាំង និងមាស។

ប្រភពដដែលបានបញ្ជាក់ថា ធនាគារជាតិនៃកម្ពុជាបានរក្សាមាសសរុបចំនួន ៣៦,៥ តោន ដូចជាការប្រកាសរបស់ប្រមុខរាជរដ្ឋាភិបាល នៅក្នុងនោះមាសដែលជាកេរ្តិ៍មរតកតាំងពីមុនសង្គ្រាមមានចំនួន ១២,៤ តោន ដែលកំពុងរក្សាទុកនៅប្រទេសស្វីស ហើយមានចំនួន ១៤,១ តោនទៀត បានកំពុងតែវិនិយោគនៅធនាគារកណ្តាលអង់គ្លេស និង មានមាសចំនួន ១០ តោនទៀតត្រូវបានរក្សាទុកនៅកម្ពុជា៕

> ប្រហែលមួយឆ្នាំមុនខ្ញុំធ្លាប់ប្រកាសថាមាសរបស់យើងមាន៣០តោនតែតាមតួលេខថ្មីនេះមាសរបស់យើងមានដល់៣៦,៥តោន។ នេះមិនមែនជាមារយាទស្រីកញ្ជើធ្លុះក្នុងការគ្រប់គ្រងសេដ្ឋកិច្ចជាតិនោះទេ



# របាយការណ៍៖ ការរំលោភសិទ្ធិមនុស្សនិងបំផ្លាញបរិស្ថាននៅពេលអភិវឌ្ឍរបស់ឯកជនគំរាមកំហែងធ្វើឱ្យមានការជន់លិចនៅក្នុងរាជធានីភ្នំពេញ

*អត្ថបទ៖ ផល សុផានិត*

អង្គការសម្ព័ន្ធខ្មែរជំរឿននិងការពារសិទ្ធិមនុស្សលីកាដូ (LICADHO) បណ្ដាញយុវជនកម្ពុជា (CYN) អង្គការសមធម៌កម្ពុជា(EC) និងអង្គការសមាគមធាងត្នោត(STT) បានបង្ហាញថា ប្រជាពលរដ្ឋជាងមួយលាននាក់នៅក្នុងរាជធានីភ្នំពេញកំពុងប្រឈមនឹងការកើនឡើងនូវទឹកជំនន់ និងមានមនុស្សជាងមួយពាន់គ្រួសារទៀតកំពុងប្រឈមនឹងការបណ្ដេញចេញ ការបាត់បង់ប្រាក់ចំណូល និងអសន្តិសុខស្បៀងខណៈដែលគម្រោងអភិវឌ្ឍន៍ អាយ អិន ជី ស៊ុធី(ING City) និង គម្រោងផ្សេងៗទៀតបាននិងកំពុងធ្វើឱ្យប៉ះពាល់តំបន់បឹងទំពុន ឬជើងឯកដែលស្ថិតនៅភាគខាងត្បូងរាជធានីភ្នំពេញ។



*ខ្សាច់មកពីទន្លេត្រូវបានប្រើប្រាស់ដើម្បីចាក់បំពេញតំបន់ជាច្រើននៅក្នុងតំបន់បឹងទំពុន ឬជើងឯកតាមបណ្ដោយមហាវិថីសម្ដេចហ៊ុន សែន (ផ្លូវ៦០ម៉ែត្រ)។ **រូបភាព៖ របាយការណ៍***

របាយការណ៍ស្រាវជ្រាវដែលមានចំណងជើងថា ការបាត់បង់បឹងទំពុន ការវាយតម្លៃហេតុ ប៉ះពាល់សង្គមនិងសិទ្ធិមនុស្សពីការបំផ្លិចបំផ្លាញតំបន់បឹងទំពុន ឬជើងឯក បានចេញផ្សាយនៅថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០២០ របស់សមាគមធាងត្នោត បានរកឃើញថា ប្រជាជនកម្ពុជារាប់លាននាក់ទំនងជានឹងរងផលប៉ះពាល់ពីការធ្វើឱ្យប៉ះពាល់ធ្ងន់ធ្ងរនៅតំបន់បឹងទំពុន ឬជើងឯកដោយក្រុមហ៊ុន អាយ អិន ជី ហូលឌីង និងសាជីវកម្មឯកជនផ្សេងៗទៀត រួមមានក្រុមហ៊ុនជីបម៉ុង អ៊ីអនម៉ល អ័រគីដេវីឡា និងបុរីប៉េងហួត។ល។

ក្រុមអង្គការសង្គមស៊ីវិលដែលធ្វើការលើវិស័យសិទ្ធិមនុស្សនិងបរិស្ថានបានស្ទង់មតិជាមួយនឹងប្រជាពលរដ្ឋចំនួន៤៦៩គ្រួសារ ដែលកំពុងរស់នៅឬប្រើប្រាស់តំបន់បឹងនេះនិងទន្លេ។

ជាលទ្ធផលរបាយការណ៍បង្ហាញពីផលប៉ះពាល់គួរឱ្យព្រួយបារម្ភក្នុង តំបន់បឹងទំពុនឬជើងឯកក្នុងផ្ទៃក្រឡាប្រមាណ ១.៥០០ ហិកតា ដែលកំពុងតែជួយទ្រទ្រង់ដល់ជីវភាពរស់នៅរបស់ប្រជាសហគមន៍មូលដ្ឋាន និងដើរតួនាទីយ៉ាងសំខាន់ក្នុងការគ្រប់គ្រងកាកសំណល់និងការពារទឹកជំនន់នៅក្នុងរាជធានីភ្នំពេញ។

សមាជិកសហគមន៍មកពីតំបន់បឹងទំពុនឬជើងឯក បាននិយាយកាលពីខែឧសភា ឆ្នាំ២០២០កន្លងទៅនេះថា៖ «ខ្ញុំគិតថា វានឹងប៉ះពាល់ដល់ប្រជាជនក្រីក្រដែលដាំបន្លែ និងនេសាទត្រីនៅក្នុងតំបន់បឹងនេះដោយសារតែយើងពឹងផ្អែកលើបឹងសម្រាប់ការរស់នៅប្រចាំថ្ងៃរបស់យើង»។

របាយការណ៍ខាងលើបានបង្ហាញថា បើគ្មានតំបន់បឹងទាំងនេះទេ ប្រជាជនជាងមួយលាននាក់នៅក្នុងរាជធានីភ្នំពេញនឹងប្រឈមការកើនឡើងនៃទឹកជំនន់។ សម្រាប់សហគមន៍នៅខ្សែទឹកខាងក្រោម បើការអភិវឌ្ឍរបស់ឯកជនដែលនៅតែបន្ត នោះនឹងបណ្ដាលឱ្យបាត់បង់នូវមុខរបរចិញ្ចឹមជីវិតនិងមនុស្សជាងមួយពាន់គ្រួសារត្រូវបានបង្ខំឱ្យចាកចេញពីលំនៅឋានរបស់ពួកគាត់។ ផ្ទៃនៃតំបន់បឹងទំពុន ឬបឹងជើងឯកដែលធ្លាប់ជាទ្រព្យសម្បត្តិសាធារណៈ ដោយសារ ស្របតាមលក្ខណៈវិនិច្ឆ័យដែលត្រូវចាត់ទុកថាជាទ្រព្យសម្បត្តិសាធារណៈ ឥឡូវត្រូវបានគេកាត់ និងបែងចែកទៅឱ្យក្រុមហ៊ុនអភិវឌ្ឍន៍នានា ដោយសារតែមានអនុក្រឹត្យរបស់រាជរដ្ឋាភិបាលនៅចន្លោះឆ្នាំ២០១៧ និងឆ្នាំ២០១៩។

ជាលទ្ធផល ផ្ទៃតំបន់បឹងទំពុនឬជើងឯកដែលពីមុនមានទំហំយ៉ាងហោចណាស់១.៥០០ ហិកតា ប៉ុន្តែឥឡូវនេះគ្រោងនឹងត្រូវកាត់មកនៅត្រឹមទំហំ១០៧ហិកតាតែប៉ុណ្ណោះ។ តំបន់បឹងទំពុនឬជើងឯកបម្រើផលប្រយោជន៍សាធារណៈសំខាន់ពីរគឺ កាត់បន្ថយទឹកជំនន់ក្នុងរាជធានីភ្នំពេញ ដោយបឹងនេះរក្សាទុកទឹកភ្លៀងដែលហូរចេញពីរាជធានី និងមួយផ្នែកទៀតដើរតួនាទីប្រព្រឹត្តកម្មទឹកកខ្វក់ដែលហូរចេញពីរាជធានីភ្នំពេញ មុនពេលហូរចូលទៅក្នុងទន្លេបាសាក់។

> « រាជរដ្ឋាភិបាលមានការទទួលខុសត្រូវក្នុងការធានាការពារប្រជាជនពីការរំលោភសិទ្ធិមនុស្ស។ របាយការណ៍នេះត្រូវបានរៀបចំឡើងដើម្បីបង្ហាញពីហានិភ័យនានាទាក់ទងនឹងសិទ្ធិមនុស្ស ដើម្បីឱ្យរាជរដ្ឋាភិបាលអាចចាត់វិធានការដែលសមស្របនានាដើម្បីដោះស្រាយបញ្ហាទាំងនោះ »

ទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិជប៉ុន (JICA) បានគ្រោងនឹងផ្ដល់នូវរោងចក្រប្រព្រឹត្តកម្មទឹកកខ្វក់ដែលមានតម្លៃខ្ពស់ ដែលអាចធ្វើប្រព្រឹត្តកម្មទឹកកខ្វក់បានតិចជាង២ភាគរយ នៃទឹកកខ្វក់ដែលកំពុងហូរចូលក្នុងតំបន់បឹងទំពុនឬជើងឯកជារៀងរាល់ថ្ងៃ។

ងាកមកផ្នែកសិទ្ធិមនុស្សវិញ សុទ្ធសឹងតែស្ថិតក្រោមការគំរាមកំហែងដោយសារគម្រោង អាយ អិន ជី ស៊ុធី ING City និងការអភិវឌ្ឍផ្សេងៗនៅលើតំបន់បឹងទំពុនឬជើងឯក។ ទឹកជំនន់ និងការបាត់បង់ជីវភាពរស់នៅត្រូវបានគេរាយការណ៍យ៉ាងទូលំទូលាយនៅតាមសហគមន៍ដែលបានស្ទង់មតិ។ គ្រួសារជាច្រើនបានរាយការណ៍ថា ប្រាក់ចំណូលចម្បងរបស់ពួកគាត់គឺផ្អែកលើការដាំដំណាំឬដោយការនេសាទនៅក្នុងបឹងនេះដែលពួកគាត់នឹងមិនអាចធ្វើបានទេនៅពេលដែលតំបន់បឹងត្រូវបានបំផ្លិចបំផ្លាញ។





*រថយន្តកំពុងដឹកដីមកចាក់បំពេញផ្ទៃដីបឹងទំពុនដើម្បីធ្វើការអភិវឌ្ឍ។ **រូបភាព៖ របាយការណ៍ អង្គការសម្ព័ន្ធខ្មែរជំរឿននិងការពារសិទ្ធិមនុស្សលីកាដូ (LICADHO) បណ្ដាញយុវជនកម្ពុជា (CYN) អង្គការសមធម៌កម្ពុជា(EC) និងអង្គការសមាគមធាងត្នោត (STT)***



*ផ្ទះនៅតាមច្រាំងទន្លេមានការបាក់ស្រុត។ **រូបភាព៖ របាយការណ៍***





*ខ្សាច់នៃតំបន់បឹងទំពុនដែលបានចាក់លុប (ពណ៌ក្រហម) និងតំបន់ដែលមានទឹកជាប្រចាំ (ពណ៌ខៀវ)។ **រូបភាព៖ របាយការណ៍***



*ប្រជាជនកំពុងប្រមូលផលដំណាំលើទឹកនៅក្នុងផ្ទៃបឹងទំពុន។ **រូបភាព៖ របាយការណ៍***

លើសពីនេះទៀត សិទ្ធិក្នុងការទទួលបានលំនៅឋានសមរម្យអាចត្រូវប្រឈមនឹងការបណ្ដេញចេញ ដោយហេតុថា ប្រជាសហគមន៍រាប់រយគ្រួសារគ្មានប័ណ្ណកម្មសិទ្ធិដីធ្លី។ ភាគច្រើននៃគ្រួសារទាំងនេះកំពុងទទួលរងនូវផលប៉ះពាល់នៃការជំពាក់បំណុលមិនសូវបានទទួលបានប័ណ្ណក្រីក្រ និងគ្រួសារស្ទើរតែទាំងអស់មិនទទួលបានការពិគ្រោះយោបល់ស្ដីពីគម្រោងអភិវឌ្ឍន៍នានារបស់ក្រុមហ៊ុនឯកជនទាំងនោះឡើយ។

លោក សឿង សារ៉ន ប្រធានអង្គការសមាគមធាងត្នោត បានថ្លែងថា៖ «រាជរដ្ឋាភិបាលមានការទទួលខុសត្រូវក្នុងការធានាការពារប្រជាជនពីការរំលោភសិទ្ធិមនុស្ស។ របាយការណ៍នេះត្រូវបានរៀបចំឡើងដើម្បីបង្ហាញពីហានិភ័យនានាទាក់ទងនឹងសិទ្ធិមនុស្ស ដើម្បីឱ្យរាជរដ្ឋាភិបាលអាចចាត់វិធានការដែលសមស្របនានាដើម្បីដោះស្រាយបញ្ហាទាំងនោះ»។

តំបន់បឹងទំពុនឬជើងឯកជាង៩០ភាគរយនឹងត្រូវរងផលប៉ះពាល់ធ្ងន់ធ្ងរ ហើយទន្លេបាសាក់ និងទន្លេមេគង្គក៏នឹងត្រូវបានបំពុលដោយសារការអភិវឌ្ឍទាំងនេះផងដែរ។ បច្ចុប្បន្ននេះ ដំណាំដែលដាំនៅលើផ្ទៃបឹង បានធ្វើព្រឹត្តកម្មទឹកកខ្វក់ដែលហូរចេញពីរាជធានីភ្នំពេញ មុនពេលវាហូរចេញពីបឹងនេះចូលទៅក្នុងទន្លេបាសាក់។ ប្រសិនបើបឹងត្រូវបានបាត់បង់ទឹកកខ្វក់នឹងហូរចូលទន្លេបាសាក់ឬទន្លេមេគង្គ ឬទន្លេទាំងពីរដោយមិនបានធ្វើព្រឹត្តកម្ម ដែលនេះបង្កហានិភ័យធ្ងន់ធ្ងរដល់ជម្រកត្រីនិងប្រជាសហគមន៍ដែលពួកគាត់ពឹងផ្អែកលើទន្លេសម្រាប់ទឹកបរិភោគ និងចំណីអាហាររបស់ពួកគាត់ប្រចាំថ្ងៃ។ ម្យ៉ាងវិញទៀត បឹងនេះគឺជាជម្រកនៃពពួកសត្វជាច្រើនប្រភេទរួមទាំងសត្វជិតផុតពូជផងដែរ។ ការធ្វើឱ្យប៉ះពាល់ឬបំផ្លិចបំផ្លាញតំបន់បឹងទំពុន ឬជើងឯកនឹងធ្វើឱ្យសត្វនិងជីវចម្រុះដែលកំពុងរស់នៅក្នុងបឹងទាំងនេះប្រឈមនឹងហានិភ័យធ្ងន់ធ្ងរ។

លោក អៀង វុទ្ធី ប្រធានអង្គការសមធម៌កម្ពុជា បានថ្លែងផងដែរថា៖ «ត្រីអាចត្រូវបានងាប់ បក្សីអាចត្រូវបានងាប់ ហើយវានឹងប៉ះពាល់ដល់សត្វនិងមនុស្សដទៃទៀត។ គេមិនទាន់ដឹងច្បាស់ថា តើមានវិធានការអ្វីខ្លះដើម្បីការពារប្រឆាំងនឹងការខូចខាតផ្នែកបរិស្ថាននេះ។ រាជរដ្ឋាភិបាលត្រូវប្រាកដថា ច្បាប់ពាក់ព័ន្ធនានាត្រូវបានគោរពដើម្បីការពារបរិស្ថាននិងសង្គម»។

លោកបានថ្លែងថា ការស្រាវជ្រាវនិងការចូលរួមជាសាធារណៈបន្ថែមទៀតគួរត្រូវបានធ្វើឡើងសម្រាប់គម្រោងដូចនេះ ពីព្រោះវានឹងធ្វើឱ្យប៉ះពាល់ដល់មនុស្សរាប់លាននាក់ និងអនាគតរាជធានីភ្នំពេញទាំងមូល។

របាយការណ៍ស្រាវជ្រាវខាងលើ ក៏បានរកឃើញថា ដីខ្សាច់ភាគច្រើនដែលចាក់លុបតំបន់បឹងពុន ឬជើងឯកនេះកំពុងត្រូវបានបូមចេញពីទន្លេមេគង្គនិងទន្លេបាសាក់។ បរិមាណដីខ្សាច់ដែលត្រូវការដើម្បីបំពេញនៅតំបន់បឹងទំពុនឬជើងឯកត្រូវបានគេប៉ាន់ប្រមាណថាមានចំនួនប្រហែល ៧៧,០០០,០០០ ម៉ែត្រគូបឬច្រើនជាង១០០លានតោន។ ការបូមខ្សាច់ចេញពីទន្លេក្បែរនោះបង្កជាហានិភ័យយ៉ាងខ្លាំងដល់បរិស្ថាននិងប្រជាជនក្នុងតំបន់ដែលរស់នៅក្បែរនោះ។

យោងតាមរបាយការណ៍ក្រុមអង្គការសិទ្ធិមនុស្ស បានបន្តលើកឡើង ពីអនុក្រឹត្យផ្សេងៗចាប់ពីឆ្នាំ២០១៧និង២០១៨ ស្ដីពីការកាត់ដីបឹងនេះទៅឱ្យបុគ្គលនិងក្រុមហ៊ុនឯកជនធ្វើការអភិវឌ្ឍ។ បើយោងតាមរបាយការណ៍នេះ មួយភាគបីនៃបឹង គឺត្រូវបានលុបទាំងស្រុង ដោយបន្សល់ទុកត្រឹមតែ ១០០០ ហិកតាប៉ុណ្ណោះ។

តាមរបាយការណ៍នេះ ក្រៅពីអត្ថប្រយោជន៍សម្រាប់ប្រជាពលរដ្ឋ កសិករ និងអ្នកនេសាទ ដែលបានរស់នៅនិងអាស្រ័យផលបឹងអស់រាប់ទសវត្ស បឹងក៏ជាផ្នែកមួយដ៏សំខាន់ក្នុងការកាត់បន្ថយទឹកជំនន់ដោយទឹកភ្លៀង និងទឹកស្អុយប្រមាណ ៧០ភាគរយបានហូរចូលក្នុងបឹងនេះ។

កាលពីខែមិថុនាកន្លងមកនេះ នាយករដ្ឋមន្ត្រីនៃប្រទេសកម្ពុជា សម្ដេចតេជោ ហ៊ុន សែន បានចុះហត្ថលេខាលើអនុក្រឹតមួយក្នុងការផ្ដល់ដីចំនួន ៣០០ហិកតា ផ្ដល់ឱ្យក្រសួងការពារជាតិ ដើម្បីសាងសង់មូលដ្ឋានបញ្ជាការយុទ្ធសាស្ត្រយូរអង្វែងនៃកងយោធពលខេមរភូមិន្ទ។ អនុក្រឹតមួយទៀតចុះថ្ងៃទី២៧ ខែមេសា ឆ្នាំ២០២០ ផ្ទៃបឹងចំនួន ៣០ហិកតាត្រូវបានកាត់ទៅឱ្យអ្នកស្រី គឹម ហ៊ាង ភរិយា លោក លី យ៉ុងផាត់ ដែលជា សមាជិកព្រឹទ្ធសភាគណបក្សប្រជាជនកម្ពុជា ក្នុងការដោះដូរនឹងដីនៅរាជធានីភ្នំពេញ ៩,៨ហិកតា។ បើយោងតាមរបាយការណ៍របស់ក្រុមសិទ្ធិមនុស្ស អ្នកស្រី គឹម ហ៊ាង គឺប្រធានក្រុមហ៊ុន Hero King Ltd., ដែលក្រុមហ៊ុននេះ មានពាក់ព័ន្ធនឹងការផ្ដល់ខ្សាច់ដើម្បីចាក់លុបបឹង៕



លោក លី គួនយ៉ូវ (Lee Kuan Yew)។ រូបភាព៖ បរទេស



គឺលោក លី សៀនឡុង (Lee Hsien Loong)។ រូបភាព៖ បរទេស



លោក លី សៀនយ៉ាង (Lee Hsien Yang)។ រូបភាព៖ បរទេស

# ត្រកូលលីនិងចក្ខុវិស័យនយោបាយនៅសិង្ហបុរី

*អត្ថបទ៖ អរិយបុត្រ*

ត្រកូលលីអាចជាសន្តិវង្សនយោបាយមួយនៅអាស៊ីអាគ្នេយ៍ ដោយសារតែជាត្រកូលមួយដែលកំពុងតែកាន់អំណាចនៅក្នុងប្រទេសសិង្ហបុរីជាបន្តបន្ទាប់ចាប់តាំងពីប្រទេសនេះមិនទាន់ទទួលបានឯករាជ្យពីម៉ាឡេស៊ី រហូតដល់បានឯករាជ្យហើយក្រោយពីឯករាជ្យនៅក្នុងឆ្នាំ១៩៦៣ រហូតដល់ពេលបច្ចុប្បន្ននេះ។

សន្តិវង្សនយោបាយនេះបានកកើតឡើងដោយបិតាឯករាជ្យនិងអភិវឌ្ឍន៍សិង្ហបុរី គឺលោក លី គួនយ៉ូវ (Lee Kuan Yew) ដែលគេដឹងថា បានកាន់អំណាចនៅក្នុងដំណែងជានាយករដ្ឋមន្ត្រីសិង្ហបុរីតាំងតែពីឆ្នាំ ១៩៥៩ រហូតដល់ឆ្នាំ ១៩៩០ បានសម្រេចចុះចេញពីតំណែងដោយប្រគល់តំណែងនេះ ទៅអ្នកដែលជិតស្និតនឹងលោកបំផុត គឺលោក ហ្គោ ចុកតុង ( Goh Chok Tong) ប៉ុន្តែទោះបីជាយ៉ាងណាក៏ដោយក៏លោក នៅតែបន្តកាន់តំណែងជាទេសរដ្ឋមន្ត្រីនៅក្នុងរដ្ឋបាលរបស់អ្នកបន្តវេនរបស់លោកដដែល រហូតដល់ ឆ្នាំ២០០៤ នៅពេលដែលកូនប្រុសច្បងរបស់លោក គឺលោក នាយករដ្ឋមន្ត្រីបច្ចុប្បន្ននៅក្នុងប្រទេសសិង្ហបុរី គឺលោក លី សៀនឡុង (Lee Hsien Loong) លោក លី គួនយ៉ូវ បានបន្តស្ថិតនៅទីប្រឹក្សាមួយសម្រាប់រដ្ឋាភិបាលកូនប្រុសលោករហូតដល់ឆ្នាំ២០១១។

លោក លី គួនយ៉ូវ បានទទួលមរណភាពនៅក្នុងឆ្នាំ ២០១៥ ប៉ុន្តែក្រោយពេលដែលលោកបានទទួលមរណៈភាពបានប៉ុន្មានឆ្នាំក៏ផ្ទុះរឿងជម្លោះផ្ទៃក្នុងគ្រួសារមួយរវាងលោក លី សៀនឡុង នឹងលោក លី សៀនយ៉ាង (Lee Hsien Yang) ដែលជាប្រុសពៅនៃសន្តិវង្សលីនៅសិង្ហបុរី។ លោក លី គួនយ៉ូវ គឺមានកូនប្រុសពីរនាក់ ដោយកូនស្រីកណ្តាលឈ្មោះ លី វៃលីង (Lee Wei Ling)។

សិង្ហបុរីជាប្រទេសប្រជាធិបតេយ្យ ដែលមេដឹកនាំរបស់ប្រទេសគឺអាចឡើងកាន់អំណាចបានតាមការបោះឆ្នោត ប៉ុន្តែអ្វីៗទាំងអស់វាអាចសុទ្ធតែជាយុទ្ធសាស្ត្រនយោបាយដែលផ្តួចផ្តើមឡើងដោយលោក លី គួនយ៉ូវ ក៏ថាបាន។ ពីព្រោះត្រកូលនេះត្រូវបានគេមើលឃើញថា សុទ្ធតែជាអ្នកដែលកាន់កាប់ការងារ សំខាន់ៗនៅក្នុងប្រទេសមិនខុសពីមេដឹកនាំនានា នៅក្នុងតំបន់អាស៊ីអាគ្នេយ៍ផ្សេងៗទៀតឡើយ។ នៅក្នុងចំណោមបងប្អូនប្រុសស្រីត្រកូលលីទាំងបីនាក់ គឺសុទ្ធតែមានតួនាទីនិងសុទ្ធតែជាជនដែលមានមុខមាត់នៅក្នុងសង្គមសិង្ហបុរី ដោយលោក លី សៀនឡុង ជានាយករដ្ឋមន្ត្រីនៅក្នុងតំណែង ហើយ ទើបតែជាប់ឆ្នោតជាថ្មីថែមទៀត។

លោក លី សៀនឡុង នៅមុនពេលត្រូវបានជាប់ឆ្នោតបន្តការដឹកនាំប្រទេសពីលោក ហ្គោ ចុកតុង លោក គឺជាអតីតឧត្តមសេនីយមួយរូបនៅក្នុងជួរកងទ័ពរបស់សិង្ហបុរី ហើយលោកបានបម្រើការងារមួយចំនួនទៀត រហូតដល់ឧបនាយករដ្ឋមន្ត្រីនៅក្នុងរដ្ឋបាលរបស់លោក ហ្គោ ចុកតុង ដែលជាអ្នកបន្តវេនពីឪពុករបស់លោក។ ប្អូនប្រុសពៅរបស់លោកនាយករដ្ឋមន្ត្រីបច្ចុប្បន្ន គឺលោក លី សៀនយ៉ាង ក៏ត្រូវបានគេដឹងថា ជាអតីតឧត្តមសេនីយកងទ័ពផងដែរ ហើយជាអតីតប្រធានប្រតិបត្តិនៃក្រុមហ៊ុន សីងតែល (Sing Tel) ដែលជាក្រុមហ៊ុនដ៏ធំនៅសិង្ហបុរី ជាអតីតប្រធាននៃអាជ្ញាធរអាកាសចរណ៍ស៊ីវិលសិង្ហបុរី។ ដោយឡែក ប្អូនស្រីកណ្តាលរបស់ត្រកូលនេះ ត្រូវបានគេដឹងថា គឺជាប្រធានវិទ្យាស្ថានវិទ្យាសាស្ត្រប្រព័ន្ធ ប្រាសាទ ជាតិសិង្ហបុរី ។

រហូតមកដល់ពេលបច្ចុប្បន្ននេះបងប្អូនត្រកូលលី កំពុងតែមានជម្លោះនឹងគ្នា ដោយពេលនេះ លោក លី សៀនយ៉ាង បានកំពុងតែរស់នៅក្នុងជីវភាពនយោបាយនៅគណបក្សប្រឆាំងរបស់ប្រទេសនេះ ដោយសារ តែជម្លោះផ្ទៃក្នុងមួយដែលមិនគួរផ្ទុះសម្រាប់ត្រកូលដែលមានការសិក្សា មានប្រវត្តិការងារល្អមានការឃុំគ្រងយ៉ាងល្អពីលោក លី គួនយ៉ូវ។

ទំនាស់នោះគឺរឿងដណ្តើមកេរ្តិ៍មរតកផ្ទះ ដែលពួកគេធ្លាប់រស់នៅជួបជុំគ្រួសារដែលជាកម្មសិទ្ធិរបស់ លោក លី គួនយ៉ូវ។ ដោយប្អូនប្រុសនិងប្អូនស្រីរបស់លោក លី សៀនឡុង បានចោទប្រកាន់លោក លី ថា បានប្រឆាំងនឹងបំណងរបស់ឪពុកនិងរំលោភអំណាច ប៉ុន្តែទោះបីជាយ៉ាងណាក៏ដោយក៏ លោក លី សៀនឡុង បានបដិសេធ នូវការចោទប្រកាន់របស់ប្អូនប្រុសនិងប្អូនស្រីរបស់លោក។

ទំនាស់គ្រួសារនេះបានផ្ទុះឡើងជាសាធារណៈកាលពីឆ្នាំ២០១៩ នៅថ្ងៃខួបនៃការស្លាប់របស់លោក លី គួនយ៉ូវ នៅពេលដែលប្អូនស្រីលោកនាយករដ្ឋមន្ត្រីសិង្ហបុរី លី វៃលីង បានចោទបងប្រុសរបស់ខ្លួនថា ធ្វើអាជីវកម្មលើកេរ្តិ៍មរតករបស់ឪពុកដើម្បីខ្លួនលោក។ ក្រោយមកលោក លី សៀនយ៉ាង ក៏បានប្រកាសជាសាធារណៈ ថា រូបគាត់បានបាត់បង់ជំនឿទុកចិត្តលើបងប្រុសរបស់ខ្លួនថា ជាមេដឹកនាំរបស់ជាតិទៀតហើយ។

លោក លី សៀនយ៉ាង បានអះអាងថា បំណងរបស់ឪពុកគឺនៅពេលដែលស្លាប់ទៅ គឺត្រូវតែបំផ្លាញផ្ទះដែលស្ថិតនៅលើផ្លូវ ៣៨ អូកស្លេ (Oxley) ជាជាងទុកតំណាងឱ្យនិមិត្តរូបរបស់លោក។

ឆ្លើយតបនឹងការចោទប្រកាន់របស់ប្អូនៗ លោក លី សៀនឡុង ក៏បានប្រកាសជាសាធារណៈថា លោកនឹងដកខ្លួនចេញពីការសម្រេចចិត្តទាំងអស់របស់រដ្ឋាភិបាលនិងអាជ្ញាធរជុំវិញផ្ទះនោះ ហើយខ្លួនលោកផ្ទាល់ គឺគោរពនិងឱ្យតម្លៃលើបំណងរបស់ឪពុកជានិច្ច។

ផ្ទះនោះត្រូវបានគេដឹងថា មានតម្លៃប្រមាណជា ២៤ លានដុល្លារសិង្ហបុរីឬ ១៧ លានដុល្លារអាមេរិកតែប៉ុណ្ណោះ។ផ្ទះនេះគឺមានទំហំ ប្រមាណជា ១២.០៦០ ហ្វិតការ៉េ ឬប្រមាណជាជាង ១.១២០ ម៉ែត្រការ៉េដែលគ្រួសារលី បានរស់នៅតាំងតែពីឆ្នាំ១៩៤៥។

ក្រោយមកមិនយូរប៉ុន្មានពោលនៅខែមិថុនា ឆ្នាំ២០២០ កន្លងទៅនេះ លោក លី សៀនយ៉ាង បានប្រកាសចាកចេញពីគណបក្សកាន់អំណាចដែលបង្កើតឡើងដោយឪពុករបស់ខ្លួន ហើយមកចូលរួមជាមួយនឹងគណបក្សប្រឆាំងថ្មីមួយ គឺគណបក្ស សិង្ហបុរីរីកចម្រើន (Progress Singapore Party ) តែលោកមិនបានចូលរួមឈរឈ្មោះបោះឆ្នោតប្រជែងជាមួយនឹងបងប្រុសរបស់លោកនៅក្នុងការបោះឆ្នោតកាលពីថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០២០ នោះទេ។

ការចាកចេញរបស់ប្អូនប្រុសរបស់លោក លី សៀនឡុង គឺជាការវាយសំពងមួយទៅលើគណបក្សសកម្មភាពប្រជាជន (People's Action Party) ដែលបានកាន់អំណាចតាំងតែពីរទទួលបានឯករាជ្យនៅឆ្នាំ១៩៦៥ មក។

នៅក្នុងការបោះឆ្នោតគណបក្សរបស់លោក លី សៀនឡុង បានបន្តឈ្នះការបោះឆ្នោត ដោយទទួលបានការគាំទ្រចំនួន ៨៣អសនៈនៅក្នុងចំណោមអសនៈនៅក្នុងសភាសរុប៩៣ ប៉ុន្តែប្រជាប្រិយភាពរបស់គណបក្សប្រឆាំងគឺគណបក្សរបស់ពលករ (Wokers'Party) គឺមានការកើនឡើងនូវការគាំទ្រគួរជាទីកត់សំគាល់ ប៉ុន្តែគណបក្សសិង្ហបុរីរីកចម្រើនគឺមិនទទួលបានជោគជ័យឡើយ។

បើទោះបីជាគណបក្សសិង្ហបុរីរីកចម្រើននេះមិនទទួលបានជោគជ័យក៏ពិតមែន ប៉ុន្តែគេដឹងថា គណបក្សនេះគឺជាគណបក្សដ៏ក្មេងខ្ចីជាងគេនៅក្នុងចំណោមគណបក្សនយោបាយដែលមាននៅសិង្ហបុរីនាពេលបច្ចុប្បន្ននេះ។ គណបក្សនេះមានអាយុកាលមិនដល់ ១ឆ្នាំផងទេ ប៉ុន្តែបានទទួលការចូលរួមពី លោក លី សៀនយ៉ាង ដែលជាបុរសសមាជិកត្រកូលលីមួយរូប។

តាមការគ្រោងទុក លោក លី សៀនឡុង ដែលនៅពេលនេះមានអាយុ ៦៨ ឆ្នាំ ហើយនោះ កំពុងតែគ្រោងនឹងលាចេញពីតំណែងនៅក្នុងរង្វង់ឆ្នាំ២០២២ ហើយប្រគល់តំណែងទៅមន្ត្រីក្នុងបក្សដែលលោកបានសំឡឹងមើលទុករួចខ្លះៗហើយ។ លោក លី សៀនឡុង មានកូនចំនួន៤នាក់ កូនស្រីម្នាក់ និង កូនប្រុស៣នាក់ ប៉ុន្តែពួកគេដូចជាមិនសូវលេចមុខនៅក្នុងសង្គមនយោបាយនៅឡើយអាចថាពួកគេនៅក្មេង ឬ មិនចូលចិត្តក៏ថាបាន។

តើការចាកចេញរបស់លោក លី សៀនយ៉ាង ពីគណបក្សកាន់អំណាចដែលបង្កើតឡើងដោយឪពុកទៅចូលរួមគណបក្សដ៏ក្មេងខ្ចី ទើបតែបង្កើតអាចជារឿងយុទ្ធសាស្ត្រកសាងសន្តិវង្សនយោបាយដែលរៀបចំដោយលោក លី គួនយ៉ូវ ដែរឬទេ? គ្មាននរណាដឹង ប៉ុន្តែលោក លី សៀនយ៉ាង គឺអាចដោយលោកទើបតែមានអាយុ៦២ឆ្នាំ ហើយជាអតីតឧត្តមសេនីយ ជាអតីតប្រធានប្រតិបត្តិក្រុមហ៊ុន ស៊ីងតែល (Sing Tel) ប្រធានអាជ្ញាធរអាកាសចរណ៍ស៊ីវិល សិង្ហបុរី។ លោក លី គួនយ៉ូវ អាចនឹងដឹងអំពីទំនោរនយោបាយ និងទឹកចិត្តរបស់ពលរដ្ឋសិង្ហបុរីនៅក្នុងការរក្សាប្រជាប្រិយភាពដើម្បីបន្តសន្តិវង្សលី នៅក្នុងជីវភាពនយបាយសិង្ហបុរីតាមវិធីសាស្ត្រដ៏សមស្រប ប៉ុន្តែទោះបីជាយ៉ាងណាក៏ដោយ នេះគឺគ្រាន់តែជាការវិភាគមួយជ្រុងតែប៉ុណ្ណោះ៕



លោក លី គួនយ៉ូវ ក្នុងសកម្មភាពដឹកនាំកាលពីអតីតកាល។ រូបភាព៖ បរទេស





# កម្ពុជាបានផ្អាកការហោះហើរពីប្រទេស ម៉ាឡេស៊ី ឥណ្ឌូនេស៊ី និងហ្វីលីពីន

*អត្ថបទ៖ អមរិន្ទ ជានុត*

នាយករដ្ឋមន្ត្រីនៃប្រទេសកម្ពុជា សម្តេចតេជោ ហ៊ុន សែន បានយល់ព្រមតាមសំណើររបស់រដ្ឋមន្ត្រីក្រសួងសុខាភិបាលក្នុងការផ្អាកជាបណ្តោះអាសន្ននូវជើងហោះហើរពីប្រទេសម៉ាឡេស៊ីនិងឥណ្ឌូនេស៊ីមួយរយៈចាប់ពីថ្ងៃទី១ ខែសីហា ឆ្នាំ២០២០តទៅ។

យោងតាមលិខិតរបស់រដ្ឋមន្ត្រីក្រសួងសុខាភិបាល លោក ម៉ម ប៊ុនហេង ផ្ញើជូនសម្តេចតេជោ ហ៊ុន សែនចុះថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០២០នេះ ដែលអ្នកនាំសារ ទទួលបាន បានបញ្ជាក់ថា យោងតាមស្មារតីអង្គប្រជុំបន្ទាន់រវាងក្រសួងសុខាភិបាលនិងអភិបាលរាជធានីភ្នំពេញនៅថ្ងៃដដែលបានសម្រេចធ្វើការស្នើសុំគោលការណ៍ពីសម្តេចតេជោក្នុងការផ្អាកការហោះហើរនេះ។

លោក ម៉ម ប៊ុនហេង បានមានប្រសាសន៍ក្នុងលិខិតនេះថា៖ «ក្នុងរយៈពេលចុងក្រោយចាប់ពីថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០២០ដល់ថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០២០នេះ ក្រសួងសុខាភិបាលសង្កេតឃើញថា មានអ្នកដំណើរតាមជើងហោះហើរមកពីប្រទេសម៉ាឡេស៊ី និងឥណ្ឌូនេស៊ីបានរកឃើញករណីឆ្លងវីរុសកូវីដ១៩ មានការកើនឡើងគួរឱ្យកត់សម្គាល់ ជាក់ស្តែងចំនួនអ្នកវិជ្ជមាននៃវីរុសកូវីដ១៩មាន១០៨នាក់ ក្នុងនោះភាគច្រើនតាមជើងហោះហើរពីប្រទេសម៉ាឡេស៊ី (៥៥នាក់លើ១០៨នាក់) និងឥណ្ឌូនេស៊ីលើអ្នកដំណើរសរុបចំនួន២៣,៥៦៧នាក់»។

លោកបានបន្តទៀតថា ចាប់ពីខែសីហា និងខែកញ្ញា តទៅ ប្រទេសកម្ពុជានឹងមានការឈប់សម្រាកក្នុងពិធីបុណ្យជាតិជាច្រើនថ្ងៃដែលតម្រូវឱ្យ (យើង) បង្កើនការប្រុងប្រយ័ត្នខ្ពស់ក្នុងកិច្ចការពារការចម្លងវីរុសកូវីដ១៩។

លោក ម៉ម ប៊ុនហេង បានបន្ថែមទៀតថា ក្នុងន័យនេះ ដើម្បីកាត់បន្ថយហានិភ័យនៃការឆ្លងវីរុសកូវីដ១៩ ពីខាងក្រៅនិងការបង្កើនការការពារសុខភាពជូនប្រជាពលរដ្ឋទូទាំងប្រទេស ក្រសួងសុខាភិបាលគោរពស្នើសុំគោលការណ៍ដ៏ខ្ពង់ខ្ពស់ពីសម្តេចតេជោមេត្តាពិនិត្យនិងសម្រេចក្នុងការផ្អាកជាបណ្តោះអាសន្ននូវជើងហោះហើរពីប្រទេសម៉ាឡេស៊ីនិងឥណ្ឌូនេស៊ីមួយរយៈចាប់ពីថ្ងៃទី១ ខែសីហា តទៅ រហូតដល់គណៈកម្មការអន្តរក្រសួងដើម្បីប្រយុទ្ធនឹងជំងឺកូវីដ១៩ពិនិត្យនិងវាយតម្លៃទៅលើហានិភ័យនៃការចម្លងវីរុសកូវីដ១៩ និងសុំគោលការណ៍សម្រេចដ៏ខ្ពង់ខ្ពស់ពីសម្តេចតេជោបើកជើងហោះហើរសារជាថ្មី។

សម្តេចតេជោ ហ៊ុន សែន បានចារ «យល់ព្រម» នៅលើលិខិតស្នើសុំពីរដ្ឋមន្ត្រីក្រសួងសុខាភិបាល លោក ម៉ម ប៊ុនហេង នៅថ្ងៃដដែលនេះផងដែរ។

គួរបញ្ជាក់ផងដែរថា នៅថ្ងៃនេះដែរ (ទី២៥ ខែកក្កដា) ក្រសួងសុខាភិបាលបានប្រកាសរកឃើញអ្នកវិជ្ជមានវីរុសកូវីដ១៩ ចំនួន២៣នាក់ទៀតបន្ថែមទៀតដែលសុទ្ធសឹងតែជាការនាំចូល។

ជាមួយគ្នានេះដែរ អ្នកនាំពាក្យនៃក្រសួងសុខាភិបាល លោកស្រី ឱ វណ្ណឌីន បានប្រាប់ឱ្យដឹងថា លទ្ធភាពនៃការចម្លងវីរុសកូវីដ១៩ ចូលសហគមន៍មិនអាចមើលរំលងបានឡើយដូច្នេះហើយ បានជាក្រសួងសុខាភិបាល តែងតែអំពាវនាវហើយអំពាវនាវទៀត ឱ្យបងប្អូនប្រជាពលរដ្ឋ ត្រូវតែបន្តកិច្ចការពារខ្លួនជាប់ជានិច្ច។

លោកស្រី បានឱ្យសារព័ត៌មានក្នុងស្រុកដឹងបន្ថែមថា៖ «ថ្ងៃនេះ ថ្វីត្បិតតែការរកឃើញអ្នកវិជ្ជមានវីរុសកូវីដ១៩ ចំនួន ២៣នាក់ ទៀត ជាករណីនាំចូលក៏ពិតមែន តែវាជាចំនួនច្រើនណាស់ ដែលយើងមិនអាចដឹងបានថា តើបន្តទៅមុខទៀតយ៉ាងណាដែរនោះទេ? ដូច្នេះ សូមអ្នកដើរកំសាន្តទាំងអស់ ត្រូវតែចេះប្រុងប្រយ័ត្នមែនទែន ដោយសារហានិភ័យនៃការចម្លងវីរុសកូវីដ១៩ ដែលអាចកើតមានគ្រប់ពេលវេលា គ្រប់កាលៈទេសៈ និងគ្រប់ទីកន្លែងទាំងអស់។ សុំកុំភ្លេចខ្លួន និងសុំកុំសន្តិភាពនិយមជាមួយវីរុសកូវីដ១៩ នេះឱ្យសោះ»។

លោកស្រី ឱ វណ្ណឌីន ក៏បានអំពាវនាវដល់ប្រជាពលរដ្ឋទាំងអស់មានសុខភាពល្អ ចៀសផុតការចម្លងវីរុសដ៏កាចសាហាវមកបុគ្គល មកក្រុមគ្រួសារ និងចៀសផុតពីការចម្លងចូលសហគមន៍ជាបន្តទៀត។

អ្នកនាំពាក្យរូបនេះក៏បានបញ្ជាក់ផងដែរថា៖ «ករណីទាំងនេះមិនមែនជារលកទីពីរទេ ដោយសារវាជាករណីនាំចូលប៉ុណ្ណោះ»៕



រាជរដ្ឋាភិបាលបានសម្រេចផ្អាកជាបណ្តោះអាសន្ននូវជើងហោះហើរពីប្រទេសម៉ាឡេស៊ីនិងឥណ្ឌូនេស។ រូបភាព៖ ស៊ីអេសស៊ី

# បុរសដែលស្លាប់នៅកន្លែងធ្វើចត្តាឡីស័កខេត្តត្បូងឃ្មុំ ដឹងមូលហេតុហើយ

*អត្ថបទ៖ ....*

ក្រសួងសុខាភិបាលបានបញ្ជាក់កាលពីយប់ថ្ងៃព្រហស្បតិ៍ ទី២៣ ខែកក្កដាថា បុរសអាយុ២១ឆ្នាំដែលបានស្លាប់នៅក្នុងកន្លែងធ្វើចត្តាឡីស័កកាលពីយប់ថ្ងៃពុធ ទី២២ ខែកក្កដាក្នុងសាលាបឋមសិក្សាភូមិ៥ ឃុំស្វាយឃ្លាំង ស្រុកក្រូចឆ្មារ ខេត្តត្បូងឃ្មុំ គឺបណ្តាលមកពីខ្យល់គរ គួបផ្សំនឹងការលេបថ្នាំច្រើនមុខពេក ដែលសរីរាង្គគាត់មិនអាចទ្រាំទ្របាន។

យោងតាមសេចក្តីជូនព័ត៌មានរបស់ក្រសួងសុខាភិបាលបានឱ្យដឹងថា បុរសរូបនេះបានទៅធ្វើពលករនៅប្រទេសម៉ាឡេស៊ី នៅថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០២០ ធ្វើដំណើរតាមផ្លូវគោកឆ្លងកាត់ប្រទេសថៃនិងបានឆ្លងព្រំដែនថៃ ចូលមកប្រទេសកម្ពុជាតាមច្រកប៉ោយប៉ែត ប៉ុន្តែគ្រូពេទ្យបានអនុញ្ញាតឱ្យគាត់មកស្រុកកំណើតដើម្បីបន្តធ្វើចត្តាឡីស័កបន្តនៅថ្ងៃទី២០ ខែកក្កដា កន្លងមកនៅក្នុងខេត្តត្បូងឃ្មុំ ខណៈការធ្វើតេស្តអវិជ្ជមានកូវីដ១៩។

នៅពេលដែលគាត់ស្នាក់នៅ ក្រុមគ្រូពេទ្យបានតាមដានពិនិត្យសុខភាពគាត់ជាប់ជាប្រចាំនិងមានការវាស់កំដៅផងដែរ តែមិនមានបញ្ហាអ្វីឡើយហើយសាមីសពក៏មិនដែលប្រាប់គ្រូពេទ្យអំពីអាការៈមិនស្រួលឬក៏មានអាការៈផ្តាសាយរបស់ខ្លួនដែរ។

បុរសរូបនេះបានស្លាប់នាយប់ថ្ងៃទី២២ ខែកក្កដា ហើយបន្ទាប់ពីការសាកសួរពីបងប្រុសរបស់សពដែលឧស្សាហ៍មកជួបសាមីសព ទើបដឹងថា បងប្រុសសពបានទិញថ្នាំពីឱសថខាងក្រៅយកមកឱ្យលេបដោយលេបម្តងៗមានថ្នាំចំនួន៥មុខ ដូចជា Paracetamol ៥00mg, Dexamethasone ៤mg, Chlopheniramine ៤mg, Tetracicliyne ២៥0mg និងMoxy Cold។

ក្រសួងបានបន្តថា ការប្រើប្រាស់ថ្នាំទាំងនេះ គឺជាការសម្រេចចិត្តដោយសាមីសពខ្លួនឯងនិងមានការលាក់លៀមមិនឱ្យក្រុមគ្រូពេទ្យដែលពិនិត្យសុខភាពប្រចាំថ្ងៃបានដឹង ហើយថ្នាំនេះទៀតបានផ្តល់ទៅឱ្យអ្នកស្លាប់នៅពេលយកបាយទៅឱ្យ។ ក្រោយលេបថ្នាំរួច នៅរសៀលថ្ងៃដដែល អ្នកជំងឺមានអាការៈថប់ដង្ហើមងងឹតមុខ រួចក៏សន្លប់បាត់ការដកដង្ហើម ទោះជាក្រុមគ្រូពេទ្យព្យាយាមជួយសង្គ្រោះដោយធ្វើម៉ាស្សាបេះដូងពីខាងក្រៅនិងដាក់អុកស៊ីហ្សែន និងជំនួយផ្សេងៗទៀតតាមបច្ចេកទេសសង្គ្រោះរបស់ពេទ្យក៏នៅតែមិនអាចជួយសង្គ្រោះបាន។

ក្រសួងសុខាភិបាលបានធ្វើការសន្និដ្ឋាន៖ «ជាលទ្ធផលនៃការវិភាគរបស់មន្ទីរពិសោធន៍វិទ្យាស្ថានប៉ាស្ទ័រកម្ពុជាដែលទទួលបាននៅម៉ោង៦ល្ងាចនេះ បានបង្ហាញថា អវិជ្ជមានវីរុសកូវីដ១៩។ ដូច្នេះ ការសន្និដ្ឋានលើករណីស្លាប់នេះ គឺអាចបណ្តាលមកពីខ្យល់គ គួបផ្សំនិងការលេបថ្នាំច្រើនមុខពេក ដែលសរីរាង្គគាត់មិនអាចទ្រាំទ្របាន»។

អនុវត្តតាមវិធានការសុខាភិបាល ក្រុមគ្រូពេទ្យមន្ទីរសុខាភិបាលខេត្តត្បូងឃ្មុំ បានណែនាំអំពីវិធានការដោយបង្ខំចិត្តធ្វើការបញ្ចុះសពទាំងយប់ ចៀសវាងការចម្លងរោគជាយថាហេតុ, មិនអនុញ្ញាតឱ្យចំអាសទឹក និងយកសំណាកវត្ថុវិភាគសាមីសពទៅវិទ្យាស្ថានប៉ាស្ទ័រកម្ពុជា ដើម្បីរកមើលវត្តមានវីរុសកូវីដ១៩ ប៉ុន្តែរកឃើញថាអវិជ្ជមានវីរុសនេះ។

ក្រសួងសុខាភិបាលអំពាវនាវទៅដល់ប្រជាពលរដ្ឋគ្រប់រូបសូមកុំប្រើប្រាស់ថ្នាំដោយខ្លួនឯង ដែលមានហានិភ័យខ្ពស់ណាស់សម្រាប់ផលប៉ះពាល់សុខភាពរបស់ខ្លួន និងអាចបាត់បង់ជីវិតបាន៕



មន្ត្រីពេទ្យពិនិត្យសាកសពបុរសដែលស្លាប់នៅកន្លែងធ្វើចត្តាឡីស័កខេត្តត្បូងឃ្មុំ។ សហការី

# ក្រសួងសុខាភិបាល៖ អត្រាគ្រុនឈាមថយចុះប៉ុន្តែត្រូវបន្តការពារការចម្លង

*អត្ថបទ៖ អមរិន្ទ ដានុត*

ក្រសួងសុខាភិបាលបានឱ្យដឹងថា ស្ថានភាពនៃជំងឺគ្រុនឈាមក្នុងរយៈពេល៦ខែឆ្នាំ២០២០នេះមានចំនួនសរុប៣.៣៣៩ករណីដែលមានស្លាប់ចំនួន៤ករណី (អត្រាស្លាប់០,០៣%)។ ចាប់ពីខែមករាដល់ខែមិថុនាឆ្នាំ២០២០នេះ ករណីជំងឺគ្រុនឈាមបានថយចុះប្រមាណជា៨៨ភាគរយ បើធៀបទៅនឹងរយៈពេលដូចគ្នានឹងឆ្នាំមុន ដែលមាន២៨.២៨៥ករណីនិងមានអ្នកស្លាប់រហូត៣២នាក់។

សេចក្តីប្រកាសព័ត៌មានរបស់ក្រសួងសុខាភិបាលបានបន្តថា ករណីជំងឺគ្រុនឈាមបានថយចុះនៅទូទាំងប្រទេសនាដើមឆ្នាំ២០២០ តែករណីមានរាយប៉ាយដុំៗតាមភូមិសាស្ត្រប្រជុំជនមួយចំនួន ពិសេសនៅរាជធានីភ្នំពេញ ខេត្តព្រះសីហនុ ប៉ៃលិន សៀមរាប កណ្តាល កំពង់ធំ តាកែវ មណ្ឌលគិរី រតនគិរី និងខេត្តព្រះវិហារ។

ស្ថានភាពជំងឺគ្រុនឈាមក្នុងប្រទេសកម្ពុជាកំពុងស្ថិតនៅក្នុងស្ថានភាពធម្មតាក្រោមការគ្រប់គ្រងយ៉ាងល្អរបស់កម្មវិធីប្រយុទ្ធនឹងជំងឺគ្រុនឈាមទូទាំងប្រទេស ដែលមានការចូលរួមអន្តរាគមន៍និងសហការពេញលេញរបស់គ្រប់ដៃគូពាក់ព័ន្ធ និងប្រជាពលរដ្ឋក្នុងសហគមន៍។

រដ្ឋមន្ត្រីក្រសួងសុខាភិបាល លោក ម៉ម ប៊ុនហេង បានលើកឡើងថា ការងារប្រយុទ្ធនឹងជំងឺគ្រុនឈាមគឺជាកាតព្វកិច្ចរបស់បុគ្គលម្នាក់ៗគ្រប់រូបដែលត្រូវចូលរួមទទួលខុសត្រូវដាច់ខាតលើការងារដូចជា លុបបំបាត់ភ្នាក់ងារចម្លងមូសខ្លានិងជង្រុកទឹក រួសរាន់ទៅទទួលយកសេវាធ្វើរោគវិនិច្ឆ័យ ព្យាបាលថែទាំករណីជំងឺត្រឹមត្រូវទាន់ពេលវេលា ដោយមិនត្រូវទុកអ្នកជំងឺគ្រុនក្តៅសាកល្បងព្យាបាលដោយខ្លួនឯង និងមិនបានសង្ស័យអំពីជំងឺគ្រុនឈាម និងត្រូវចូលរួមអនុវត្តវិធានការរស់នៅស្អាត បរិស្ថានផ្ទះសំបែងមានអនាម័យ សំរាន្តក្នុងមុងទាំងថ្ងៃទាំងយប់ ប្រើសម្លៀកបំពាក់ដៃជើងវែងៗបង្ការការខាំរបស់សត្វមូសជាដើម។

លោកបានថ្លែងថា៖ «ក្រសួងសុខាភិបាលនៅតែបន្តផ្តល់ជូនដោយមិនគិតថ្លៃនូវថ្នាំបាណកឃាដ (ថ្នាំអាបែត) សម្រាប់ដាក់ចូលក្នុងភាជន៍ទឹកទុកប្រើប្រាស់មួយឆ្នាំ២ដង (ដើមនិងចុងរដូវវស្សា )នៅតាមផ្ទះគ្រប់ៗគ្នាតាមគោលដៅភូមិសាស្ត្រនៃភ្នាក់ងារចម្លងមូសខ្លា»៕



# ករណីគ្រុនចាញ់ក្នុងឆមាសទី១ឆ្នាំនេះ ថយចុះ ៧០ភាគរយនិងគ្មានអ្នកស្លាប់

*អត្ថបទ៖ អមរិន្ទ ដានុត*



ក្នុងរយៈពេល៦ខែដើមឆ្នាំ២០២០នេះ ជំងឺគ្រុនចាញ់មានការថយចុះ៧០ភាគរយបើធៀបនឹងរយៈពេលដូចគ្នានឹងឆ្នាំ២០១៩ ដែលមានចំនួន៤៥៤០ករណីធៀបនឹង១៥.១៦៥ករណី ប៉ុន្តែមិនមានស្លាប់នោះទេ។ នេះបើយោងតាមសេចក្តីជូនដំណឹងរបស់ក្រសួងសុខាភិបាលស្តីពីស្ថានភាពជំងឺគ្រុនចាញ់នៅក្នុងប្រទេសកម្ពុជាពីខែមករាដល់ខែមិថុនា ឆ្នាំ២០២០នេះ។

ប្រភពដដែលបានឱ្យដឹងថា ជំងឺគ្រុនចាញ់ប្រភេទសន្ធំ (Plasmodium falciparum-Pf) មានចំនួន៣៨១ករណី ដែលធៀបនឹងឆ្នាំ២០១៩មានការថយចុះ៨០ភាគរយដែលមាន១៩២០ករណី។ ស្ថានភាពជំងឺគ្រុនចាញ់ឆ្នាំ២០២០ ដែលកំពុងបានថយចុះនេះ ក៏មានរាយប៉ាយខ្ពស់តាមទីតាំងភូមិសាស្ត្រមួយចំនួនជាតំបន់មានព្រៃ-ភ្នំ ពិសេសនៅខេត្តកំពង់ស្ពឺ មណ្ឌលគិរី រតនគិរី ពោធិសាត់ និងខេត្តស្ទឹងត្រែង។

ក្រសួងសុខាភិបាលបានលើកឡើងថា៖ «ជាសន្និដ្ឋានសម្រាប់ខណៈពេលនេះ គឺប្រទេសកម្ពុជាបានសម្រេចនូវសមិទ្ធផលមួយក្នុងចំណោមពីររួចជាស្រេច គឺសូចនាករអត្រាស្លាប់ស្មើសូន្យតាំងពីឆ្នាំ២០១៨មកដល់បច្ចុប្បន្ន («បានន័យថាជោគជ័យ៣ឆ្នាំមុនគោលដៅគ្រោងទុក»)។

ក្រសួងបានបន្ថែមថា សមិទ្ធផលទីពីរ គឺសូចនាករអត្រាឈឺដោយគ្រុនចាញ់សន្ធំ (Pf) កំពុងស្ថិតនៅការគ្រប់គ្រងបានយ៉ាងល្អ( បានកាត់បន្ថយជាបន្ត បន្ទាប់) ដែលរំពឹងយ៉ាងមុតមាំថានឹងឈានទៅសម្រេចបានជោគជ័យតាមការគ្រោងទុក។

លោក ម៉ម ប៊ុនហេង រដ្ឋមន្ត្រីក្រសួងសុខាភិបាលបានលើកទឹកចិត្តនិងអំពាវនាវដល់ប្រជាជនគ្រប់រូបត្រូវបន្តចូលរួមអនុវត្តតាមវិធានការរបស់កម្មវិធីប្រយុទ្ធនឹងជំងឺគ្រុនចាញ់ដែលកំពុងបានប្រតិបត្តិការជាបន្តបន្ទាប់ឱ្យមានប្រសិទ្ធភាពខ្ពស់។

លោកបានថ្លែងថា៖ «កុំភ្លេចយកមុងជ្រលក់ថ្នាំទៅតាមពេលចូលព្រៃភ្នំ តំបន់ប្រឈមចម្លងជំងឺគ្រុនចាញ់ ត្រូវសំរាន្តក្នុងមុងជ្រលក់ថ្នាំជាប្រចាំ ពិសេសពេលព្រលប់និងយប់ ត្រូវស្វែងរកសេវាពិនិត្យ ព្យាបាលជំងឺគ្រុនចាញ់ដែលនៅជិតបំផុតដើម្បីពិគ្រោះជំងឺឬជោះឈាមរកមេរោគគ្រុនចាញ់នៅរាល់ពេលបន្ទាប់ពីបានចូលទៅតំបន់ប្រឈមចម្លងជំងឺគ្រុនចាញ់និងត្រូវទទួលការព្យាបាលត្រឹមត្រូវតាមការណែនាំរបស់ភ្នាក់ងារពិនិត្យ ព្យាបាលជំងឺគ្រុនចាញ់»។

ក្រសួងសុខាភិបាលនៅតែបន្តផ្តល់ជូនដោយមិនគិតថ្លៃទាំងមុងជ្រលក់ថ្នាំ ការធ្វើតេស្ត និងព្យាបាលជំងឺគ្រុនចាញ់៕







*អាកាសយានដ្ឋានអន្តរជាតិភ្នំពេញ។ រូបភាព៖ ស៊ីអេសស៊ី*

# រដ្ឋាភិបាលកម្ពុជាកែសម្រួលលក្ខខណ្ឌចំពោះការធ្វើដំណើររបស់ជនបរទេសមកកាន់កម្ពុជា

*អត្ថបទ៖ អមរិន្ទ ដានុត*

ដើម្បីផ្តល់ភាពងាយស្រួលដល់អ្នកដំណើរបរទេសដែលបានមកដល់ឬគ្រោងធ្វើដំណើរមកកាន់ប្រទេសកម្ពុជា រដ្ឋាភិបាលកម្ពុជាសម្រេចអនុវត្តយន្តការធានា (Sponsorship Mechanism) ដើម្បីជួយសម្រួលអ្នកដំណើរបរទេសដែលជាវិនិយោគិន-ធុរជនបុគ្គលិកក្រុមហ៊ុន អ្នកជំនាញការ កម្មករជំនាញ អ្នកបច្ចេកទេស និងក្រុមគ្រួសារ ដែលមានការធានាឬមានការអញ្ជើញ តែមិនមានការធានាឬមិនមានការអញ្ជើញ និងមិនមានការធានាឬអ្នកធ្វើដំណើរបរទេសទូទៅ។

ក្រសួងសុខាភិបាលបានចេញសេចក្តីជូនដំណឹងមួយនាដើមខែសីហា ឆ្នាំ២០២០នេះថា ចំពោះអ្នកដំណើរបរទេសដែលជាវិនិយោគិន-ធុរជន បុគ្គលិកក្រុមហ៊ុន អ្នកជំនាញការ កម្មករជំនាញអ្នកបច្ចេកទេស និងក្រុមគ្រួសារដែលទទួលបានការធានា ដោយមុនពេលធ្វើដំណើរមកដល់ប្រទេសកម្ពុជា អ្នកដំណើរបរទេសត្រូវមានឯកសារមួយចំនួនដូចជា វិញ្ញាបនបត្របញ្ជាក់សុខភាព ចេញដោយអាជ្ញាធរសុខាភិបាលដែលទទួលស្គាល់ដោយរដ្ឋាភិបាលប្រទេសសាមី, លិខិតបញ្ជាក់លើការធានាទូទាត់សងប្រាក់ដែលចេញនិងទទួលស្គាល់ដោយរាជរដ្ឋាភិបាលកម្ពុជា។

ប្រភពដដែលបានឱ្យដឹងថា ការធានានឹងត្រូវការរយៈពេលមួយថ្ងៃដើម្បីពិនិត្យនិងវាយតម្លៃដោយស្ថាប័នមានសមត្ថកិច្ច។ ក្នុងករណីដែលពិនិត្យឃើញថា ការធានានេះមានភាពត្រឹមត្រូវ រាជរដ្ឋាភិបាលនឹងចេញលិខិតបញ្ជាក់លើការធានាទូទាត់សងប្រាក់ដែលអ្នកដំណើរបរទេសអាចបោះពុម្ពបានសម្រាប់កាន់ភ្ជាប់មកជាមួយក្នុងការដាក់ពាក្យស្នើសុំទិដ្ឋាការនៅស្ថានទូតកម្ពុជាឬស្ថានកុងស៊ុលកម្ពុជា និងក្នុងការធ្វើដំណើរមកកាន់ប្រទេសកម្ពុជា។ ទិដ្ឋាការដែលមានសុពលភាពស្របច្បាប់ស្តីពីអន្តោប្រវេសន៍ដែលត្រូវបានផ្តល់ឱ្យពីសំណាក់ស្ថានទូតកម្ពុជាឬពីស្ថានទូតកុងស៊ុលកម្ពុជានៃប្រទេសសាមី។ លិខិតឬឯកសារបញ្ជាក់ពីការបានកក់បន្ទប់សណ្ឋាគារសម្រាប់ស្នាក់នៅដែលការកក់បន្ទប់សណ្ឋាគារនេះត្រូវធ្វើឱ្យបានយ៉ាងតិច៣ថ្ងៃមុនពេលចេញដំណើរ។



*លោកជំទាវ ឱ វណ្ណឌីន រដ្ឋលេខាធិការ និងជាអ្នកនាំពាក្យក្រសួងសុខាភិបាល។ រូបភាព៖ Freshnews*

នៅពេលមកដល់អាកាសយានដ្ឋានអន្តរជាតិនៃប្រទេសកម្ពុជា អ្នកដំណើរបរទេសត្រូវបង្ហាញទិដ្ឋាការដែលមានសុពលភាពនិងចេញដោយស្ថានទូតកម្ពុជាឬពីស្ថានកុងស៊ុលកម្ពុជានៃប្រទេសសាមុី វិញ្ញាបត្របញ្ជាក់សុខភាពចេញដោយអាជ្ញាធរសុខាភិបាលដែលទទួលស្គាល់ដោយរដ្ឋាភិបាលប្រទេសសាម៉ុបញ្ជាក់ថាគ្មានជំងឺកូវីដ១៩ ក្នុងរយៈ៧២ម៉ោងមុនពេលចេញដំណើរលិខិតបញ្ជាក់លើការធានាទូទាត់សងប្រាក់និងលិខិតឬឯកសារបញ្ជាក់ពីការបានកក់បន្ទប់សណ្ឋាគារ។

ក្រសួងសុខាភិបាលបានបញ្ជាក់ថា ក្នុងករណីដែលអ្នកដំណើរបរទេសតម្រូវឱ្យធ្វើចត្តាឡីស័កសម្រាប់រយៈពេល១៤ថ្ងៃ អ្នកធានាត្រូវទទួលរ៉ាប់រងលើរាល់ការចំណាយទាំងស្រុង។ ក្នុងករណីដែលអ្នកដំណើរបរទេសមានជំងឺកូវីដ១៩ ក្នុងអំឡុងពេលស្នាក់នៅក្នុងប្រទេសកម្ពុជា អ្នកធានាត្រូវតែទទួលរ៉ាប់រងលើរាល់ចំណាយសម្រាប់ការព្យាបាលអ្នកជំងឺរហូតជាសះស្បើយ និងត្រូវទូទាត់ជូនមន្ទីរពេទ្យរដ្ឋដែលអ្នកជំងឺកូវីដ១៩បានសម្រាកព្យាបាល។

ចំពោះអ្នកដំណើរបរទេសដែលជាវិនិយោគិន-ធុរជន បុគ្គលិកក្រុមហ៊ុន អ្នកជំនាញការ កម្មករជំនាញ អ្នកបច្ចេកទេស និងក្រុមគ្រួសារដែលមិនមានការធានាប៉ុន្តែត្រូវបានការអញ្ជើញ គឺមុនពេលធ្វើដំណើរមកដល់ប្រទេសកម្ពុជា ត្រូវមានវិញ្ញាបនបត្របញ្ជាក់សុខភាពចេញដោយអាជ្ញាធរសុខាភិបាល ដែលទទួលស្គាល់ដោយរដ្ឋាភិបាលសាម៉ុ បញ្ជាក់ថាគ្មានជំងឺកូវីដ១៩ ក្នុងរយៈពេល៧២ម៉ោងមុនពេលចេញដំណើរដែលលិខិតនេះត្រូវចេញនិងទទួលស្គាល់ដោយរាជរដ្ឋាភិបាលកម្ពុជា។

ក្រសួងបានបញ្ជាក់បន្ថែមថា ទិដ្ឋាការដែលមានសុពលភាពស្របតាមនីតិវិធីនៃច្បាប់ស្តីពីអន្តោប្រវេសន៍ ដែលត្រូវបានផ្តល់ឱ្យពីសំណាក់ស្ថានទូតកម្ពុជាឬពីស្ថានកុងស៊ុលកម្ពុជានៃប្រទេសសាម៉ុ, លិខិតបញ្ជាក់លើការទិញសេវាធានារ៉ាប់រងសុខភាពដែលតម្រូវឱ្យអ្នកធ្វើដំណើរបរទេសទិញសេវាធានារ៉ាប់រងសុខភាព សម្រាប់ព្យាបាលជំងឺកូវីដ១៩ក្នុងតម្លៃ៩០ដុល្លារអាមេរិកនិងមានរយៈពេលធានា២០ថ្ងៃ។

សម្រាប់អ្នកដំណើរបរទេសដែលជាវិនិយោគិន-ធុរជន បុគ្គលិកក្រុមហ៊ុន អ្នកជំនាញការ កម្មករជំនាញ អ្នកបច្ចេកទេស និងក្រុមគ្រួសារ ដែលមិនមានការធានានិងមិនត្រូវបានអញ្ជើញ គឺកម្ពុជានៅតែស្វាគមន៍ចំពោះការធ្វើដំណើរមកដល់របស់អ្នកដំណើរបរទេសទាំងនេះ ប៉ុន្តែពួកគេនឹងត្រូវអនុវត្តដូចអ្នកធ្វើដំណើរបរទេសទូទៅដទៃទៀតដូចជា អនុវត្តតាមសេចក្តីជូនដំណឹងរបស់ក្រសួងសុខាភិបាលដោយគិតថ្លៃសេវាធ្វើតេស្តរកមេរោគកូវីដ១៩ ការធ្វើចត្តាឡីស័កនិងការពិនិត្យព្យាបាលជំងឺកូវីដ១៩នៅមន្ទីរពេទ្យរដ្ឋដែលនៅអនុវត្តជាធរមាន។ ការដាក់ប្រាក់តម្កល់ចំនួន២០០០ដុល្លារអាមេរិក នៅពេលមកដល់អាកាសយានដ្ឋានអន្តរជាតិនៃប្រទេសកម្ពុជាដែលប្រាក់នេះនឹងត្រូវប្រើសម្រាប់ចំណាយលើថ្ងៃស្នាក់នៅក្នុងអំឡុងពេលរង់ចាំលទ្ធផលធ្វើតេស្តរកមេរោគកូវីឌ១៩ ថ្លៃធ្វើតេស្ត ថ្លៃដឹកជញ្ជូន និងការចំណាយអំឡុងពេលធ្វើចត្តាឡីស័ក។ ពួកគាត់ក៏តម្រូវឱ្យទិញសេវាធានារ៉ាប់រងសុខភាព សម្រាប់ព្យាបាលជំងឺកូវីដ១៩ក្នុងតម្លៃ៩០ដុល្លារអាមេរិកនិងរយៈពេលធានា២០ថ្ងៃ៕

# វប្បធម៌សិល្បៈនិងអក្សរសាស្ត្រខ្មែរនាពេលសព្វថ្ងៃកំពុងឈានទៅរកភាពបាត់បង់

*អត្ថបទ៖ ដាលីស*

បច្ចុប្បន្នយើងសង្កេតឃើញថា វប្បធម៌សិល្បៈកំណាព្យ និងអក្សរសាស្ត្រខ្មែរ កំពុងវិវត្តន៍ថយក្រោយឈានទៅរកភាពបាត់បង់។

យុវជនខ្មែរសម័យទំនើបមួយចំនួនកំពុងតែលង់ខ្លួនជាមួយនឹងវប្បធម៌សិល្បៈបរទេសដែលធ្វើឱ្យកេរ្តិ៍មរតកខ្មែរពីដូនតាសាបរលាបបន្តិចម្តងៗ ដោយសារតែការព្រងើយកន្តើយនិងមិនសូវមានការយកចិត្តទុកដាក់ពីសំណាក់របស់យុវជនខ្មែរ ដោយទុកឱ្យសម្បត្តិវប្បធម៌ទាំងនេះនៅឯកោ។

ជាក់ស្តែងតាមរយៈការប្រើប្រាស់បណ្តាញសង្គម យុវជនមួយចំនួនបានយកឧបករណ៍ទាំងនេះមកបង្ហាញកេរ្តិ៍ខ្មាស់ដូចជា ការថតរូបចេញគល់ភ្លៅ ចេញដើមទ្រូងរួចបង្ហោះលើបណ្តាញមួយនេះដើម្បីទទួលបានការចុចឡាយ៍ (Like) និងស៊ែរ (Share) ជាដើម និងមានយុវជនមួយចំនួនទៀតបានប្រើប្រាស់ពាក្យសម្តីមិនសមគួរដូចជា ការជេរប្រមាថគ្នាឬបង្កជាជំលោះនៅលើបណ្តាញសង្គមជាដើម។

លោកសាស្ត្រាចារ្យ យ៉ាន់ បូរិន បច្ចុប្បន្នជាទីប្រឹក្សានៃក្រសួងវប្បធម៌និងវិចិត្រសិល្បៈ បានផ្តល់បទសម្ភាសន៍ដល់ RVAkhmer កាលពីថ្ងៃទី៩ ខែកក្កដា ឆ្នាំ២០២០ ក្នុងកម្មវិធីសិក្ខាសាលាមួយស្តីពី «ទម្រង់សិល្បៈកំណាព្យខ្មែរ» នៅព្រះសហគមន៍កាតូលិកភ្នំពេញថ្មីថា មូលហេតុដែលវប្បធម៌សិល្បៈកាន់តែធ្លាក់ចុះខ្សោយទៅៗដោយសារគ្មានការចាប់អារម្មណ៍ពីយុវជនខ្មែរ ហើយអ្នកដែលមកសិក្សាមានតែព្រះសង្ឃ ចំណែកឯសិស្សានុសិស្សវិញមិនមានអ្នកចាប់អារម្មណ៍រៀននោះទេ។ ម្យ៉ាងវិញទៀតដូចជាផ្នែកខាងកំណាព្យវិញ លោកគ្រូអ្នកគ្រូ ឬសាស្ត្រាចារ្យមានតិចណាស់ដែលគាត់ចេះច្បាស់អំពីការសូត្រកំណាព្យ ដែលវាបង្កទៅជាភាពលំបាកដល់ការអប់រំបន្តទៅក្មេងៗជំនាន់ក្រោយ។



លោកសាស្ត្រាចារ្យ យ៉ាន់ បូរិន ទីប្រឹក្សានៃក្រសួងវប្បធម៌និងវិចិត្រសិល្បៈ។ *រូបភាព៖ សហការី*

លោកសាស្ត្រាចារ្យបន្តទៀតថា ដោយការព្រងើយកន្តើយរបស់យុវជននេះហើយ ទើបធ្វើឱ្យសិល្បៈវប្បធម៌ខ្មែរកាន់តែបាត់បង់ ព្រោះកម្លាំងយុវជននេះហើយដែលអាចថែរក្សាកេរ្តិ៍មរតកវប្បធម៌បុរាណនេះបាន តែបើគ្មានការមើលថែពីយុវជនទេ វប្បធម៌ខ្មែរនឹងសាបសូន្យទៅហើយ។

លោកសាស្ត្រាចារ្យ យ៉ាន់ បូរិន បានមានប្រសាសន៍ថា៖ «វប្បធម៌រលត់ជាតិរលាយ វប្បធម៌ពណ្ណរាយជាតិថ្កើនថ្កាន វប្បធម៌ពណ្ណរាយបាន ដោយពឹងលើកូនៗយុវជន និងប្រជាពលរដ្ឋកម្ពុជានាំគ្នាថែរក្សា»។

លោកបន្តថា បើប្រជាពលរដ្ឋខ្មែរមិនខំថែទេ គ្មានបរទេសណាគេមកថែទេ ម្យ៉ាងវិញទៀតសំរាប់បរទេសដែលមានវប្បធម៌ស្រដៀងនឹងរបស់ខ្មែរ ពួកគេបន់សុំឱ្យតែរបស់ខ្មែររលាយ ដើម្បីគេបានលើកជាតិសាសន៍គេឡើង។

លោកបានលើកជាឧទាហរណ៍ឡើងអំពីល្ខោនខោលដែលសព្វថ្ងៃកំពុងតែប្រទាញប្រទង់គ្នា ដោយសារតែប្រទេសជិតខាងមានទម្រង់ស្រដៀងៗគ្នាដូចនឹងប្រទេសខ្មែរដែរ តែគេចាញ់ដោយសារតែប្រទេសកម្ពុជាមានភស្តុតាងនៅលើសិលាចារិកជាក់ស្តែង។

លោកសាស្ត្រាចារ្យ យ៉ាន់ បូរិន បានអំពាវនាវដល់រាជរដ្ឋាភិបាលឱ្យយកចិត្តទុកដាក់ចំពោះបញ្ហានេះដោយសារ សព្វថ្ងៃសិល្បៈវប្បធម៌ខ្មែរកំពុងស្ថិតក្នុងភាពរងគ្រោះ ព្រោះទម្រង់វប្បធម៌បរទេសកំពុងតែជ្រៀតជ្រែក ជាពិសេស តាមរយៈប្រព័ន្ធបណ្តាញសង្គមចូលមកក្នុងខួរក្បាលយុវជនខ្មែរបានយ៉ាងងាយ ដូចជា ពាក្យពេជ្យផ្សេងៗនៅក្នុងរឿងភាគ ដែលវាធ្វើឱ្យការនិយាយស្តីរបស់យុវជនហាក់មានភាពគំរោះគំរើយ គ្មានសីលធម៌ និងគុណធម៌ បាត់បង់តម្លៃជាខ្មែរជាដើម។

លោកសាស្ត្រាចារ្យក៏បានទទូចសុំដល់យុវជនយុវនារីខ្មែរ នាពេលបច្ចុប្បន្ន ត្រូវខិតខំប្រឹងប្រែងរៀនសូត្រ និងស្រាវជ្រាវអំពីសិល្បៈវប្បធម៌ និងជាពិសេសអំពីសិល្បៈកំណាព្យ និងការតែងនិពន្ធដើម្បីកុំឱ្យមរតកទាំងនេះបាត់បង់នាពេលដ៏ខ្លីខាងមុខ៕

សូមចុចនៅទីនេះ

# វចនានុក្រមទស្សនវិជ្ជាត្រូវបានដាក់សម្ពោធបន្ទាប់ពីបកប្រែជាថ្មី

*អត្ថបទ៖ ដាលីស*

វិទ្យាស្ថានស្រាវជ្រាវសហជីវិនព្រះយេស៊ូ Magga (Jesuit Research Center) បានសម្ពោធវចនានុក្រមទស្សនវិជ្ជាដែលបានបកប្រែថ្មី ជាភាសាខ្មែរ នាព្រឹកថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០២០ កន្លងមកនេះ នៅក្នុងសហគមន៍ព្រាបសសង្កាត់ភ្នំពេញថ្មី។

ពិធីសម្ពោធនេះដឹកនាំដោយលោកបណ្ឌិត កាំង អ៊ីនហ៊្គីន ជាបូជាចារ្យកាតូលិក ក្រុមសហជីវិនព្រះយេស៊ូ និងជាប្រធានក្រុមបកប្រែនិងកែសម្រួលវចនានុក្រមនេះ ដោយមានភ្ញៀវដែលបានអញ្ជើញមកពីតំណាងសាសនានិងសាស្ត្រាចារ្យដែលមកពីសាកលវិទ្យាល័យភូមិន្ទភ្នំពេញផងដែរ។

កម្មវិធីត្រូវបានចាប់ផ្តើមដោយការស្នឹងស្នាធ លោកបូជាចារ្យ អ៊ីនហ្គីនបានស្វាគមន៍ភ្ញៀវកិត្តិយសទាំងអស់ដែលបានចូលរួម និងប្រកាសបង្ហាញអំពីសាវតានៃការរៀបចំក្រុមចងក្រងវចនានុក្រមនេះដោយចាប់ផ្តើមកាលពី១៥ ឆ្នាំមុនហើយត្រូវបានផ្អាកមួយរយៈទើបតែបង្កើតឡើងវិញនាឆ្នាំ២០១៥កន្លងទៅនេះ។ នៅក្នុងឱកាសនេះដែរ លោកអ៊ីនហ្គីន ក៏បានអំពាវនាវដល់ប្រជាពលរដ្ឋខ្មែរទាំងអស់ចេះផ្តល់តម្លៃដោយមិនចម្លងដើម្បីរក្សានូវកម្មសិទ្ធិបញ្ញារបស់អ្នកនិពន្ធ។

លោកបណ្ឌិត អ៊ុន លាង ជាសមាជិកនៃក្រុមស្រាវជ្រាវនេះមានប្រសាសន៍ថា៖ «សៀវភៅនេះមិនទាន់មានផលប៉ះពាល់ដល់សង្គមភ្លាមៗនោះទេ ក៏ប៉ុន្តែនៅពេល៣០ឆ្នាំទៅមុខទៀតសៀវភៅនេះនឹងក្លាយទៅជាមូលដ្ឋានគ្រឹះដល់ជំនាន់ក្រោយក្នុងការបណ្តុះគំនិតបញ្ញវន្ត»។

លោកបានបន្ថែមថា នៅពេលជជែកគ្នាដោយប្រើភាសាបរទេសផ្សេងពីកន្លែងដែលយើងរស់នៅនាំឱ្យមានការឃ្លាតចាកឆ្ងាយពីអត្ថន័យដើម ហើយនៅក្នុងសៀវភៅនេះមានពាក្យខ្លះថ្មីនៅក្នុងសង្គមយើងដែលខ្ចីពីខាងសាសនានានា ទាំងគ្រីស្តសាសនានិងពុទ្ធសាសនាផងដែរ។ ដូច្នេះ វត្តមាននៃសៀវភៅនេះគួរតែផ្សារភ្ជាប់នៅក្នុងទិដ្ឋភាពសង្គមបច្ចុប្បន្ន។



លោកបណ្ឌិត កាំង អ៊ីនហ្គីន (អាវខ្មៅ) និងតំណាងសាសនានិងសាស្ត្រាចារ្យដែលមកពីសាកលវិទ្យាល័យភូមិន្ទភ្នំពេញ។ *រូបភាព៖ ស៊ីអេសស៊ី*

សម្តេចមហាអរិយវង្ស បណ្ឌិត យី សុវណ្ណរតនា ព្រះសាកលវិទ្យាធិការនៃពុទ្ធិកសាកលវិទ្យាល័យព្រះសីហនុរាជ មានថេរដីកាដោយចាប់អារម្មណ៍លើវិទ្យាស្ថានប្រើពាក្យ Magga «មាគ៌ា»។

សម្តេចបន្ថែមថា ការបោះពុម្ពផ្សព្វផ្សាយនេះបានផ្តល់អត្ថប្រយោជន៍ចំពោះសង្គមខ្មែរដូចជា៖ ធ្វើឱ្យអក្សរសិល្ប៍ខ្មែរកាន់តែសម្បូរបែប ហើយសង្ឃឹមថានឹងកាន់តែឈានទៅមុខបន្ថែមទៀត។ ការបកប្រែជាភាសាខ្មែរនិងការបញ្ចូលគំនិតទាំងនោះ គឺធ្វើឱ្យគំនិតទាំងឡាយដែលមាននៅក្នុងសៀវភៅភាសាបរទេសនឹងជួយកូនខ្មែរគិតនៅក្នុងភាសាខ្លួន ព្រមទាំងអាចពង្រីកនៃការគិតខាងផ្នែកទស្សនវិជ្ជានិងអាចបំប្លែងទៅជាគំនិតរបស់ខ្លួន។ ព្រះតេជគុណបញ្ជាក់ទៀតថា សំខាន់ណាស់ដែលយើងត្រូវប្រមូលធនធានចូលគ្នានៅក្នុងសង្គមមួយដែលផ្តោតលើចំណេះដឹងនិងបណ្តាញនានា។



វចនានុក្រមទស្សនវិជ្ជាអក្សហ្វ័ដ (Oxfor Dictionary of Philosophy) ជាសៀវភៅដែលលក់ដាច់ណាស់ដូច្នេះហើយទើបជាស្ថានសម្រេចបកប្រែវចនានុក្រមនេះជាភាសាខ្មែរ។ វចនានុក្រមនេះដាក់បញ្ចូលការសិក្សាគ្រប់ផ្នែកនៃទស្សនវិជ្ជាចាប់ពីអារីស្តូថេល្លេស ដល់និកាយហ្សេននៃពុទ្ធសាសនា រួមទាំងប្រវត្តិទស្សនវិទូល្បីៗជាង ៤០០ នាក់ ហើយព្រមទាំងមានការវិភាគយ៉ាងជ្រាលជ្រៅអំពីស័ព្ទ និងបញ្ញត្តិទស្សនៈវិជ្ជាផ្សេងៗ។ អ្នកសិក្សាទស្សនវិជ្ជាទាំងឡាយក៏ឱ្យប្រើប្រាស់វចនានុក្រមនេះជាមូលដ្ឋានក្នុងការសិក្សា ការបង្រៀន ការស្រាវជ្រាវ និងឯកសារយោងផងដែរ។

Magga (Jesuit Research Center) បានមកពីភាសាបាលីដែលមានន័យថា "មាគ៌ា" ដែលសំដៅទៅផ្លូវដ៏ជ្រាលជ្រៅនៃទស្សនវិជ្ជានិងសាសនាអាស៊ី ហើយក៏ជាការធ្វើដំណើររួមគ្នាឈានឆ្ពោះទៅកសាងសង្គមមួយដែលពោរពេញដោយយុត្តិធម៌សន្តិភាពនិងសេចក្តីពិត។ វិទ្យាស្ថាន Magga ជាផ្នែកមួយនៃអង្គការជេស៊ូតសឺវិសកម្ពុជា (Jesuit Service Cambodia)។ វិទ្យាស្ថានគាំទ្រការអប់រំជាន់ខ្ពស់នៅក្នុងសង្គមខ្មែរជាពិសេសលើផ្នែកមនុស្សសាស្ត្រទស្សនវិជ្ជានិងសាសនាតាមរយៈឧបទេសសិក្ខាសាលាការផ្តល់អាហារូបករណ៍ការឧបត្ថម្ភថវិកានិងការបោះពុម្ពផ្សាយ។ ក្រៅពីការបោះពុម្ពវចនានុក្រមនេះវិទ្យាស្ថានមានគម្រោងក្នុងការបន្តស្រាវជ្រាវ និងបោះពុម្ពស្នាដៃទស្សនវិជ្ជានិងសាសនាជាច្រើនទៀតដើម្បីជាជំនួយដល់អ្នកសិក្សាស្រាវជ្រាវក្នុងសង្គមបញ្ញវន្តខ្មែរ៕

សូមចុចនៅទីនេះ





# ប្រគំតន្ត្រីមនុស្សធម៌សម្រាប់មណ្ឌលកុមារមានពិការភាព




ក្រុមតន្ត្រីករអ្នករបាំបុរាណខ្មែរនិងអ្នកចំរៀងបស្ចិមប្រទេសក្នុងការប្រគំតន្ត្រីសប្បុរសធម៌។ *រូបភាព៖ សហការី*

*អត្ថបទ៖ ដាលីស*

នៅល្ងាចថ្ងៃព្រហស្បតិ៍ទី៣០ ខែកក្កដា ក្រុមតន្ត្រីករអ្នករបាំបុរាណខ្មែរនិងអ្នកចំរៀងបស្ចិមប្រទេសបានប្រគំតន្ត្រីសប្បុរសធម៌នៅរាជធានីភ្នំពេញ។

លោកស្រី មីវ៉ាកូកូហ្វូជីវ៉ា (Miwako Fujiwara) បានរៀបចំព្រឹត្តិការណ៍នេះដើម្បីរកប្រាក់ចំណូលសម្រាប់ «ផ្ទះពន្លឺនៃមេត្តា» នៅបឹងទំពុន។

ព្រឹត្តិការណ៍នេះប្រារព្ធឡើងនៅសណ្ឋាគារសូហ្វីតែល ភោគីត្រា។ ដោយសារតែមានមេរោគកូវីដ មានតែ ៣០ នាក់ប៉ុណ្ណោះដែលត្រូវបានអនុញ្ញាតឱ្យចូលរួមក្នុងព្រឹត្តិការណ៍នេះ។

ព្រះអង្គម្ចាស់តេសសូស៊ីសុវត្ថិបានផ្តល់កិត្តិយសចូលរួមក្នុងការប្រគុំតន្ត្រីនេះ។ ការប្រគំតន្ត្រីនេះ រៀបចំឡើងក្រោមប្រធានបទការប្រគំតន្ត្រីគឺសន្តិភាព ដោយមានការគាំទ្រពីស្ថានទូតជប៉ុនផងដែរ។

កម្មវិធីនេះមានទាំងតន្ត្រីបុរាណនិងតន្ត្រីសម័យ។ បទ "តេដើម" (Te Deum, ជាភាសាឡាតាំង មានន័យថា យើងសរសើរព្រះជាម្ចាស់) របស់អ្នកនិពន្ធ ម៉ូហ្សាត (Mozart) ច្រៀងដើម្បីអរព្រះគុណព្រះជាម្ចាស់ ដែលបានការពារ ព្រះរាជាណាចក្រកម្ពុជា ក្នុងអំឡុងពេលមានវិបត្តិនេះ។

របាំសត្វព្រាប គឺជាសញ្ញានៃសន្តិភាពសម្រាប់ពិភពលោក។ ការប្រគំតន្ត្រីនេះមានបរិយាកាសស្ងប់ស្ងាត់ល្អ និងមានភាពសុខដុមរមនាផងដែរ។ អ្នកលេងឧបករណ៍ភ្លេងបុរាណខ្មែរ ចូលរួមជាមួយ ក្រុមតន្ត្រីករជនជាតិខ្មែរ លេងឧបករណ៍បស្ចិមប្រទេសនិងក្រុមតន្ត្រីមញ្ញូស៊ីកា ហ្វិលីស (Musica Felice)។ ក្រុមតន្ត្រី Musica Felice គឺជាក្រុមចម្រៀង ពាក់កណ្តាលអាជីព ដែលតែងតែរៀបចំការប្រគំតន្ត្រីសប្បុរសធម៌ នៅក្នុងរាជធានីភ្នំពេញ។

ថវិកាដែលទទួលបានពីការប្រគំតន្ត្រីនេះត្រូវបានផ្តល់ជូន ដើម្បីគាំទ្រដល់ «ផ្ទះពន្លឺនៃមេត្តា»។ ក្រុមបងស្រីឧបការគុណបានបង្កើតផ្ទះនេះឡើង ដើម្បីផ្តល់កន្លែងស្នាក់នៅ និងការអប់រំដល់កុមារដែលមានបញ្ហាគថ្លង់ឬពិការភ្នែក។

ក្រុមបងស្រីឧបការគុណ ថ្លែងអំណរគុណដល់សប្បុរសជនខ្មែរដែលបានជួយមណ្ឌលនេះ ដើម្បីបន្តបេសកកម្មរបស់ខ្លួន ក្នុងអំឡុងពេលមានវិបត្តិ។ ការប្រគំតន្ត្រីនេះ បានបង្ហាញថា ទោះបីមានវិបត្តិសេដ្ឋកិច្ចក៏ដោយ ក៏មនុស្សជាច្រើននៅតែមានចិត្តសប្បុរស និងត្រៀមខ្លួនជួយដល់អ្នកដែលខ្វះខាត។

លោកបូជាចារ្យ វីល ខំហ្គើ (Will Conquer) បាននិយាយថា "ព្រះជាម្ចាស់របស់យើង គឺជាព្រះដែលផ្គត់ផ្គង់ សូម្បីតែពេលមានវិបត្តិក៏ដោយ។ យើងគួរអរព្រះគុណព្រះអង្គគ្រប់កាលៈទេសៈ។ យើងគួរតែរៀនស្រឡាញ់អ្នកដទៃ ដូចទ្រង់បានស្រឡាញ់យើងដែរ"៕

# មណ្ឌលអប់រំជំនឿកាតូលិកកម្ពុជាបង្កើតសិក្ខាសាលាស្តីអំពីទម្រង់សិល្បៈកំណាព្យខ្មែរជាលើកដំបូង

*អត្ថបទ៖ ដាលីស*

មណ្ឌលអប់រំជំនឿកាតូលិកកម្ពុជា បានបង្កើតសិក្ខាសាលាស្តីអំពី "ទម្រង់សិល្បៈកំណាព្យខ្មែរ" ជាលើកដំបូង នាថ្ងៃទី៩ ខែកក្កដា ឆ្នាំ២០២០ ដែលដឹកនាំដោយលោកប្រ៊ុយណូ កូសម៍ អភិបាលទទួលបន្ទុកមណ្ឌលអប់រំជំនឿកាតូលិកកម្ពុជា។ សិក្ខាសាលានេះមានសិក្ខាកាមមកពីភូមិភាគភ្នំពេញ និងកំពង់ចាមចូលរួមចំនួន២០នាក់ ដោយមានលោកយ៉ាន់ បូរិន្ទ ដែលជាសាស្ត្រាចារ្យ និងជាទីប្រឹក្សានៃក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ រួមជាមួយលោក សីហា ឧត្តម ជាគ្រូបង្គោលនៃក្លិបអភិរក្សមរតកកំណាព្យខ្មែរ និងជានាយកសាលាអភិរក្សមរតកសិល្បៈបូរាណខ្មែរ ជាវ៉ាគ្និន។

ក្នុងឱកាសនេះដែរ លោកអភិបាល ប្រ៊ុយណូ បានមានប្រសាសន៍ថា សិល្បៈទាំងអស់សុទ្ធតែជាមធ្យោបាយដែលយើងគួរប្រើដើម្បីសម្តែងពីជំនឿរបស់យើង។ លោកអភិបាលបញ្ជាក់ទៀតថា សិល្បៈទាំងអស់ដែលយើងប្រើជាប្រចាំថ្ងៃ ដើម្បីបង្ហាញពីសោភណ្ឌភាពឱ្យគេចាប់អារម្មណ៍ ហើយយើងចង់ផ្តល់សាក្សីភាពអំពីជំនឿរបស់យើង និងអ្វីដែលទាក់ទងនឹងព្រះជាម្ចាស់។ លោកបន្តថា «ជាពិសេស ថ្ងៃនេះយើងបានធ្វើសិក្ខាសាលាជាលើកទីមួយតែមួយព្រឹកអំពីកំណាព្យ អំពីទំនុកតម្កើង ព្រោះនៅពេលយើងអានព្រះគម្ពីរមិនសូវពិបាកទេ តែរបៀបសូត្រមិនសូវស្រួលទេ គឺមានន័យថាអ្វីៗទាំងអស់ដែលយើងចង់សម្តែងពីព្រះបន្ទូលរបស់ព្រះជាម្ចាស់តាមរយៈវប្បធម៌ខ្មែរ នោះអាចនាំឱ្យប្រជាជនខ្មែរអាចយល់បាន ដោយសារវប្បធម៌និងសិល្បៈចូលជ្រៅក្នុងចិត្តរបស់មនុស្ស»។



លោកអភិបាល ប្រ៊ុយណូ និងសិក្ខាកាមមកពីភូមិភាគភ្នំពេញ និងកំពង់ចាម។ *រូបភាព៖ ស៊ីអេសស៊ី*

លោកសាស្ត្រាចារ្យ បូរិន្ទ បានមានប្រសាសន៍ដោយស្ងើចសរសើរព្រះសហគមន៍កាតូលិកដែលបង្កើតសិក្ខាសាលានេះឡើង ដោយបានលើកយកពីបែបបទនៃការសូត្រ និងនិពន្ធកំណាព្យខ្មែរ ដើម្បីយកទៅប្រើប្រាស់នៅក្នុងលក្ខណៈខ្មែរ។ លោកបន្តថា នេះក៏ជាការផ្សព្វផ្សាយដើម្បីជួយជំរុញផ្នែកផ្លូវចិត្តនិងផ្លូវកាយរបស់អ្នកស្តាប់ឱ្យកើតមាននូវការគោរពការស្រឡាញ់ ជាពិសេស គឺការដឹងគុណចំពោះព្រះជាម្ចាស់ដែលបានផ្តល់នូវអ្វីៗល្អៗសម្រាប់អប់រំដល់បងប្អូនជាភាសាខ្មែរ។

លោកបន្ថែមថា៖ «ព្រឹកនេះខ្ញុំបានបង្ហាញឱ្យស្តាប់តាមបែបបទនៃការសូត្រកំណាព្យបានតាមទម្រង់បទផ្សេងៗ និងមានបងប្អូនបានសួរខ្ញុំថា តើទម្រង់ណាមួយដែលយើងអាចយកប្រើបាននៅក្នុងកម្មវិធីអាពាហ៍ពិពាហ៍ និងកម្មវិធីអប់រំផ្សេងៗ? តាមពិតនេះអាស្រ័យលើខ្លឹមសារ និងស៊ីសងលើដំណើរសូត្រ»។

យុវជន ឡឹម សម្បត្តិ ជាសមាជិកក្រុមចម្រៀងមកពីព្រះវិហារសន្តយ៉ូសែបផ្សារតូច បានឱ្យនិយាយថា «សិក្ខាសាលានេះពិតជាបានធ្វើឱ្យខ្ញុំមានចំណាប់អារម្មណ៍មែនទែនអំពីទំនាក់ទំនងរវាងព្រះសហគមន៍កាតូលិក និងប្រជាជន វប្បធម៌ខ្មែរ។ ហើយការអញ្ជើញសាស្ត្រាចារ្យ ដែលជាអធិរាជសូត្រកំណាព្យ ជាឱកាសដែលព្រះសហគមន៍អាចផ្សារភ្ជាប់ទៅនឹងវប្បធម៌ប្រពៃណី ដែលជាជំហានដែលនាំឱ្យយើងងាយស្រួលក្នុងការចែករំលែកជំនឿរបស់យើង តាមលក្ខណៈវប្បធម៌ប្រពៃណីខ្មែរ។ ជាពិសេស អាចជួយឱ្យប្រជាជនខ្មែរដែលមិនទាន់ក្លាយជាគ្រីស្តបរិស័ទ អាចឈ្វេងយល់ពីព្រះជាម្ចាស់តាមរយៈវប្បធម៌នេះ»។

សម្បត្តិបញ្ជាក់ថា សិក្ខាសាលានេះបានជួយដល់គាត់ឈ្វេងយល់បន្ថែមពីលក្ខណៈប្រពៃណីវប្បធម៌ និងចេះបែងចែកអ្វីជាសូត្រនិងការសូត្រ ជាពិសេស អាចដឹងពីរបៀបសូត្រតាមបទនីមួយៗ ដើម្បីយកទៅអនុវត្តនៅក្នុងព្រះសហគមន៍។

សិក្ខាសាលារយៈពេលមួយព្រឹកនេះ មានគ្រីស្តបរិស័ទចូលរួម ជាក្រុមចម្រៀង ក្រុមយុវជន ក្រុមគ្រូសារអប់រំជំនឿ នៅក្នុងព្រះសហគមន៍។ សិក្ខាសាលានេះបានលើកបង្ហាញពីទម្រង់សិល្បៈដែលមាននៅក្នុងវប្បធម៌ខ្មែរ របៀបសូត្រ និងសូត្រកំណាព្យ ព្រមទាំងរបៀបនិពន្ធកំណាព្យផងដែរ៕

សូមចុចនៅទីនេះ



# សមាគមព្រះគម្ពីរកម្ពុជាច្រានចោលការចោទប្រកាន់និងព្រមានចាត់វិធានការច្បាប់




សមាគមព្រះគម្ពីរកម្ពុជា គឺជាសមាជិកពេញអង្គមួយរូបរបស់សមាគមព្រះគម្ពីរសកលដែលមានសមាជិកចំនួន១៥០ ក្នុងចំណោម២០០ប្រទេស។ ថ្មីៗនេះ សមាគមព្រះគម្ពីរកម្ពុជាសង្កេតឃើញថា មានព័ត៌មាននិងការចែកផ្សាយជាច្រើននៅលើបណ្ដាញសង្គមហ្វេសប៊ុកដែលប៉ះពាល់ដល់កិត្តិយសសេចក្ដីថ្លៃថ្នូរ ភាពត្រឹមត្រូវ និងសិទ្ធិស្របច្បាប់របស់សមាគមព្រះគម្ពីរកម្ពុជាដែលទទួលស្គាល់ដោយរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ព្រមទាំងផ្ទុយពីគោលការណ៍សុខដុមនីយកម្មរបស់រាជរដ្ឋាភិបាលផងដែរ មិនតែប៉ុណ្ណោះក៏ជាសកម្មភាពមួយផ្ទុយពីវប្បធម៌និងក្រមសីលធម៌របស់គ្រីស្ដបរិស័ទថែមទៀតផង។

សមាគមព្រះគម្ពីរកម្ពុជាបានចេញសេចក្ដីប្រកាសព័ត៌មានមួយដើម្បីជម្រាបដល់សាធារណៈមតិទាំងអស់ឱ្យបានដឹងនិងយល់ឱ្យបានច្បាស់ថា សមាគមព្រះគម្ពីរកម្ពុជ គឺជាស្ថាប័នគ្រីស្ដបរិស័ទឯករាជ្យ បម្រើឱ្យផលប្រយោជន៍រួមសម្រាប់ទាំងអន្តរគណៈនិងអន្តរនិកាយ សមាគមព្រះគម្ពីរកម្ពុជា ជាស្ថាប័នគ្រីស្ដបរិស័ទដែលបាននឹងកំពុងបំពេញតួនាទីរបស់ខ្លួនដោយមិនលំអៀងទៅកាន់គណៈឬនិកាយណាមួយឡើយ ក្នុងការបកប្រែ ការបោះពុម្ព និងការចែកផ្សាយព្រះគម្ពីរជាភាសាជាតិខ្មែរទៅដល់បងប្អូនគ្រីស្ដបរិស័ទទូទៅ និងប្រជាពលរដ្ឋខ្មែរទាំងអស់នៅក្នុងប្រទេសកម្ពុជា ក៏ដូចជាអ្នកប្រើប្រាស់ព្រះគម្ពីរជាភាសាខ្មែរនៅទូទាំងពិភពលោកផងដែរ។

សេចក្ដីប្រកាសព័ត៌មានបានបន្តទៀតថា សមាគមព្រះគម្ពីរអង់គ្លេសបានបើកសាខារបស់ខ្លួនស្របច្បាប់នៅក្នុងប្រទេសកម្ពុជា ចាប់តាំងពីឆ្នាំ១៨៩២ ហើយបានបន្តបើកទីស្នាក់ការដើម្បីចែកចាយព្រះគម្ពីរគ្រីស្ដបរិស័ទដំបូងបំផុតនៅទីក្រុងភ្នំពេញក្នុងឆ្នាំ១៩៥៥។ ដោយសារសង្គ្រាមស៊ីវិលបានឆាបឆេះឡើង និងមានការផ្លាស់ប្ដូរប្រទេសកម្ពុជាទៅជារបបកម្ពុជាប្រជាធិបតេយ្យ ប្រល័យពូជសាសន៍ខ្មែរក្រហមចាប់ពីឆ្នាំ១៩៧៥មក សមាគមព្រះគម្ពីរកម្ពុជា បានផ្អាកដំណើរការរបស់ខ្លួនមួយរយៈពេលធំ។ រហូតមកដល់ឆ្នាំ១៩៩៣ សមាគមព្រះគម្ពីរកម្ពុជាបានចាប់ផ្ដើមដំណើរការឡើងវិញ ដោយស្របច្បាប់ដែលត្រូវបានទទួលស្គាល់ដោយក្រសួងធម្មការនិងសាសនានៃព្រះរាជាណាចក្រកម្ពុជា។

សមាគមព្រះគម្ពីរកម្ពុជា គឺជាសមាជិកពេញអង្គរបស់សមាគមព្រះគម្ពីរសកល។ ហេតុនេះរាល់ការបកប្រែព្រះគម្ពីរមកជាភាសាជាតិខ្មែរ ចាប់តាំងពីឆ្នាំ១៩២៣ រហូតមកដល់បច្ចុប្បន្ននេះ គឺសុទ្ធសឹងតែជាការផ្ដួចផ្ដើមចេញពីសមាគមព្រះគម្ពីរសកលដោយផ្ទីការសហការជាមួយសមាគមព្រះគម្ពីរប្រចាំនៅក្នុងប្រទេសកម្ពុជា ដើម្បីដំណើរការការបកប្រែព្រះគម្ពីរជាភាសាជាតិខ្មែរ។ ក្រុមការងារបកប្រែព្រះគម្ពីរគ្រីស្ដបរិស័ទ ពុំបានទទួលជំនួយឧបត្ថម្ភពីគណៈណាមួយឬពីនិកាយណាមួយ ឬពីបុរីវ៉ាទីកង់ ដូចមានការចោទប្រកាន់ដោយគ្មានមូលដ្ឋាន ភស្ដុតាងច្បាស់លាស់ ដែលបាននឹងកំពុងតែផ្សព្វផ្សាយនៅលើបណ្ដាញសង្គមហ្វេសប៊ុកនោះឡើយ។ រីឯអ្នកបកប្រែទៀតសោត ក៏ធ្វើឡើងដោយគោលការណ៍ស្ម័គ្រចិត្តទាំងស្រុង ដោយគ្មានទទួលបានប្រាក់ឧបត្ថម្ភពីសមាគមព្រះគម្ពីរកម្ពុជាឬពីសមាគមព្រះគម្ពីរសកលនោះឡើយ។

សេចក្ដីប្រកាសព័ត៌មានដដែលនេះបានលើកឡើងបន្ថែមទៀតថា រាល់ការបកប្រែព្រះគម្ពីរនីមួយៗដែលបានធ្វើឡើងនៅសមាគមព្រះគម្ពីរកម្ពុជាគឺសុទ្ធតែបានធ្វើការចុះបញ្ជីកម្មសិទ្ធិបញ្ញាស្របច្បាប់ត្រឹមត្រូវ ក្នុងនោះព្រះគម្ពីរបរិសុទ្ធឆ្នាំ១៩៥៤ ត្រូវបានចុះបញ្ជីដោយសមាគមព្រះគម្ពីរអង់គ្លេស រីឯព្រះគម្ពីរដ៏វិសុទ្ធឆ្នាំ២០០៥ ត្រូវបានចុះបញ្ជីដោយសមាគមព្រះគម្ពីរសកល។ រាល់សេចក្ដីថ្លែងការណ៍ដែលបញ្ជាក់អំពីកម្មសិទ្ធិបញ្ញាអន្តរជាតិ សុទ្ធតែត្រូវបានបោះពុម្ពនៅក្នុងទំព័រមុខនៃព្រះគម្ពីរទាំងអស់របស់សមាគមព្រះគម្ពីរកម្ពុជាចាប់តាំងពីខ្លួនដំណើរការ ការបោះពុម្ពមក។ មួយវិញទៀត សមាគមព្រះគម្ពីរកម្ពុជាមិនដែលមានផែនការផ្អាក ឬបញ្ឈប់ការបោះពុម្ពគម្ពីរបរិសុទ្ធ១៩៥៤ ដូចពាក្យចោទប្រកាន់របស់មនុស្សមួយក្រុមនោះទេ។ សមាគមព្រះគម្ពីរកម្ពុជា នៅតែបន្តបម្រើព្រះជាម្ចាស់តាមរយៈការបោះពុម្ពផ្សាយព្រះគម្ពីរជាភាសាខ្មែរទាំងពីរប្រភេទនេះតទៅមុខទៀត ស្របតាមតម្រូវការរបស់អ្នកជឿនៅព្រះរាជាណាចក្រកម្ពុជា។




សមាគមព្រះគម្ពីរកម្ពុជា សូមធ្វើការបដិសេធទាំងស្រុងនូវរាល់ព័ត៌មានទាំងឡាយណាដែលមានប្រភពមិនច្បាស់លាស់ ដែលបានលើកឡើងចោទប្រកាន់ដោយគ្មានមូលដ្ឋាន និងគ្មានភស្ដុតាងនៅលើបណ្ដាញសង្គមដែលផ្ទុយពីសេចក្ដីប្រកាសព័ត៌មាននេះ។

សមាគមព្រះគម្ពីរកម្ពុជាបានបញ្ជាក់បន្ថែមយ៉ាងច្បាស់ថា៖ «សមាគមសូមរក្សាសិទ្ធិរបស់ខ្លួនក្នុងការមិនឆ្លើយតបឬក៏ឆ្លើយតបទៅកាន់ព័ត៌មានទាំងឡាយណាដែលខ្លួនគិតថាគួរឬមិនគួរ។ សមាគមសូមធ្វើការបដិសេធនិងមិនចូលរួមដាច់ខាតនូវរាល់ទង្វើរឬសកម្មភាពអុជអាលទាំងឡាយណាដែលបង្កការបាក់បែក ការរើសអើងសាសនា ជម្លោះនិន្នាការនិកាយសាសនា ទាំងផ្ទៃក្នុងគ្រីស្ដបរិស័ទ ឬជាមួយនឹងសាសនានានានៅក្នុងព្រះរាជាណាចក្រកម្ពុជា ដែលអាចនាំមកនូវការបាត់បង់សណ្ដាប់ធ្នាប់ សេចក្ដីថ្លៃថ្នូរ និងព្រះកិត្តិនាមរបស់ព្រះអម្ចាស់យេស៊ូគ្រីស្ដ ក៏ដូចជាការបាត់បង់នូវសុខុដុមនីយកម្មសាសនា ដែលរាជរដ្ឋាភិបាលកម្ពុជាតែងតែយកចិត្តទុកដាក់ខ្ពស់នៅក្នុងសង្គមជាតិខ្មែរ ដោយបានផ្ដល់នូវសិទ្ធិសេរីភាពផ្នែកជំនឿសាសនាដល់ប្រជាពលរដ្ឋទូទៅ និងត្រូវបានធានាដោយរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា»។

សមាគមព្រះគម្ពីរកម្ពុជា រក្សាសិទ្ធិក្នុងការចាត់វិធានការផ្លូវច្បាប់ចំពោះរាល់ការចោទប្រកាន់ផ្ដេសផ្ដាស់ គ្មានភស្ដុតាង ឬប្រភពច្បាស់លាស់ជាមូលដ្ឋានពីសំណាក់ស្ថាប័ន ក្រុម ឬបុគ្គលដែលនាំឱ្យមានការរើសអើង ប៉ះពាល់ដល់កិត្តិយសមុខមាត់ និងពន្ធកិច្ចរបស់សមាគមព្រះគម្ពីរកម្ពុជា។

សមាគមស្នើឱ្យអស់លោកអ្នក បងប្អូន បន្តការអាននិងស្វែងយល់ពីព្រះបន្ទូលដ៏អស្ចារ្យរបស់ព្រះអង្គបន្តទៀត ដើម្បីឱ្យព្រះបន្ទូលរបស់ព្រះអង្គនៅតែមានសកម្មភាពនៅក្នុងដួងចិត្ត និងជីវិតរបស់លោកអ្នក។

## ប្រវត្តិនៃព្រះគម្ពីរជាភាសាខ្មែរ៖

សមាគមព្រះគម្ពីរអង់គ្លេស (British and Foreign Bible Society-BFBS) ដែលបានបើកទីស្នាក់ការស្របច្បាប់នៅប្រទេសកម្ពុជា បកប្រែព្រះគម្ពីរដំបូងគឺ «ដំណឹងល្អលូកា» ផ្សាយចេញនៅឆ្នាំ១៨៩៩។ នៅឆ្នាំ១៩២៣ សមាគមនេះបានបកប្រែព្រះគម្ពីរជាភាសាខ្មែរ ហើយបានបោះពុម្ពផ្សាយព្រះគម្ពីរសញ្ញាថ្មីនៅឆ្នាំ១៩២៩ បន្ទាប់មកបោះពុម្ពព្រះគម្ពីរទាំងមូល ឈ្មោះថា «ព្រះគម្ពីរបរិសុទ្ធ» នៅឆ្នាំ១៩៥៤។

នៅឆ្នាំ១៩៦៨ សមាគមព្រះគម្ពីរសកល (United Bible Society-UBS) បានរួមសហការជាមួយក្រុមជំនុំគ្រីស្ដបរិស័ទដំណឹងល្អខ្មែរ និងព្រះសហគមន៍កាតូលិកកម្ពុជា បកប្រែព្រះគម្ពីរជាលើកទី២ ដែលមានចំណងជើងថា «ព្រះគម្ពីរជាភាសាខ្មែរសម្រាយ»។ ដោយសារសង្គ្រាម ក្នុងប្រទេសកម្ពុជា ព្រះគម្ពីរនេះត្រូវបានបកប្រែចប់និងបោះពុម្ពក្នុងឆ្នាំ១៩៩៧។ ដោយមានសំណូមពរពីក្រុមជំនុំគណៈប្រូតេស្តង់ បានកែសម្រួលចំណងជើងមកជា «ព្រះគម្ពីរដ៏វិសុទ្ធ» ផ្សាយនៅក្នុងឆ្នាំ២០០៥។

សមាគមព្រះគម្ពីរសកល ដែលមានទីស្នាក់ការនៅប្រទេសអង់គ្លេស និងនៅសហរដ្ឋអាមេរិក បានប្រគល់សិទ្ធិគ្រប់គ្រងកម្មសិទ្ធបញ្ញាដល់សមាគមព្រះគម្ពីរកម្ពុជា ដែលជាសមាជិកពេញអង្គរបស់ខ្លួន ហើយមានតែសមាគមព្រះគម្ពីរកម្ពុជាតែមួយគត់ដែលមានសិទ្ធិបោះពុម្ពនិងចែកចាយព្រះគម្ពីរបរិសុទ្ធ និងព្រះគម្ពីរដ៏វិសុទ្ធ ដល់សហគមន៍គ្រីស្ដបរិស័ទគ្រប់គណៈនិកាយ ស្របតាមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា៕

សូមចុចនៅទីនេះ

# ដូនជីសារិន ថ្វាយពាក្យសច្ចានិរន្តរ៍

*អត្ថបទៈ កែវ កញ្ញា*

«នាងខ្ញុំបានសរសេរឯកសារនេះដោយដៃរបស់ខ្ញុំផ្ទាល់ ហើយខ្ញុំសូមចុះហត្ថលេខានៅលើអសនៈនេះ។ នៅពេលនេះ ជីវិតរបស់ខ្ញុំ ចូលរួមជារៀងរហូតជាមួយនឹងសក្ការបូជារបស់ព្រះគ្រីស្ត។ តាមរយៈព្រះបន្ទូលព្រះអង្គ សូមព្រះអង្គទទួលនាងខ្ញុំ ឱ្យខ្ញុំអាចរកឃើញជីវិតតែនៅក្នុងព្រះអង្គ»។



*ដូនជី ម៉ារីយ៉ា ដូមីនីកា ម៉ាស្សារេឡូ អេង សារិន ដែលបានថ្វាយពាក្យសច្ចានិរន្តរ៍។ រូបភាពៈ សហការី*

នេះជាសម្ដីរបស់ដូនជី ម៉ារីយ៉ា ដូមីនីកា ម៉ាស្សារេឡូ អេង សារិន ដែលបានថ្វាយពាក្យសច្ចានិរន្តរ៍ក្នុងក្រុមគ្រួសារបុត្រីព្រះនាងម៉ារីជាទីពំនឹងពំនាក់នៃសាលេស៊ានដុនបូស្កូ នាព្រឹកថ្ងៃទី០៥ ខែសីហា ឆ្នាំ២០២០កន្លងមកនេះ។

កម្មវិធីនេះបានធ្វើឡើងក្រោមអធិបតីភាពរបស់លោក ប្រ៊ុយណូ កូសម៍ ជាអភិបាលព្រះសហគមន៍កាតូលិកភូមិភាគកំពង់ចាម នៅសាលាវិទ្យាល័យដុនបូស្កូទឹកថ្លា នារាជធានីភ្នំពេញ។

ដោយសារតែកូវីដ១៩ ក្រុមដូនជីបានអញ្ជើញភ្ញៀវតិចតួចបំផុតចូលរួមក្នុងកម្មវិធីនេះ ដែលមានដូចជា លោកបូជាចារ្យ៩អង្គ បងស្រីប្រធានក្រុមគ្រួសារ និងសមាជិកនៃក្រុមគ្រួសារដូនជី រួមនឹងបងប្អូនសាច់ញាតិរបស់បងស្រីសារិន។

ក្នុងពិធីថ្វាយអភិបូជា ដើម្បីអរព្រះគុណព្រះជាម្ចាស់ លោកអភិបាល ប្រ៊ុយណូ កូសម៍ មានប្រសាសន៍ថា អ្វីដែលបងស្រីបានធ្វើក្នុងថ្ងៃនេះ គឺថ្វាយខ្លួនទាំងស្រុង។ ដូចនៅក្នុងអត្ថបទគម្ពីរ ព្រះយេស៊ូបានប្រាប់ដល់មនុស្សជាច្រើនថា ត្រូវថ្វាយខ្លួនដោយចេញពីចិត្ត គឺថ្វាយខ្លួនទាំងស្រុង ដែលជាជម្រើសអចិន្ត្រៃយ៍ មិនមែនតែម្ដង តែជារៀងរហូត។ លោកអភិបាលបានមានប្រសាសន៍ថាៈ «ជំនឿរបស់យើងគឺយើងថ្វាយខ្លួន ដើម្បីជួយអ្នកដទៃដែរ»។

លោកអភិបាលបញ្ជាក់បន្តថាៈ «អ្វីដែលយើងធ្វើគឺមិនមែនសម្រាប់ខ្លួនឯង តែគឺសម្រាប់អ្នកដទៃ ហើយអ្វីៗដែលយើងអាចធ្វើទៅបាន ដោយសារព្រះអង្គប្រទានកម្លាំងទាំងស្រុង ហើយកម្លាំងរបស់បងស្រី ក៏បានមកពីក្រុមគ្រួសារអ្នកបួសដែរ ដែលបានជួយគ្នាឱ្យទៅមុខ។ ដូច្នេះបងស្រីមិននៅម្នាក់ឯងទេ។



*កម្មវិធីថ្វាយពាក្យសច្ចានិរន្តរ៍ ស្ថិតក្រោមអធិបតីភាពរបស់លោក ប្រ៊ុយណូ កូសម៍ ជាអភិបាលព្រះសហគមន៍កាតូលិកភូមិភាគកំពង់ចាម នៅសាលាវិទ្យាល័យដុនបូស្កូទឹកថ្លា នារាជធានីភ្នំពេញ។ រូបភាពៈ សហការី*

ជាមួយគ្នានេះដែរ ដូនជីសារិន មានប្រសាសន៍ថា ក្នុងជីវិតជាអ្នកបួសរយៈពេល៧ឆ្នាំមកនេះ ជួបឧបសគ្គជាច្រើន ប៉ុន្តែអ្វីដែលអាចជំនះនូវរបាំងនេះ គឺការអធិដ្ឋាននិងទទួលស្គាល់សេចក្ដីស្រឡាញ់របស់ព្រះជាម្ចាស់ដ៏លើសលប់ចំពោះរូបគាត់ផ្ទាល់»។

ដូនជីសារិនបានថ្លែងថាៈ «ទោះបីជាឧបសគ្គហ្នឹងវាពិបាក មើលទៅដូចជាវាធ្ងន់ធ្ងរយ៉ាងណាក៏ដោយ ប៉ុន្តែវាអត់ធំជាងសេចក្ដីស្រឡាញ់របស់ព្រះជាម្ចាស់ដែលខ្ញុំទទួលបានទេ»។

ក្នុងបេសកកម្មជាដូនជីកាតូលិកនៅក្នុងក្រុមគ្រួសារសាលេស៊ានដុនបូស្កូ ដូនជីរូបនេះ បានខិតខំប្រើប្រាស់អំណោយទានដែលព្រះជាម្ចាស់ប្រទានមកចែកចាយដល់យុវជននិងកុមារនៅក្នុងសាលាតាមរយៈកិច្ចការបង្រៀន។

ក្រុមគ្រួសារបុត្រីព្រះនាងម៉ារី ជាទីពំនឹងពំនាក់ ជាក្រុមគ្រួសារមួយដែលផ្ដោតការយកចិត្តទុកដាក់លើផ្នែកអប់រំកុមារនិងយុវជន តាមស្មារតីផ្លូវវិញ្ញាណរបស់លោកបូជាចារ្យយ៉ូហានបូស្កូ និងអ្នកម្ដាយម៉ាហ្សារ៉េឡូ ដែលជាអ្នកបង្កើតក្រុមគ្រួសារដូនជីនេះ។

ដូនជីសារិន បានអំពាវនាវ ដល់យុវតីដែលមានបំណងចង់ចូលរួមបម្រើព្រះជាម្ចាស់ជាអ្នកបួសឱ្យមានចិត្តក្លាហានឆ្លើយតបនឹងការត្រាស់ហៅនេះ។

ដូនជីសារិនបានឱ្យដឹងថាៈ «ជីវិតនៅក្នុងការដើរតាមព្រះជាម្ចាស់មិនមែនស្រួល ក៏ប៉ុន្តែវាអស្ចារ្យ ព្រោះយើងបានជិតស្និទ្ធជាមួយព្រះជាម្ចាស់តាមរយៈអ្វីដែលយើងអាចធ្វើបាន... ហើយពេលនោះព្រះអង្គនឹងប្រទានពរឱ្យយើងក្លាយជាសន្តសន្តិនៅក្នុងអាថ៌កំបាំង ក្នុងព្រះហឫទ័យរបស់ព្រះជាម្ចាស់»។

អ្នកស្រី អ៊ុំ មុំ អាយុ៧៤ឆ្នាំ ជាម្ដាយរបស់ដូនជីសារិន បាននិយាយឱ្យដឹងថា កាលពីដំបូងគាត់មិនពេញចិត្តនឹងការសម្រេចចិត្តរបស់កូនស្រីទេ ប៉ុន្តែការលើកទឹកចិត្តពីស្វាមីបានធ្វើឱ្យអ្នកស្រីផ្លាស់ប្ដូរគំនិត។

អ្នកស្រីបញ្ជាក់អំពីអារម្មណ៍នៅពេលបច្ចុប្បន្នថាៈ «មានការត្រេកអរច្រើនណាស់ រាល់ថ្ងៃសប្បាយចិត្តហ្មង។ អត់មានតក់ស្លុត អត់មានថា កូនហៅមកអីចឹង មិនចង់មកមិនចង់អី អត់ទេ»។

ដូនជីម៉ារីយ៉ា ដូមីនីកា ម៉ាស្សារេឡូ អេង សារិន កើតនៅថ្ងៃទី៧ ខែកញ្ញា ឆ្នាំ១៩៨១ នៅ អូរបែកក្អម សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ រាជធានីភ្នំពេញ ដែលមានគ្រួសារជាពុទ្ធបរិស័ទ។ បងស្រីជាកូនទី៤ ក្នុងចំណោមបងប្អូនប្រុសស្រីចំនួន៧នាក់។

ក្នុងឆ្នាំ២០០២បងស្រីសារិនបានបញ្ចប់ការសិក្សានៅសាលាដុនបូស្កូផ្នែកនារី លើជំនាញវិជ្ជាមេផ្ទះនិងសណ្ឋាគារ ហើយបានធ្វើការងារមួយរយៈជាមួយក្រុមគ្រួសារបុត្រីព្រះនាងម៉ារីជាទីពំនឹងពំនាក់។ ក្រោយមកបងស្រីចាប់ផ្ដើមឈ្វេងយល់បន្ថែមអំពីជីវិតនៃការត្រាស់ហៅ ហើយបានសម្រេចចិត្តសាកល្បងក្នុងឆ្នាំ២០០៧ និងបានបន្តការសិក្សាជាដូនជីនៅប្រទេសហ្វីលីពីន។

នៅថ្ងៃទី៥ ខែសីហា ឆ្នាំ២០១៣ បងស្រី អេង សារិនបានថ្វាយពាក្យសច្ចាលើកដំបូងក្នុងក្រុមគ្រួសារបុត្រីព្រះនាងម៉ារីជាទីពំនឹងពំនាក់នៃសាលេស៊ានដុនបូស្កូ។ ក្រុមគ្រួសារដូនជីនេះ បច្ចុប្បន្នមានសមាជិកខ្មែរចំនួន៨នាក់៕



*ដូនជី ម៉ារីយ៉ា ដូមីនីកា ម៉ាស្សារេឡូ អេង សារិន។ រូបភាពៈ សហការី*





# លោកវីល ខ័រហ្គើ «ខ្ញុំចង់ទៅប្រកាសដំណឹងល្អដល់អ្នកក្រីក្រ»

*អត្ថបទៈ កែវ កញ្ញា*










លោកបូជាចារ្យវីល ខ័រហ្គើ កំពុងសិក្សាភាសាខ្មែរ បច្ចុប្បន្នលោកស្នាក់នៅក្នុងព្រះវិហារព្រះកុមារយេស៊ូបឹងទំពុន និងជារៀងរាល់ថ្ងៃអាទិត្យលោកថ្វាយពិធីអភិបូជានៅផ្ទះបងស្រីមេត្តាករុណានៅចោមចៅក្នុងរាជធានីភ្នំពេញ។

ក្នុងអំឡុងពេលកូវីដ១៩ លោកបានស្នាក់នៅជាមួយក្រុមបងស្រីមេត្តាករុណាមួយរយៈ ដែលក្នុងឱកាសនោះ លោកមានពេលវេលាច្រើនរៀននិយាយភាសាខ្មែរជាមួយអ្នកជំងឺដែលកំពុងស្នាក់នៅក្នុងមណ្ឌល។

និយាយភាសាខ្មែរមិនសូវច្បាស់និងមួយៗ លោកបូជាចារ្យរូបនេះ មានប្រសាសន៍ថា «ខ្ញុំចូលចិត្តក្រុមបងស្រីមេត្តាករុណា»។

លោកបានបន្ថែមថា លោករកឃើញ ជីវិតនៃការត្រាស់ហៅជាបូជាចារ្យ ដោយសារសក្ខីកម្មរបស់ក្រុមបងស្រីនិងបងប្រុសមេត្តាករុណានេះនៅប្រទេសឥណ្ឌា។ លោកបូជាចារ្យវីល «ខ្ញុំមានឱកាសបានទៅប្រទេសឥណ្ឌាជាមួយមិត្តភក្តិខ្ញុំ។ យើងទៅកាល់គូតា។ មនុស្សក្រច្រើន។ ខ្ញុំសួរខ្លួនឯង ហេតុអីព្រះជាម្ចាស់ធ្វើឱ្យមានអ្នកក្រ?»

លោកបូជាចារ្យបញ្ជាក់ថា «ក្រោយមកខ្ញុំយល់ថា ព្រះជាម្ចាស់ចង់ឱ្យយើងបង្ហាញមេត្តាករុណារបស់ព្រះអង្គដល់ពួកគេ»។

បន្ទាប់ពីបញ្ចប់វិស្សមកាលនៅប្រទេសឥណ្ឌា លោកវីលជាជនជាតិបារាំងកាត់អាមេរិកមានចិត្តចង់ប្រកាសដំណឹងល្អដល់មនុស្សដែលមិនស្គាល់ព្រះជាម្ចាស់។ លោកបានស្វែងរកក្នុងវេបសាយ ដើម្បីធ្វើជាសាសនទូត។ លោកវីល «ខ្ញុំអត់ស្គាល់នរណាជាសាសនទូត ខ្ញុំចង់ទៅប្រកាសដំណឹងល្អដល់អ្នកក្រីក្រ។ ខ្ញុំរកក្នុងអ៊ីនធឺណេត ឃើញក្រុមសាសនទូតទីក្រុងប៉ារីស។ ខ្ញុំប្រាប់ឪពុកខ្ញុំ ខ្ញុំចង់បួស»។

ចំណូលចិត្តនៃផ្លូវជីវិតថ្មីរបស់លោកបានធ្វើឱ្យក្រុមគ្រួសាររបស់លោកឆ្ងល់យ៉ាងខ្លាំងនិងជំទាស់ពីឪពុកផង។ លោកវីល «ឪពុកខ្ញុំសួរថា កូនអត់ពេញចិត្តគ្រួសារ មានជីវិតដូចយើង? គាត់សួរដោយសារខ្ញុំមានមិត្តភក្តិច្រើន មានសង្សារ មានការងារល្អ...»។

តែទោះបីជាយ៉ាងណា ក្នុងលោកជាប់ចិត្តនឹងជីវិតសាសនទូត និងចង់បម្រើព្រះជាម្ចាស់ក្នុងជីវិតថ្មីនេះ។ លោក វីល ខ័រហ្គើ អាយុ៣០ឆ្នាំ ត្រូវបានតែងតាំងជាបូជាចារ្យកាតូលិកនាថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០១៨ នៅប្រទេសបារាំងក្នុងក្រុមសាសនទូតនាទីក្រុងប៉ារីស (MEP)។ ឪពុកម្ដាយរបស់លោកមានកូនៗចំនួន៦នាក់ ដែលរូបលោកជាកូនទី៣។ លោកបូជាចារ្យរូបនេះបញ្ជាក់ថា បងប្រុសច្បងរបស់លោកក៏កំពុងសិក្សានៅទេវវិទ្យាល័យដើម្បីក្លាយជាបូជាចារ្យកាតូលិកផងដែរ។

លោកវីលបានធ្វើដំណើរតាមរថភ្លើងពីប្រទេសបារាំងមកកាន់កម្ពុជាដោយឆ្លងកាត់ប្រទេសជាច្រើនដោយចំណាយពេល១ខែ បន្ទាប់ពីក្លាយជាបូជាចារ្យ។ លោក បានមកដល់ប្រទេសកម្ពុជាជិត១ឆ្នាំមកហើយ។ លោកកំពុងសិក្សាភាសាខ្មែរ ឈ្វេងយល់អំពីវប្បធម៌និងអរិយធម៌ខ្មែរ និងជីវិតរស់នៅរបស់ប្រជាជន។ លោកក៏ចូលចិត្តឈ្វេងយល់អំពីជំនឿសាសនានានា និងចូលចិត្តប្រគំឧបករណ៍តន្ត្រីផងដែរ។

ចាប់តាំងពីលោកវីល បានតែងតាំងជាបូជាចារ្យកាតូលិក លោកតែងស្លៀកសំលៀកបំពាក់ អាវបំពង់វែងដែលភាសាអង់គ្លេសហៅថា Clerical Cloth ដែលមាន២ពណ៌ គឺខ្មៅនិងស។ «ខ្ញុំមានអាវបីអាវមួយពណ៌សនិងខ្មៅ២។ រាល់ថ្ងៃខ្ញុំត្រូវបោកអាវស្តើងរបស់ខ្ញុំដូចមនុស្សទាំងអស់។» លោកបូជាចារ្យបញ្ជាក់។

លោកបន្តថា «អាវបំពង់នេះ គឺជានិមិត្តរូបរលឹកអំពីឈើឆ្កាងរបស់ព្រះគ្រីស្ត។»

ជាទូទៅសម្លៀកបំពាក់នេះ គេឃើញមានតែបូជាចារ្យមួយចំនួនតូចនៅអឺរ៉ុប ឬបស្ចិមប្រទេសទេដែលប្រើប្រាស់វា។ នៅក្នុងប្រទេសកម្ពុជា លោកបូជាចារ្យបានប្រើប្រាស់វាមុនសម័យសង្គ្រាមស៊ីវិល។

លោកបូជាចារ្យវីលបានបញ្ជាក់អំពីបេសកកម្មជាសាសនទូតរបស់លោកនៅប្រទេសកម្ពុជាយ៉ាងនេះថា «ខ្ញុំជាក្មេងក្នុង (ចំណោម) អ្នកបួស។ ដូច្នេះខ្ញុំត្រូវរៀនច្រើនផងដែរ។ ទើបតែចាប់ផ្ដើមបេសកកម្មនៅប្រទេសខ្មែរ ដូច្នេះខ្ញុំត្រូវរៀនរឿងច្រើន ដើម្បីយល់ប្រទេសខ្មែរច្បាស់ជាងមុន ដើម្បីយល់ប្រជាជនខ្មែរផងដែរ។ ដើម្បីយល់នៅក្នុងប្រទសនេះ ព្រះអង្គចង់ធ្វើអ្វី។ នៅក្នុងប្រទេសនេះ ព្រះគ្រីស្តស្រឡាញ់មនុស្សទាំងអស់យ៉ាង(ដូច)ម្ដេច? ហើយខ្ញុំសង្ឃឹមថា ខ្ញុំនឹងរកមធ្យោបាយថ្មីៗដើម្បីប្រកាសដំណឹងល្អនៅក្នុងប្រទសនេះ»៕

## សូមអរព្រះគុណព្រះជាម្ចាស់ដែលបានប្រទានលោកបូជាចារ្យ យ៉ូហាន អាស្លី អ៊ីវ៉ាន់ Ashley Evans ដែលបានបំពេញបេសកកម្មនៅកម្ពុជាតាំងពីឆ្នាំ១៩៩៣។ ពេលនេះលោកបានធ្វើមាតុភូមិនិវត្តន៍ទៅប្រទេសអៀកឡង់វិញ។











## ជូនដំណើរគ្រូខ្មែរ សូ សុភីន នៃក្រុមគ្រួសារឧបការគុណបានអញ្ជើញទៅកាន់ប្រទេសបារាំង។



## សូមស្វាគមន៍លោកបូជាចារ្យ សែសាត និងលោកបូជាចារ្យផានបូរី វិលមកបម្រើការងារនៅកម្ពុជាវិញ។

*លោកបូជាចារ្យខ្មែរ សែសាត និងលោកបូជាចារ្យផានបូរី បានមកដល់ប្រទេសកម្ពុជាវិញហើយ ក្រោយពីលោកទាំងពីរបានទៅសិក្សានៅប្រទេសបារាំងមួយរយៈ។ សូមអង្វរព្រះជាម្ចាស់ សូមព្រះអង្គប្រទានកម្លាំងកាយចិត្ត ដល់លោកទាំងពីរក្នុងបេសកកម្មថ្មីផង! លោកទាំងពីរជាបូជាចារ្យ ក្នុងព្រះសហគមន៍កាតូលិកកំពង់ចាម ដែលមានលោកប្រ៊ុយណូ កូសម៍ ជាអភិបាល*



## លោកអភិបាលអន់តូនីសាមី ស៊ូសៃរាជ្យ ទៅសម្រាកនៅបារាំងក្នុងរយៈពេលមួយឆ្នាំ។ សូមបងប្អូនអធិដ្ឋានសម្រាប់លោក។

*លោកអភិបាលអន់តូនីសាមី ស៊ូសៃរាជ្យ បានធ្វើដំណើរទៅកាន់ប្រទេសបារាំង ដើម្បីសម្រាករយៈពេលមួយឆ្នាំ កាលពីថ្ងៃទី១៩ ខែកក្កដានេះ។ លោកអភិបាលអន់តូនីបានចូលនិវត្តន៍ នៅឆ្នាំ២០១៩ ពីមុខងារជាអភិបាលព្រះសហគមន៍កាតូលិកភូមិភាគកំពង់ចាម។ លោកអភិបាលប្រ៊ុយណូ កូសម៍ បន្តមុខងារពីលោក ជាអភិបាលព្រះសហគមន៍កាតូលិកភូមិភាគកំពង់ចាមនាពេលបច្ចុប្បន្ន។*



